ភ្នំពេញ ប៉ុស្តិ៍

ថ្ងៃអង្គារ ទី១២ ខែតុលា ឆ្នាំ២០២១ | អ្នកជោគជ័យ អានភ្នំពេញ ប៉ុស្តិ៍ | លេខ ៣០១១ / តម្លៃ ១២០០ រៀល

លោក ស ខេង ណែនាំឱ្យរដ្ឋបាលខេត្តយកចិត្តទុកដាក់មតិយោបល់របស់ប្រជាពលរដ្ឋ

វ៉ែន ដាវ៉ា

ភ្នំពេញ: លោក ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីបានណែនាំឱ្យរដ្ឋបាលខេត្តនានាយកចិត្តទុកដាក់លើមតិយោបល់របស់ប្រជាពលរដ្ឋ ដើម្បីដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការដោយសិក្ខាពីបទពិសោធរបស់អភិបាលខេត្តដែលដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការបានល្អ ដូចជាលោក ម៉ៅ ធនិន អតីតអភិបាលខេត្តពោធិ៍សាត់ ដែលទើបតែត្រូវបានផ្ទេរតំណែងទៅអភិបាលខេត្តកំពតក្នុងពេលថ្មីៗនេះ។

លោក ស ខេង ថ្លែងបែបនេះនៅពេលដែលលោកធ្វើជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង នៅថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២១។ ក្នុងនោះលោក សុខ លូ អភិបាលខេត្តកំពង់ធំ ត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់ផ្ទេរភារកិច្ចទៅជាអភិបាលខេត្តបាត់ដំបង។ ចំណែកលោក ងួន រតន: អភិបាលខេត្តបាត់ដំបង ត្រូវផ្ទេរទៅជាអភិបាលខេត្តកំពង់ធំវិញ។

លោកថ្លែងថា: «ខ្ញុំក៏សូមស្នើចំណុចមួយចំនួនដែរ គឺការដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការ នេះជាបញ្ហាមួយដែលយើងត្រូវយកចិត្តទុកដាក់។ កន្លងទៅខ្ញុំបានបង្កើតហ្វេសប៊ុកមួយ ដែលមានក្រុមការងារមួយដើម្បីចាំទទួល...តទៅទំព័រ ៤

ក្រសួងការពារជាតិបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ដូសជុំញ កាលពីថ្ងៃអង្គារមិញៗ។ រូបថត General Tea Banh page

កម្ពុជាចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងបង្ការកូវីដ១៩ដូសទី៣ទ្រង់ទាយធំនៅទូទាំងប្រទេស

មុំ គន្ធា

ភ្នំពេញ: កម្ពុជាបានចាប់ផ្តើមនូវយុទ្ធនាការចាក់វ៉ាក់សាំងបង្ការកូវីដ១៩ដូសទី៣ ទ្រង់ទ្រាយធំទៅដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសដែលចាប់ផ្តើមពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ខណ:ដែលដំណើរការចាក់វ៉ាក់សាំងជុំទី១បានជិតសម្រេចតាមផែនការកំណត់ចំនួន១០លាននាក់។

លោក ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិ ដែលបានចូលរួមប្រកាសបើកនូវយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ដូសជុំរុញជូនប្រជាពលរដ្ឋរស់នៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងទូទាំងប្រទេសថ្លែងថា រាជរដ្ឋាភិបាល បានចាត់ទុកនយោបាយចាក់វ៉ាក់សាំងកូវីដ១៩គឺជាយុទ្ធសាស្ត្រគន្លឹះដ៏សំខាន់មួយ និងជាខ្សែក្រវាត់ ការពារទី១សំខាន់ជាង...តទៅទំព័រ ៦

ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-អាមេរិក មានតម្លៃជិត $៥,៥ពាន់លាន

ហ៊ឹន ពិសី

ភ្នំពេញ: ការធ្វើពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងអាមេរិក នៅក្នុងរយៈពេល ៨ខែដំបូងឆ្នាំ ២០២១ មានទឹកប្រាក់សរុបជិត ៥,៥ពាន់លានដុល្លារ កើនជាង ២៨ភាគរយបើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០ ក្នុងនោះការនាំទំនិញពីកម្ពុជាទៅអាមេរិកមានកំណើនជាង ២៧ ភាគរយ។ នេះបើតាមទិន្នន័យពីការិយាល័យជំរឿនអាមេរិក។

ទិន្នន័យចេញផ្សាយនាពេលថ្មីៗនេះឱ្យដឹងថា បើទោះបីជំងឺកូវីដ១៩ នៅបន្តអូសបន្លាយការរីករាលដាលលើពិភពលោក ដែលបណ្តាលឱ្យប៉ះពាល់ដល់ ចង្វាក់ផលិតកម្មមួយចំនួន ក៏ការធ្វើពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងអាមេរិក នៅតែបន្តសញ្ញាវិជ្ជមាន ដោយគិតចាប់ពីខែមករា មកដល់ខែសីហា ឆ្នាំ ២០២១ មាន...តទៅទំព័រ ៩

ព្រះរាជពិធីបុណ្យអុំទូកនឹងត្រូវធ្លាក់ក្នុងឆ្នាំនេះដោយសារការរីករាលដាលនៃជំងឺកូវីដ១៩

មុំ គន្ធា

ភ្នំពេញ: ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ សម្រាប់ឆ្នាំ ២០២១នេះ នឹងមិនអនុញ្ញាតឱ្យមានការប្រារព្ធដូចឆ្នាំមុនៗឡើយ ដោយសារតែការរីករាលដាលនៃមេរោគកូវីដ១៩។ នេះជាការបញ្ជាក់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ក្នុងពិធីប្រកាសចូលកាន់មុខតំណែងអភិបាលខេត្តបាត់ដំបង នាថ្ងៃទី១១ ខែតុលា។

លោក ស ខេង...តទៅទំព័រ ២

គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេស ៧៥ ត្រូវបានអនុម័ត

ហ៊ឹន ពិសី

ភ្នំពេញ: គម្រោងវិនិយោគឯកជននៅក្រៅតំបន់សេដ្ឋកិច្ចពិសេសចំនួន ៧៥គម្រោង ត្រូវបានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័តក្នុងរយៈពេល ៨ខែដើមឆ្នាំ២០២១ ធ្លាក់ជិត ៣០ភាគរយធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ នេះបើតាមរបាយការណ៍ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។...តទៅទំព័រ ១០

សេដ្ឋកិច្ច

ក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជាចំនួន២ បានបង្ហាញពីភាពរីកចម្រើននៃអាជីវកម្មរបស់ខ្លួន...ទំព័រ ៩

អន្តរជាតិ

តៃវ៉ាន់ថា ខ្លួននឹងមិនចុះចាញ់ដោយមានសម្ពាធពីចិនឡើយ ទោះបីមានការអំពាវនាវបង្រួបបង្រួមពីទីក្រុងប៉េកាំង...ទំព័រ ១១

ជីវិតកម្សាន្ត

ស្រីស្រស់កញ្ញា ប៉ូតឹមចេង សុធីតា បានត្រងមកុដកញ្ញាឯកដ៏អស្ចារ្យនៃកម្ពុជាឆ្នាំ ២០២១...ទំព័រ ១៣

ព្រះរាជពិធីបុណ្យអុំទូកនឹងត្រូវផ្អាក...

ទិដ្ឋភាពការប្រណាំងទូកក្នុងពិធីបុណ្យអុំទូក កាលពីឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ។ រូបថត ហេង ជីវិន

តពីទំព័រ ១...មានប្រសាសន៍ថា៖«ឥឡូវនេះចូលដល់ខែតុលា តាមការសម្រេចរបស់រាជរដ្ឋាភិបាល គឺឆ្នាំនេះ យើងមិនបានប្រារព្ធពិធីបុណ្យអុំទូក អកអំបុក ដូចបណ្ដាឆ្នាំមុនៗទេ ដោយសារបញ្ហាកូវីដនេះឯង។ ប៉ុន្តែនៅឆ្នាំ២០២២ ដែលនឹងឈានចូលមកដល់នោះ យើងមានព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយរបស់ជាតិ ដែលមិនអាចរំលងបាន គឺការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់»។

នៅឆ្នាំ២០២១នេះព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ ប្រសិនបើអាចប្រារព្ធបាន នឹងត្រូវធ្វើឡើងក្នុងរយៈពេល៣ថ្ងៃ ដែលចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២០ ខែវិច្ឆិកាខាងមុខនេះ។

លោកស ខេង ដែលក៏ជាឧបនាយករដ្ឋមន្ត្រីផងនោះ បានអំពាវនាវ នាឱកាសនោះផងដែរ ដោយប្រាប់ឱ្យប្រជាពលរដ្ឋត្រូវរៀនរស់ក្នុងស្ថានភាពកូវីដ១៩ ដែលមេរោគនេះមិនទាន់មានភាពធូរស្រាលនៅឡើយទេ។

លោកបានបញ្ជាក់ថា៖«មកដល់ពេលនេះមិនទាន់មានអ្នកណាទស្សន៍ទាយ ឬសន្និដ្ឋានជាក់លាក់ថា ឆ្នាំណាមេរោគនេះនឹងបញ្ចប់ទេ។ ដូច្នេះ ប្រសិនបើយើងមិនបញ្ចប់បញ្ហានេះទេ ហើយយើងនៅបន្តបិទប្រទេសទាំងមូល ឬដាច់ដោយដុំៗក៏ដោយ ក៏វានៅតែប៉ះពាល់ទៅដល់សេដ្ឋកិច្ចសង្គម និងជីវភាពរបស់ប្រជាពលរដ្ឋ។ ដូចនេះយើងត្រូវរៀនរស់ក្នុងស្ថានភាពកូវីដ»។

មន្ត្រីនៃគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មិនអាចទាក់ទងសុំព័ត៌មានបន្ថែមទាក់ទងនឹងពិធីបុណ្យអុំទូកនេះបានទេ កាលពីថ្ងៃទី១១ ខែតុលា។

គួរបញ្ជាក់ផងដែរថា កាលពីឆ្នាំ២០២០ រាជរដ្ឋាភិបាលកម្ពុជា ក៏បានសម្រេចផ្អាកការប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ ដូចគ្នាផងដែរ ដោយសារមានការឆ្លងនៃវីរុសកូវីដ១៩ តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។

លោកប៊ុត រ៉ា អាយុ២៥ឆ្នាំ ជាកម្មករសំណង់ បានប្រាប់ភ្នំពេញប៉ុស្ដិ៍ នៅថ្ងៃទី១១ ខែតុលាថា លោកក៏មិនចង់ឱ្យមានការប្រារព្ធពិធីបុណ្យអុំទូកនេះដែរ ដោយសារប្រទេសកម្ពុជានៅមានអ្នកឆ្លងជំងឺកូវីដ១៩ច្រើន។ លោកបារម្ភថាវាអាចនឹងផ្ទុះការឆ្លងជំងឺនេះកាន់តែខ្លាំងថែមទៀត។

លោកនិយាយថា៖«ទាំងគេទាំងខ្ញុំ គឺចង់សប្បាយ ចង់ឈប់សម្រាកជួបជុំគ្រួសារមិត្តភក្តិ ប៉ុន្តែដូចយើងដឹងស្រាប់ហើយប្រទេសយើងនៅមានអ្នកឆ្លងវីរុសកូវីដ១៩ច្រើនណាស់។ មិនធ្វើពិធីបុណ្យនេះគឺល្អណាស់»។

ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ ធ្លាប់ត្រូវបានផ្អាកការប្រារព្ធរយៈពេល៣ឆ្នាំជាប់ៗគ្នា គឺឆ្នាំ២០១១ ២០១២ និងឆ្នាំ២០១៣ បន្ទាប់ពីមានព្រឹត្តិការណ៍រត់ជាន់គ្នាលើស្ពាននៅកោះពេជ្រ ដែលបណ្ដាលឱ្យមានមនុស្សជាច្រើនរយនាក់បានស្លាប់និងរបួសផងដែរ។ ការផ្អាកបន្តបន្ទាប់ទៀត គឺដោយសារគ្រោះទឹកជំនន់ និងក្រោយការសោយទិវង្គតរបស់ព្រះបរមរតនកោដ្ឋព្រះបាទសម្តេចព្រះនរោត្តម សីហនុ។ នៅឆ្នាំ២០១៥ ពិធីបុណ្យនេះក៏ត្រូវបានផ្អាកម្តងទៀតដោយសារទឹកទន្លេរាក់ពេកដែលធ្វើឱ្យទូកមិនអាចអុំបាន៕ ■

Cambodian Mine Action and Victim Assistance Authority (CMAA)

Project: Clearing for Results IV

VACANCY ANNOUNCEMENT FORINTERNATIONAL CONSULTANT ON SOUTH-SOUTH COOPERATION

(From 1st January to 30thApril 2022 with possibility of extension)

1) The Royal Government of Cambodia,represented by the Cambodian Mine Action andVictim Assistance Authority (CMAA) now invites internationalqualified consultants to submit the Letter of Application and Curriculum Vitae(CV) for the position of International Consultant on South-South Cooperation.

2) Detailed information of the TOR with requirementscan be obtained from the address given below or from CMAA website:www.cmaa.gov.kh.

3) The submission deadline is at 10am on25thOctober 2021.

4) The address for obtaining the TOR and for submission is:
Human Resource Unit, CMAA
Street 273 Corner 516,
Sangkat Toul Sangker, Khan Russey Keo, Phnom Penh, Cambodia
Tel: 098 581 009Email: moulekachea@gmail.com

បសស ណែនាំមន្ត្រីមិនឱ្យផ្តល់សេវាជូនដល់អ្នកដែលមិនបានបង្ហាញបណ្ណចាក់វ៉ាក់សាំង

ឡាយ សាមាន

ភ្នំពេញ: បេឡាជាតិរបបសន្តិសុខសង្គម (បសស) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានណែនាំដល់គ្រប់ទីស្នាក់ការ (បសស) ទូទាំងរាជធានី-ខេត្តមិនត្រូវផ្តល់សេវាជូនកម្មករនិយោជិតឬពលរដ្ឋដែលមិនបង្ហាញបណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ទេ។

បសស កាលពីថ្ងៃទី១០ ខែតុលា បានជូនដំណឹងដល់នាយកឬម្ចាស់សហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិត ព្រមទាំងសាធារណជនទាំងអស់ត្រូវតែបង្ហាញបណ្ណចាក់វ៉ាក់សាំងកូវីដ១៩រាល់ពេលទៅរកសេវា (បសស) នៅតាមទីតាំងភ្នាក់ងាររបស់ខ្លួនបើពុំនោះទេនឹងមិនផ្តល់សេវាជូនឡើយ។

បសស បន្តថា៖ «ចាប់ពីថ្ងៃជូនដំណឹងនេះតទៅរាល់ពេលលោក លោកស្រីមកទទួលសេវានៅគ្រប់ទីស្នាក់ការ បសស ទូទាំងរាជធានី-ខេត្ត ខណ្ឌទាំងអស់ត្រូវបង្ហាញបណ្ណចាក់វ៉ាក់សាំងកូវីដ១៩ ឬ បណ្ណចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ឬ លិខិតបញ្ជាក់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩»។

បើតាម បសស ការណែនាំនេះដោយយោងតាមសេចក្តីណែនាំរបស់សាលារាជធានីភ្នំពេញកាលពីថ្ងៃទី៥ ខែតុលា ដោយតម្រូវឱ្យពលរដ្ឋបង្ហាញបណ្ណចាក់វ៉ាក់សាំងកូវីដ១៩ឬលិខិតបញ្ជាក់ការចាក់វ៉ាក់សាំងរាល់ពេលចេញ-ចូលគ្រឹះស្ថានសិក្សា ផ្សារ និងទីតាំងអាជីវកម្មដ្ឋាននានាក្នុងភូមិសាស្ត្ររាជធានីដើម្បីគ្រប់គ្រងការរីករាលដាលនៃជំងឺរាតត្បាតនេះឱ្យកាន់តែមានប្រសិទ្ធភាព។

រដ្ឋបាលរាជធានីភ្នំពេញបន្តថា៖ «ប្រសិនបើមានបុគ្គលណាម្នាក់មិនព្រមសហការបង្ហាញបណ្ណចាក់វ៉ាក់សាំង ដាច់ខាតមិនត្រូវអនុញ្ញាតឱ្យចូលក្នុងទីតាំងឬទីកន្លែងរបស់ខ្លួនឡើយ និងត្រូវរាយការណ៍ទៅអាជ្ញាធរក្បែរនោះជាបន្ទាន់»។

នាយករងអង្គការសិទ្ធិមនុស្សលីកាដូ (LICADHO) លោក អំ សំអាត យល់ថា លក្ខខណ្ឌរបស់ បសស នាពេលនេះចង់ជំរុញទាំងកម្មករ និងអ្នកដែលមានបណ្ណ បសស ឱ្យចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ឱ្យបានគ្រប់ៗគ្នា។ ប៉ុន្តែលោកបន្តថា ការធ្វើបែបនេះធ្វើឱ្យប៉ះពាល់ដល់ការទទួលបានសេវាសាធារណៈរបស់ប្រជាជន។ ទោះយ៉ាងណាលោកជឿថា៖«មកដល់ពេលនេះប្រជាពលរដ្ឋស្ទើរគ្រប់គ្នាហើយទទួលបានការចាក់វ៉ាក់សាំងកូវីដ១៩»។

លោកថ្លែងថា ការទទួលបានសេវាសុខភាពសាធារណៈពលរដ្ឋគួរទទួលបានដូចៗគ្នា ដោយសារអ្នកដែលមានបណ្ណបសស គឺពួកគេក៏មានកាតព្វកិច្ចបង់សេវានេះផងដែរ។

លោកថា៖ «តែបើមើលទិដ្ឋភាពទូទៅវិញ ការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ ទោះបីជាមានបណ្ណឬមិនមានបណ្ណចាក់វ៉ាក់សាំងក៏ដោយ ពលរដ្ឋត្រូវតែទទួលបានការព្យាបាលផ្នែកសុខភាពសាធារណៈដូចគ្នា ជាពិសេសទាក់ទងបសស គឺពលរដ្ឋមានការបង់សេវាសម្រាប់ បសស»។

បើតាមរបាយការណ៍របស់ក្រសួងសុខាភិបាលគិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី៦ឆ្នាំឡើង សរុបជាង ១៣លាននាក់ឬស្មើនឹង៨៤,-៣៣%ធៀបនឹងគោលដៅចំនួន១៦លាននាក់បានទទួលការចាក់វ៉ាក់សាំង៕ ■

សំណង់ជាង១០តូប សង់រំលោភលើដីចំណីផ្លូវ និងសង់លើប្រព័ន្ធលូ នៅរាជធានី ត្រូវបានរុះរើ

ឡុង គីមម៉ារីតា

ភ្នំពេញ: អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ចុះរុះរើសំណង់ដែលសង់រំលោភលើដីចំណីផ្លូវ សាងសង់លើប្រព័ន្ធលូ និងបានចាក់សាបបេតុងចូលរំលោភលើផ្លូវជិត២ម៉ែត្រ ជាង ១០តូប ដែលស្ថិតនៅភូមិត្រពាំងទា សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ប្រតិបត្តិការចុះរុះរើនេះបានធ្វើឡើងនៅថ្ងៃទី១១ ខែតុលា បន្ទាប់ពីមានការបញ្ជាផ្ទាល់ពីលោកឃួងស្រេងអភិបាលរាជធានីភ្នំពេញ ដែលដឹកនាំដោយលោកសុយ សារិទ្ធិ អភិបាលរងរាជធានីភ្នំពេញ។ លោកហែម ដារិទ្ធិ អភិបាលខណ្ឌពោធិ៍សែនជ័យ បានដឹកនាំក្រុមការងារ ចុះធ្វើការរុះរើសំណង់សាងសង់រំលោភលើចិញ្ចើមផ្លូវសាធារណៈនៅទីតាំងផ្ទាល់។

លោកប៉ាង លីដា អភិបាលរងខណ្ឌ និងក្រុមការងារ ដែលបានចុះអនុវត្តការងាររុះរើសំណង់ដោយផ្ទាល់បានប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១នេះ ថាសំណង់ដែលត្រូវបានរុះរើនេះគឺមានជាង១០តូប ដែលមានម្ចាស់តែម្នាក់ ដោយបានសង់រំលោភផ្លូវសាធារណៈជាយូរមកហើយ។

លោកថ្លែង...តទៅទំព័រ ៣

អាជ្ញាធរខណ្ឌពោធិ៍សែនជ័យ ចុះរុះរើសំណង់សង់លើចំណីផ្លូវពីថ្ងៃទី១១ តុលា។ រូប FB

កម្ពុជា-ស៊ែប៊ី ប្តេជ្ញាពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលាយ

រី សុចាន់

លោក អ៊ុច បូរិទ្ធ រដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស។ រូបថត ក្រសួងការបរទេស

ភ្នំពេញ: កម្ពុជា និងស៊ែប៊ី ប្តេជ្ញាពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែទូលំទូលាយ និងស៊ីជម្រៅថែមទៀតក្នុងវិស័យនយោបាយ សេដ្ឋកិច្ច ទេសចរណ៍ និងវិនិយោគ ដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រទេសទាំង២ និងឯកភាពបន្តគាំទ្រគ្នាទៅវិញទៅមកលើឆាកអន្តរជាតិ។

ការប្រកាសជំហរបែបនេះធ្វើឡើងក្នុងជំនួបទ្វេភាគីរវាងលោកអ៊ុច បូរិទ្ធ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោក នីកូឡា សេឡាកូវិច (Nicola Selakovic) រដ្ឋមន្ត្រីការបរទេសស៊ែប៊ី កាលពីថ្ងៃទី១០ ខែតុលា នៅទីស្តីការក្រសួងការបរទេសស៊ែប៊ី នៅក្នុងឱកាសដែលលោកតំណាងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចូលរួមកិច្ចប្រជុំជាន់ខ្ពស់រំឭកខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតចលនាមិនចូលបក្សសម្ព័ន្ធ ដែលរៀបចំឡើងនៅថ្ងៃទី១១-១២ ខែតុលា នៅទីក្រុងប៊ែលក្រាត ប្រទេសស៊ែប៊ី។

ក្រសួងការបរទេសកម្ពុជា បញ្ជាក់ក្នុងសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី១១ ខែតុលា ថា ភាគីទាំង២បានធ្វើការពិភាក្សាផ្លាស់ប្តូរមតិគ្នាដោយផ្តោតសំខាន់លើចំណងមិត្តភាពដ៏យូរលង់ និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរប្រកបដោយផ្លែផ្ការវាងប្រទេសទាំង២ ពូនជ្រុំដោយអតីតអ្នកដឹកនាំដ៏ឆ្នើមប្រទេសទាំង២តាំងពីឆ្នាំ១៩៥៧។

សេចក្តីប្រកាសព័ត៌មានបញ្ជាក់ថា៖ «ភាគីទាំង២គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ភាគីទាំង២ក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងវិស័យនយោបាយ សេដ្ឋកិច្ច ទេសចរណ៍ និងវិនិយោគ។ល។ ដើម្បីផលប្រយោជន៍រួមនៃប្រជាជាតិទាំង២»។

បើតាមសេចក្តីប្រកាសព័ត៌មានដដែលលោក នីកូឡា សេឡាកូវិច បានថ្លែងថា រដ្ឋាភិបាលស៊ែប៊ី បានត្រៀមខ្លួនជាស្រេចក្នុងការទទួលស្វាគមន៍ «យ៉ាងកក់ក្តៅ» ដំណើរទស្សនកិច្ចរបស់លោក ហ៊ុន សែន នៅប្រទេសស៊ែប៊ី ដែលបានត្រោងទុករួចមកហើយ ដើម្បីធ្វើឱ្យចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសស៊ែប៊ី និងកម្ពុជា កាន់តែទូលំទូលាយ ស៊ីជម្រៅថែមទៀត។

ក្រសួងការបរទេសបានដកស្រង់សម្តីលោកនីកូឡា សេឡាកូវិច ថា៖ «រដ្ឋាភិបាលស៊ែប៊ីកំពុងពិចារណាបើកស្ថានបេសកកម្មរបស់ខ្លួននៅតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅកម្ពុជា ហើយនៅក្នុងដំណាច់ឆ្នាំនេះរដ្ឋាភិបាលស៊ែប៊ី និងបញ្ជូនគណៈប្រតិភូរបស់ខ្លួនទៅទស្សនកិច្ច នៅបណ្តាប្រទេសក្នុងតំបន់ និងកម្ពុជា ដើម្បីសិក្សាអំពីបញ្ហានេះ»។

បើយោងតាមសេចក្តីប្រកាសព័ត៌មានដដែល ចំពោះអ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការរវាងប្រទេសទាំង២ ភាគីស៊ែប៊ីបានអះអាងថា សភាស៊ែប៊ីនឹងផ្តល់សន្យាប័នក្នុងពេលឆាប់ៗខាងមុខនេះ។

ប្រភពដដែលថា៖ «លើសពីនេះទៅទៀត ភាគីទាំង២បានឯកភាពគ្នាជំរុញកិច្ចសហប្រតិបត្តិការ វិស័យការទូតសេដ្ឋកិច្ចរវាងប្រទេសទាំង២ឱ្យកាន់តែរីកចម្រើនថែមទៀត និងឯកភាពបន្តគាំទ្រគ្នាទៅវិញទៅមកលើឆាកអន្តរជាតិ»។

លោក គិន តា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា និងជាអ្នកវិភាគបញ្ជាននយោបាយថ្លែងថា កម្ពុជាក្នុងក្របខ័ណ្ឌកិច្ចខិតខំប្រឹងប្រែងក្នុងកិច្ចការទូតរបស់ខ្លួនរយៈពេលចុងក្រោយនេះព្យាយាមធ្វើពិពិធកម្មការទូតដោយជំរុញ និងលើកកម្ពស់ទំនាក់ទំនងរបស់កម្ពុជា និងបណ្តាប្រទេសនានាទាំងក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោកជាទម្រង់ទ្វេភាគី និងពហុភាគី។ «យើងឃើញនិន្នាការរួម ទាំងនិន្នាការតំបន់ក៏ដូចជាពិភពលោកបច្ចុប្បន្នគឺហាក់ដូចជាឆ្ពោះទៅរកនិន្នាការពហុភាគីនិយម។ យើងឃើញប្រទេសនានារាប់ទាំងកម្ពុជាផងហាក់ដូចជាមានភាពឆ្លាតវៃច្រើនក្នុងការពង្រីកទំនាក់ទំនងការទូតរបស់ខ្លួនទៅកាន់បណ្តាប្រទេសផ្សេងៗ ទាំងក្នុងតំបន់ និងពិភពលោក គឺផលប្រយោជន៍សម្រាប់សេដ្ឋកិច្ចនយោបាយ និងការទូត»៕ ■

សំណង់ជាង១០គួប សង់រំលោភលើដីចំណីផ្លូវ និងសង់លើ...

តពីទំព័រ ២ ...ថា៖«មុនពេលចុះទៅរុះរើ អាជ្ញាធរខណ្ឌបានជូនដំណឹង និងបានទុកពេលឱ្យម្ចាស់សំណង់រុះរើដោយខ្លួនឯងក្រោយភ្ជុំហើយ។ ប៉ុន្តែ មកដល់ពេលនេះ ម្ចាស់សំណង់ នៅតែមិនបានរុះរើ។ ដូចនេះអាជ្ញាធរសម្រេចប្រើវិធានការក្តៅចុះរុះរើតែម្តង»។

បើតាមលោកប៉ាង លីដា អស់រយៈពេលជិត១ឆ្នាំកន្លងមកហើយ ដែលសំណង់ខុសច្បាប់នេះត្រូវបានសាងសង់រំលោភលើដីចំណីផ្លូវ សាងសង់លើប្រព័ន្ធលូ និងបានចាក់សាបបេតុងចូលរំលោភលើផ្លូវជិត២ម៉ែត្រ។ កាលពីថ្ងៃទី១០ ខែតុលា ម្ចាស់សំណង់ ក៏បានបន្តការសាងសង់ដោយបានបាំងសង្កសីពីក្រៅ ដើម្បីឱ្យក្រុមជាងលួចធ្វើខាងក្នុងទៀតផង។

លោកគង់ រតនៈ ប្រធានវិទ្យាស្ថានជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក លើកឡើងថា បញ្ហានៃការរំលោភបំពានដីចំណីផ្លូវចេះតែកើតមាន អាចបណ្តាលមកពីកត្តា៣។ ទី១ មកពីអាជ្ញាធរមូលដ្ឋានអាចនឹងទទួលបានលាភសក្ការៈ ឬប្រយោជន៍នៃការសាងសង់ទាំងនេះ ដែលបណ្តាលឱ្យបញ្ហានេះចេះតែកើតមានឡើងជាបន្តបន្ទាប់។

ចំណុចទី២ លោកមើលឃើញថា ចំពោះបញ្ហានេះប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ក៏បានដឹងដែរថា ការរំលោភយកដីចំណីផ្លូវ គឺជាអំពើខុសច្បាប់។ ប៉ុន្តែពួកគេនៅបន្តរំលោភបំពាន ដោយគិតថាការធ្វើបែបនេះ នឹងទទួលបាននូវផលប្រយោជន៍ផ្ទាល់ខ្លួន បណ្តោះអាសន្នក្នុងករណីដែលអាជ្ញាធរមិនមានចំណាត់ការ។

រីឯចំណុចទី៣ លោកគង់ រតនៈ មើលឃើញថា ការដែលបញ្ហានៃការរំលោភបំពានដីចំណី ឬផ្លូវសាធារណៈនេះ ក៏ព្រោះតែរាល់ចំណាត់ការដែលមានចំពោះអ្នករំលោភបំពានទាំងនេះ គឺច្រើនតែធ្វើឡើងតាមបញ្ជាពីថ្នាក់លើ ឬធ្វើឡើងជាប្រព័ន្ធ ដែលនាំឱ្យការបង្ក្រាបនោះ ហាក់មានការខ្វះចន្លោះ។

លោកបញ្ជាក់ថា៖«ទាក់ទងនឹងវិធានការទាំងនេះ ខ្ញុំគិតថាប្រសិទ្ធភាពនេះ គឺហាក់ដូចជាមិនទាន់ធ្វើបានល្អទេ។ ខ្ញុំគិតថា អាជ្ញាធរ គួរតែស្វែងរក ឬសគល់ថា ហេតុអ្វីបានប្រជាពលរដ្ឋហ្នឹង គាត់សម្រេចចិត្តសាងសង់សំណង់លើផ្លូវសាធារណៈ។ មួយទៀតយើងត្រូវផ្តោតលើយុទ្ធសាស្ត្របង្ការ កុំឱ្យពលរដ្ឋរំលោភបំពានបន្ថែមទៀត»៕ ■

មន្ត្រីសហការដាំកូនឈើ និងជិះកង់អបអរសាទរក្រុងសៀមរាបត្រូវជ្រើសជាក្រុងវប្បធម៌អាស៊ាន

ឡាយ សាមាន

សៀមរាប: ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយអាជ្ញាធរជាតិអប្សរា បានរៀបចំពិធីដាំកូនឈើ និងជិះកង់នៅរមណីយដ្ឋានអង្គរ ដើម្បីអបអរសាទរក្រុងសៀមរាប ដែលត្រូវបានជ្រើសរើសជាទីក្រុងវប្បធម៌អាស៊ានសម្រាប់ឆ្នាំ២០២១-២០២២។

ពិធីដាំកូនឈើ និងជិះកង់នេះ ត្រូវបានធ្វើឡើងនៅក្នុងតំបន់រមណីយដ្ឋានអង្គរ កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ដោយមានការចូលរួមពីលោក ស៊ុំ ម៉ាប់ រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ លោកស្រី យូ សុភា អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប លោក ហង់ ៣ អគ្គនាយកអាជ្ញាធរជាតិអប្សរា និងតំណាងស្ថានទូតមួយចំនួនផងដែរ។

មន្ត្រីដាំកូនឈើនៅតំបន់រមណីយដ្ឋានអង្គរ។ រូបថត មន្ទីរព័ត៌មាន

លោក ហង់ ៣ បានថ្លែងថា ការរៀបចំពិធីនេះដើម្បីបង្ហាញពីសកម្មភាពរបស់កម្ពុជាទៅកាន់សមាជិកអាស៊ាន ក្នុងនាមកម្ពុជាជាប្រធានអាស៊ានប្តូរវេនផ្នែកវប្បធម៌។

លោកបន្តថា៖ «ជាធម្មតាយើងមានតួនាទីក្នុងការប្តូរវេនគ្នាជាប្រធានអាស៊ានផ្នែកវប្បធម៌ អ៊ីចឹងនៅថ្ងៃនេះក្រសួងវប្បធម៌ បានរៀបចំពិធីដាំកូនឈើ និងជិះកង់ ដែលប្រទេសកម្ពុជា គឺជាប្រធានអាស៊ានសម្រាប់ឆ្នាំ២០២១-២០២២ ដូច្នេះយើងបានជ្រើសរើសក្រុងសៀមរាបជាទីក្រុងវប្បធម៌អាស៊ាន»។

លោកបន្តថា ការធ្វើជាប្រធានអាស៊ានប្តូរវេននេះមានរយៈពេល២ឆ្នាំម្តង ដោយប្រទេសនីមួយៗត្រូវជ្រើសរើសក្រុងនៃប្រទេសរបស់ខ្លួន ដើម្បីដាក់ចូលទៅក្នុងគណៈកម្មការរបស់អាស៊ាន ដើម្បីវាយតម្លៃថាក្រុងនោះអាចទទួលជាក្រុងវប្បធម៌អាស៊ាន។

លោកបានគូសបញ្ជាក់ថា មូលហេតុដែលកម្ពុជាជ្រើសរើសក្រុងសៀមរាបជាទីក្រុងវប្បធម៌អាស៊ាន ដោយសារសៀមរាបជាទីកន្លែងប្រមូលផ្តុំដោយវប្បធម៌ខ្មែរ។

លោកបន្តថា៖ «ដោយសារសៀមរាបគឺជាប្រភពដើម និងកំណើត និងជាក្រុងវប្បធម៌របស់ប្រទេសកម្ពុជាតាំងពីយូរលង់ណាស់មកហើយ អ៊ីចឹងមានន័យថាអ្វីៗអាស្រ័យទៅលើប្រទេសនីមួយៗដែលជ្រើសរើសក្រុងរបស់ខ្លួនដាក់ចូលជាក្រុងវប្បធម៌អាស៊ាន»។

លោកហង់ ៣ បន្តថា ជាធម្មតាក្នុងនាមជាប្រធានប្តូរវេន នឹងអញ្ជើញសមាជិកអាស៊ានមកទស្សនាក្រុងវប្បធម៌អាស៊ាននៅកម្ពុជា ប៉ុន្តែដោយសារបញ្ហាកូវីដ១៩ ទើបធ្វើឱ្យកម្មវិធីមួយចំនួនត្រូវបានផ្អាកជាបណ្តោះអាសន្ន។

លោកបន្តថា៖ «ជាធម្មតាបើសិនមិនមានបញ្ហាកាលដាលនៃជំងឺកូវីដ១៩ ទេ ប្រទេសនីមួយៗនឹងអញ្ជើញភាគីដែលជាប្រទេសអាស៊ានចូលទស្សនាក្រុងវប្បធម៌អាស៊ាន ដើម្បីបង្ហាញឱ្យឃើញពីសកម្មភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសនានា»។ «តែចៃដន្យក្នុងបរិបទកូវីដ១៩ តាំងពីដើមឆ្នាំ២០២០ គឺយើងបានទទួលនូវបញ្ហាកូវីដ ដែលធ្វើឱ្យយើងមិនអាចបង្ហាញពីសកម្មភាពនានានៃការជួបជុំ ដូច្នេះហើយថ្ងៃនេះគឺជាពិធីមួយក្នុងចំណោមពិធីនានា ដែលក្រសួងវប្បធម៌រៀបចំដើម្បីបង្ហាញថាអ្វីទៅដែលជាក្រុងវប្បធម៌របស់អាស៊ាន»។

លោក ហង់ ៣ បានឱ្យដឹងទៀតថា ការរៀបចំឱ្យមានក្រុងវប្បធម៌អាស៊ាន ដើម្បីចែករំលែក និងដើម្បីស្វែងយល់ពីវប្បធម៌ពីគ្នាទៅវិញទៅមក។

សូមជម្រាបថា ទីក្រុងវប្បធម៌អាស៊ាន ដែលបានជ្រើសរើសកន្លងមករួមមាន១- ទីក្រុង Cebu នៃប្រទេសហ្វីលីពីន ចាប់ពីឆ្នាំ២០១០ -២០១១។ ២-ទីក្រុង Singapore នៃប្រទេសសិង្ហបុរី ចាប់ពីឆ្នាំ២០១២-២០១៣។ ៣- ទីក្រុង Hue នៃប្រទេសវៀតណាម ចាប់ពីឆ្នាំ២០១៤-២០១៥។ ៤- ទីក្រុង Bandar Seri Begawan នៃប្រទេសប្រ៊ុយណេ ចាប់ឆ្នាំ២០១៦-២០១៧។ ៥- ទីក្រុង Yogyakarta នៃប្រទេសឥណ្ឌូនេស៊ី ចាប់ពីឆ្នាំ២០១៨-២០២០។

សម្រាប់កម្ពុជាជ្រើសរើសក្រុងសៀមរាប ជាទីក្រុងវប្បធម៌អាស៊ាន ចាប់ពីឆ្នាំ២០២១-២០២២៕ ■

លោក ស ខេង ណែនាំឱ្យរដ្ឋបាលខេត្ត...

តពីទំព័រ១...យកនូវសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ»។

លោកបន្តថា៖ «និយាយរួមយើងលើកចំហាយើញថា ដូចជាទទួលបានផលល្អ គឺមានប្រហែលជិត១ពាន់ករណី ដែលមានសំណូមពរជាច្រើនដែលយើងបានដោះស្រាយ ទោះបីជាយើងមិនទាន់បានដោះស្រាយបានទាំងស្រុងក៏ដោយ»។

លោក ស ខេង លើកឡើងថា វិធីដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋនៅក្រៅប្រព័ន្ធតុលាការបែបនេះ មិនមែនដោយសារមិនទុកចិត្តរដ្ឋបាលខេត្តនៅនឹងកន្លែងនោះទេ។ប៉ុន្តែក៏ជាការបង្កលក្ខណៈឱ្យមានជម្រើសជូនដល់ប្រជាពលរដ្ឋក្នុងការស្វែងរកការដោះស្រាយបញ្ហានានា។

លោក ស ខេង នៅក្នុងពិធីផ្ទេរតំណែងអភិបាលខេត្តបាត់ដំបងនៅថ្ងៃ១១ តុលា។ រូបថត Sar Kheng Page

លោកបញ្ជាក់ថា៖ «ជួនអីដោះស្រាយនៅកន្លែងណាមួយនោះមិនបាន ឬវាមិនយុត្តិធម៌។ យើងទុកផ្លូវឱ្យគាត់ បើដោះរបៀបហ្នឹងមិនបានទេ យើងត្រូវដោះមួយទៀតដើម្បីនឹងដោះ។ អីចឹងទេ ខ្ញុំគិតថា យើងត្រូវហ៊ានបើកចំហដើម្បីទទួលយកមតិយោបល់របស់ប្រជាពលរដ្ឋនោះ ក៏ចាត់ទុកថា យើងយកកញ្ចក់មកឆ្លុះហើយ។ ប្រជាពលរដ្ឋគាត់ហ៊ានថា ហ៊ាននិយាយក្នុងន័យស្ថាបនា»។

លោក ស ខេង បានណែនាំថា ក្នុងនាមជាមន្ត្រីបម្រើការជូនជាតិនិងប្រជាពលរដ្ឋត្រូវហាមចូលប្រឡូកជាមួយបញ្ហាទាំងអស់នោះដែលប្រជាពលរដ្ឋមានសំណូមពរមកហើយឱ្យជួយដោះស្រាយដល់ប្រជាពលរដ្ឋ។

លោកបានបញ្ជាក់ថា៖ «ម៉ៅ ធនិន គាត់មានវិធីដោះស្រាយមួយ សូមឱ្យសិក្សាមើល ចំណុចណាដែលគាត់ដោះស្រាយបានល្អ ជាមេរៀន បទពិសោធយើងក៏គួរតែយកមករៀនដែរ។ យកមករៀនបទពិសោធដែលដោះស្រាយ អាហ្នឹងជាបទពិសោធមួយ»។

លោកបន្តថា៖ «អីចឹងគឺថា ខំប្រមូលបញ្ហា ហើយយើងទុកលទ្ធភាពថា បើសិនដោះស្រាយនៅកន្លែងមិនបានទេ ដោះស្រាយតាមឋានានុក្រមមិនបានទេ យើងក៏បើកឱកាសដើម្បីឱ្យគាត់ប្តឹងទៅ។ ជួនអីប្តឹងទៅដល់សម្តេចតេជោ លោកក៏ខិតខំដោះស្រាយតាមជាក់ស្តែង»។

លោកឧបនាយករដ្ឋមន្ត្រី បានណែនាំឱ្យមន្ត្រីនៅថ្នាក់ក្រោមជាតិ កុំបិទទុកបញ្ហា ត្រូវឱ្យពលរដ្ឋមានមតិយោបល់ ក្នុងន័យស្ថាបនា ក្នុងន័យដែលស្មោះត្រង់ ដើម្បីជួយរកយុត្តិធម៌ដល់ប្រជាពលរដ្ឋ។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យអង្គការសមាគមអាដហុកបានថ្លែងថា តាមសង្កេត ការអនុវត្តកន្លងមក គឺមានតែអតីតអភិបាលខេត្តពោធិ៍សាត់មួយប៉ុណ្ណោះដែលបានប្រើប្រាស់វិធីសាស្ត្រដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការដល់ប្រជាពលរដ្ឋ។ចំណែកអភិបាលខេត្តផ្សេងទៀតគឺមិនមានការអនុវត្តក្រៅប្រព័ន្ធតុលាការនោះទេ។

លោកបានថ្លែងថា៖«ខ្ញុំយល់ថា ការណែនាំនេះ គឺល្អប្រសើរ ចៀសវាងកុំឱ្យមានស្តង់ដា២ ដោយសារតែរដ្ឋបាលខេត្តមួយចំនួនអត់បានយកចិត្តទុកដាក់ក្នុងការដោះស្រាយជូនប្រជាពលរដ្ឋទេ ដែលជាហេតុធ្វើឱ្យករណីមួយចំនួននៅតែមានបញ្ហារ៉ាំរ៉ៃយឺតយ៉ាវនាំឱ្យមានបញ្ហាដល់ពលរដ្ឋរងគ្រោះដែលរង់ចាំដំណោះស្រាយយុត្តិធម៌ដល់ពួកគាត់»។

យ៉ាងណាក្តី លោក សែនករុណា បានសម្គាល់ថា លោក ម៉ៅ ធនិន អតីតអភិបាលខេត្តពោធិ៍សាត់ ដោះស្រាយបញ្ហាក្រៅប្រព័ន្ធតុលាការកន្លងមក នោះក៏បានលើកយកតែបញ្ហាតូចតាច ជាលក្ខណៈវិវាទមិនទាន់ធំដុំ តែមិនទាន់ដោះស្រាយបញ្ហាធ្ងន់ធ្ងរដូចជាបញ្ហាវិវាទដីធ្លីរវាងពលរដ្ឋនិងអ្នកមានលុយមានអំណាចនៅឡើយទេ។

លោកបានបន្តថា៖ «យើងចង់យើញឱ្យមានការដោះស្រាយទៅលើករណីវិវាទស៊ីវិលរឿងបញ្ហាដីធ្លីជាដើមដែលបញ្ហានេះ មានការប៉ះពាល់ដល់ប្រជាពលរដ្ឋដោយមានការរំលោភពីសំណាក់ក្រុមហ៊ុន អ្នកមានអំណាចជាដើម ដើម្បីឱ្យការដោះស្រាយនេះកាន់តែមានទម្ងន់ថែមទៀត ចៀសវាងការគ្រាន់តែដោះស្រាយបញ្ហាស្រាលៗតូចៗ មិនទាន់ទូលំទូលាយនៅឡើយ»៕ ■

គ.ជ.ប.ចែកលិខិតអញ្ជើញពលរដ្ឋឱ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត

នៅ ស៊ីវុត្ថា

ភ្នំពេញ: គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានចែកលិខិតអញ្ជើញប្រជាពលរដ្ឋឱ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោតចាប់ពីថ្ងៃទី១២ ខែតុលាឆ្នាំ២០២១ ទៅ ដោយសម្រេចបានចំនួន ៧ ៩១៦-៧៤៥នាក់ ស្មើនឹង៨៩,៦៤% នៃប្រជាពលរដ្ឋដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ខណៈការចុះឈ្មោះអ្នកបោះឆ្នោតថ្មី ក៏ចាប់ផ្តើមជាមួយគ្នានេះដែរ។

លោកមាន សខិ សមាជិក គ.ជ.ប ថ្លែងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធកាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ ថា ការចែកលិខិតអញ្ជើញប្រជាពលរដ្ឋ ត្រូវបានបញ្ចប់នៅថ្ងៃទី១១ ខែតុលា ប៉ុន្តែ ប្រជាពលរដ្ឋដែលមិនទាន់បានទទួលលិខិតអញ្ជើញ អាចទៅស្នើសុំនៅសាលា ឃុំ សង្កាត់ដែលប្រជាពលរដ្ឋមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់នោះ។

លោក សោម សូរីដា អគ្គលេខាធិការរង គជប ពន្យល់ថា មូលហេតុដែល គ.ជ.ប ចែកលិខិតអញ្ជើញមិនគ្រប់ចំនួនប្រជាពលរដ្ឋនៅពេលនេះ ដោយសារ តែមានបញ្ហាមួយចំនួនដូចជាអាកាសធាតុដែលមានភ្លៀងធ្លាក់ច្រើន ប្រជាពលរដ្ឋដែលធ្វើចំណាកស្រុក ទទួលមរណភាព ប្រជាពលរដ្ឋចំណូលថ្មីដែលធ្វើឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មិនស្គាល់អត្តសញ្ញាណ។

ករណីមួយទៀត គឺដោយសារតែបញ្ហាជំងឺកូវីដ១៩ ដែលតម្រូវឱ្យមានការបិទខ្ទប់ភូមិ និងឃុំមួយចំនួន និងប្រជាពលរដ្ឋមួយចំនួនទៀតជាប់ធ្វើចត្តាឡីស័ក។ ទោះជាយ៉ាងណាលិខិតអញ្ជើញដែលមិនត្រូវបានចែកដល់ដៃប្រជាពលរដ្ឋនេះ ត្រូវបានរក្សាទុកនៅឃុំ សង្កាត់ ដើម្បីចែកជូនដល់ប្រជាពលរដ្ឋបន្តទៀត។

លោក សូរីដា ថ្លែងថា៖ «មធ្យោបាយដែលឱ្យប្រជាពលរដ្ឋដឹងថា មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត មានការផ្សាយពីបញ្ជីបោះឆ្នោត នៅតាមគេហទំព័ររបស់គ.ជ.ប មាននៅក្នុងApp និងការចែកលិខិតអញ្ជើញ ហើយខ្លឹមសារនៃលិខិតអញ្ជើញនេះ...តទៅទំព័រ ៥

ក្រសួងកសិកម្មកំពុងអនុវត្តគម្រោងរ៉េតបូកនៅខេត្តកំពង់ធំដើម្បីយកកាបូនលក់

អោម ប៊ុនធឿន

កំពង់ធំ:ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បាននិងកំពុងអនុវត្តគម្រោងរ៉េតបូក (REDD+)ដើម្បីថែរក្សាការពារព្រៃឈើសម្រាប់លក់កាបូនព្រៃឈើ បន្ទាប់ពីដីនេះត្រូវបានចុះបញ្ជីជាដីសហគមន៍ព្រៃឈើអូរបុស្សលាវ ដែលមានទំហំ ១ ៣៥៩ហិកតា នៅក្នុងខេត្តកំពង់ធំ កាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០២១។

សមត្ថកិច្ចចុះទៅចំណុចអូរបុស្សលាវនៅឆ្នាំនេះ។ រូបថត ហ្វេសប៊ុក

លោក សួន សុវណ្ណ អនុប្រធានរដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម បានថ្លែងនៅថ្ងៃទី១១ ខែតុលា ថា គម្រោងរ៉េតបូកគឺជាការរក្សាព្រៃឈើទុកដើម្បីយកកាបូនព្រៃឈើនោះលក់។ ក្រសួងទើបបានចុះបញ្ជីដីសហគមន៍ព្រៃឈើអូរបុស្សលាវ ដែលស្ថិតនៅឃុំទំរឹង ស្រុកសណ្តាន់ ខេត្តកំពង់ធំ មានផ្ទៃដីទំហំ ១ ៣៥៩ហិកតាដើម្បីរក្សាព្រៃនៅទីនោះសម្រាប់យកកាបូន។

លោកបានបន្តថា ផលនៃការលក់កាបូនព្រៃឈើនឹងត្រូវបែងចែកជូនទៅដល់សហគមន៍ព្រៃឈើ ចំណែកដីព្រៃដែលបានចុះបញ្ជីជាដីរដ្ឋនោះមិនអនុញ្ញាតឱ្យមានការកាប់រានទន្ទ្រានឡើយ ប៉ុន្តែប្រជាពលរដ្ឋនៅតែអាចអាស្រ័យផលបានធម្មតាពីព្រៃឈើនោះ។

លោកបញ្ជាក់ថា៖ «ពលរដ្ឋគាត់នៅតែអាចរកជ័រទឹក វល្លិផ្តៅ អីចឹងទៅប្រសិនបើវាមាននៅក្នុងព្រៃហ្នឹងគាត់នៅតែអាចប្រកបរបរហ្នឹងបានដដែល។ ប៉ុន្តែគ្រាន់តែគាត់ត្រូវជួយចូលរួមល្បាតថែរក្សាការពារព្រៃឈើដើម្បីឱ្យនៅគង់វង្ស ហើយយើងអាចទទួលបានកាបូន ដើម្បីយកទៅលក់»។

បើតាមលោក សួន សុវណ្ណ ការចុះបញ្ជីដីសហគមន៍ព្រៃឈើអូរបុស្សលាវនេះគឺបានទទួលប្រកាសពីក្រសួងកសិកម្ម ចុះថ្ងៃទី២០ សីហា ២០១០។ មានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍រវាងខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំ និងគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ នៅថ្ងៃទី២៥ សីហា ២០១១ និងបានទទួលអនុផែនការគ្រប់គ្រងព្រៃសហគមន៍ នៅថ្ងៃទី៤ សីហា ២០១៧។

ភ្នំពេញប៉ុស្ដិ៍មិនអាចស្វែងរកប្រភពទំនាក់ទំនងទៅសហគមន៍ព្រៃឈើអូរបុស្សលាវបានទេនៅថ្ងៃទី១១ ខែតុលា។

ប៉ុន្តែយ៉ាងណា លោកសួន សុវណ្ណ បញ្ជាក់ថា ពលរដ្ឋមានការសប្បាយរីករាយ នៅពេលដឹងថា សហគមន៍នោះត្រូវបានចុះបញ្ជីជាដីរដ្ឋដោយជោគជ័យ។ លោកបញ្ជាក់ទៀតថា ការចុះបញ្ជីដីសហគមន៍ព្រៃឈើអាចធ្វើទៅបានលុះត្រាតែដីនោះមិនមានជម្លោះ។

លោក ស៊ឹង សែនករុណា អ្នកនាំពាក្យសមាគមអាដហុក ថ្លែងនៅថ្ងៃទី១១ ខែតុលា ថា លោកមានការពេញចិត្តចំពោះការចុះបញ្ជីដីសហគមន៍ព្រៃឈើ ព្រោះនេះជាអ្វីដែលគ្រប់គ្នាចង់យើញឆន្ទៈរបស់ស្ថាប័នពាក់ព័ន្ធក្នុងការការពារព្រៃឈើ។ លោកបន្តថា កន្លងមកមានតំបន់ខ្លះ បើទោះបីជាមានការពារដោយអនុក្រឹត្យក៏ដោយ ក៏នៅតែមានការរំលោភបំពានដដែល។

លោកបញ្ជាក់ថា៖«ការចុះបញ្ជីដីព្រៃសហគមន៍ហ្នឹងគឺជាមូលដ្ឋានសម្រាប់សហគមន៍ព្រៃឈើដែលរស់នៅតំបន់ហ្នឹង គាត់អាចមានសិទ្ធិក្នុងការចូលរួមដើម្បីធ្វើការការពារដោយយោងទៅតាមការចុះបញ្ជីកាហ្នឹង»៕ ■

ពលរដ្ឋ៣០គ្រួសារនៅក្នុងភូមិ១៦និង១៧នៅតែមិនយកសំណងឱ្យចេញពីលំនៅ

ឡុង គីមម៉ារីតា

ភ្នំពេញ: ពលរដ្ឋរងផលប៉ះពាល់គម្រោងអភិវឌ្ឍន៍ផ្លូវដែកនៅភូមិ១៦ និង១៧ ស្ថិតក្នុងខណ្ឌទួលគោក នៅតែប្រកាន់ជំហរ មិនទទួលយកសំណងដែលតម្រូវឱ្យពួកគេចាកចេញពីលំនៅបច្ចុប្បន្ន ទៅទទួលយកដីនៅ 7NG ខេត្តកណ្តាល និងនៅគោក-ខ្សាច់ក្នុងខណ្ឌកំបូល។

ការប្រកាសជំហរជាថ្មីនេះ បានធ្វើឡើងបន្ទាប់ពីពលរដ្ឋ៥ នាក់ តំណាងឱ្យប្រជាពលរដ្ឋ ៣០គ្រួសារ បានជួបជាមួយអាជ្ញាធរខណ្ឌទួលគោក នៅថ្ងៃទី១១ តុលា ដើម្បីពិភាក្សាពីសំណើរបស់ពួកគេ ដែលចង់បានសំណងជាដីនៅក្រោយវត្តទួល-អស់លោក ឬដីក្នុងខណ្ឌទួលគោក ក្រោយអាជ្ញាធរប្រកាសថា ផ្ទះរបស់ពួកគេ នឹងត្រូវរុះរើ ដើម្បីធ្វើការបើកផ្លូវ ស្ថាបនាផ្លូវបេតុង និងអាងស្តុកទឹក ក្នុងខណ្ឌទួលគោកនាពេលខាងមុខ។

អ្នកស្រី ហ៊ុយ សាធៀន ជាពលរដ្ឋ រស់នៅក្នុងតំបន់រងផលប៉ះពាល់ជាង ៣០ ឆ្នាំ ដែលបានចូលជួបពិភាក្សា ជាមួយអាជ្ញាធរខណ្ឌទួលគោក បាន ប្រាប់ភ្នំពេញប៉ុស្តិ៍នៅថ្ងៃទី ១១ តុលា ថា ការជួបពិភាក្សានេះ មិនទទួល

តំណាងប្រជាពលរដ្ឋ៣០គ្រួសារមកជួបអាជ្ញាធរខណ្ឌទួលគោក។ រូបថត ហុង មិនា

បានដំណោះស្រាយអ្វីនោះទេ ព្រោះអាជ្ញាធរខណ្ឌ នៅតែទទូចឱ្យពលរដ្ឋទទួលយកសំណងជាដីនៅ 7NG ខេត្តកណ្តាល និងនៅគោកខ្សាច់ក្នុងខណ្ឌកំបូលដដែល។

អ្នកស្រីបន្តថា ជំនួសឱ្យការបាត់បង់ផ្ទះសំបែង គឺប្រជាពលរដ្ឋទាំងអស់គ្នាស្នើសុំការដោះដូរជាដីនៅក្រោយវត្តទួលអស់លោក ឬដីក្នុងខណ្ឌទួល-គោកតែ១គត់ ដែលពួកគេនិយាយថា វាងាយស្រួលដល់ការរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ជាពិសេស គឺសម្រាប់កូនៗបន្តការសិក្សា។

អ្នកស្រីនិយាយថា៖ «ជាមួយនឹងការអភិវឌ្ឍនេះ ពួកយើងមិនជំទាស់នោះទេ ប៉ុន្តែពួកយើង ប្រកាន់ជំហរក្នុងការស្នើសុំសំណងជាការដោះដូរពីកន្លែងដែលយើងរស់នៅនេះ នៅក្នុងខណ្ឌទួលគោកដដែល ឬនៅជិតវត្តទួលអស់លោក ដែលស្ថិតនៅកន្លែងយើងចាស់ ទើបពួកយើងព្រមចាក-ចេញ»។

លោក កូវ សារុន ជាប្រជាពលរដ្ឋរងគ្រោះម្នាក់ដែរ បានអះអាងថា បើមិនទទួលបានដីនៅក្នុងតំបន់ដែលពួកគេ ចង់បាននោះទេ គឺពួកគេ នឹងមិនចាកចេញពីលំនៅនោះទេ ព្រោះថាការចាកចេញទៅរស់នៅកន្លែងដែលអាជ្ញាធរ ផ្តល់ឱ្យ នឹងធ្វើឱ្យជីវភាពរបស់ពួកគេ កាន់តែយ៉ាប់យឺន ខណៈតំបន់ថ្មី មិនមានហេដ្ឋារចនា-សម្ព័ន្ធ សាលារៀន ហើយក៏ធ្វើឱ្យបាត់បង់មុខរបរទៀតផង។

លោក បានរៀបរាប់ថា៖ «ពួកខ្ញុំបញ្ជាក់យ៉ាងច្បាស់ហើយ ថា មិនទទួលយកជាដាច់ខាត ហើយនឹងស្នើសុំទៅលើបន្តទៀត។ បើសិនជាមិនមានលទ្ធផលទេ នឹងដាក់សំណើជាកញ្ចប់ទៅសម្តេចនាយក ស្នើឱ្យធ្វើការដោះស្រាយតែម្តង ព្រោះសម្រាប់សាលាក្រុង និងខណ្ឌ អត់មានលទ្ធភាព ក្នុងការដោះស្រាយឱ្យពួកយើងទេ។ ពួកខ្ញុំ តែ៣០ គ្រួសារសោះ ក៏មិនផ្តល់ដំណោះស្រាយឱ្យពួកខ្ញុំ»។

លោក ជា ពិសី អភិបាលខណ្ឌទួល-គោក កាលពីថ្ងៃទី ១១ តុលា មិនអាចសុំការអត្ថាធិប្បាយជុំវិញបញ្ហានេះបានទេ ដោយលោក មិនលើទូរស័ព្ទ។ ចំណែកលោក ហួរ ហួត នាយក-រដ្ឋបាលខណ្ឌទួលគោកកាលពីម្សិល-មិញបានបដិសេធធ្វើការអត្ថាធិប្បាយ ដោយអះអាងថា លោកជាប់រវល់។

លោក សឿន សារ៉ន នាយក-ប្រតិបត្តិនៃសមាគមធាងត្នោត នៅតែទទូចឱ្យអាជ្ញាធរ ស្វែងរកដំណោះ-ស្រាយណាមួយដែលឱ្យប្រជាពលរដ្ឋអាចទទួលយកពីគម្រោងអភិវឌ្ឍន៍នានា ខណៈដែលលោកមើលឃើញថា ជាទូទៅសំណង និងដំណោះ-ស្រាយដែលអាជ្ញាធរបានផ្តល់ឱ្យប្រជាពលរដ្ឋរងគ្រោះហាក់មិនអាចទទួលយកបាននោះទេ។

លោក រំពឹងថា៖ «នៅពេលមានការដោះស្រាយតាមយុទ្ធសាស្ត្រឈ្នះឈ្នះនោះប្រជាពលរដ្ឋ ក៏គាត់សប្បាយពេញចិត្តនឹងទទួលយក ហើយបង្កើតសុខសន្តិភាពដល់ពលរដ្ឋ។ ចំពោះអាជ្ញាធរខ្លួនឯងផ្ទាល់ក៏ទទួលបានការកោតសរសើរទៅតាមនោះដែរ ក្នុងការដោះស្រាយផលប៉ះពាល់ដល់ពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន»។

លោកសឿន សារ៉ន លើកឡើងថា ការផ្តល់ដំណោះស្រាយដែលមិនអាចទទួលយកបាន គឺជាមូលហេតុដែលបណ្តាលឱ្យមានការតវ៉ា ហើយវាក៏បង្កទៅជាអយុត្តិធម៌ក្នុងសង្គម ដែលធ្វើឱ្យប្រជាពលរដ្ឋមានការឈឺចាប់៕ ■

គ.ជ.ប.ចែក...

តពីទំព័រ៤...គឺជាខ្លឹមសារដែលផ្ទេរចេញពីទិន្នន័យផ្លូវការរបស់គ.ជ.ប។ នៅពេលពលរដ្ឋទទួលបានលិខិតអញ្ជើញនេះ មិនចាំបាច់ទៅពិនិត្យនៅតាមឃុំ-សង្កាត់ក៏បានដែរ»។

បើតាមលោក សោម សូរីដា ពលរដ្ឋដែលមិនទទួលបានលិខិតឱ្យទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោតមានជាង១០ %។

លោក ទេព នីថា អគ្គលេខា-ធិការគ.ជ.ប ឱ្យដឹងដែរថា ការត្រៀមរៀបចំការបោះឆ្នោត បានប្រព្រឹត្តទៅដោយរលូន តាមនីតិវិធី បទបញ្ជា និងផែនការ។ ទោះជាយ៉ាងណា ក៏គ.ជ.ប បានជួបបញ្ហាខ្វះខាតខ្លះ ប៉ុន្តែត្រូវបានកែសម្រួលទាន់ពេលផងដែរ។

បើតាម លោក មាន សុទិ សមាជិក គ.ជ.ប ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះ-ឆ្នោត មានរយៈពេល៥០ថ្ងៃ គឺចាប់ពីថ្ងៃទី១២ខែតុលា ឆ្នាំនេះ ដល់ថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ២០២១ រៀងរាល់ថ្ងៃរួមទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យនៅតាមសាលាឃុំ សង្កាត់ និងទីតាំងមួយចំនួនក្នុងឃុំ-សង្កាត់។

ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះ-ឆ្នោតនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវបិទការិយាល័យចុះឈ្មោះរៀងរាល់១៥ថ្ងៃម្តងដើម្បីប្រជុំជាមួយក្រុមចុះឈ្មោះ ពិភាក្សាលើការងារអនុវត្តកន្លងមក និងរៀបចំការងារបន្តទៅទៀត។

លោកថ្លែងថា៖«តាមប្រតិ-ទិនការងារការិយាល័យនេះ ត្រូវធ្វើនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ និងថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១»៕ ■

មន្ត្រី គ.ជ.ប. ប្រជុំតាមអនឡាញពីថ្ងៃ១១ តុលា។ រូបថត គ.ជ.ប

National Committee for Sub-National Democratic Development Secretariat (NCDDS)
Cambodia Nutrition Project
Wishes to Purchase:
115 Tablet Computers with Warranty one year on hardware and 3 years on services.
REF No. NCDDS-GO-RFQ 2

1. The *National Committee for Sub-National Democratic Development Secretariat (NCDDS) has received* a *P162675* from the *World Bank* toward the cost of *Cambodia Nutrition Project (CNP)*, and it intends to apply part of the proceeds of this *Grant* to payments under the Contract for Supplying and Delivery of 115 Tablet Computers with *Warranty one year on hardware and 3 years on services.*
2. The goods are required by *12 weeks from the date of contract.*
3. Interested qualified eligible suppliers are invited to obtain a copy of the bidding documents free-of-charge from the address given below by submitting a written application. Except for the submission of a written application, there shall be no other conditions for obtaining the bidding documents.
4. To be considered eligible and qualified a bidder must:
   (i) Meet the eligibility criteria *of World Bank.*
   (ii) Have completed at least two contracts for supply of similar goods in the preceding 3 years of a value not less than *50% of estimate contract price.*
   (iii) Have completed contracts with a total cumulative value equal to at least *two times estimated contract price* in the preceding 2 years.
   (iv) Not be under any notice of suspension or disbarment issued by the Government or *World Bank.*
5. Quotations must be delivered to the address given below on or before **10 AM, 25th October 2021**. Late Quotations will be rejected. Quotations will be opened in public immediately thereafter at the address given below in the presence of the Bidders' representatives who choose to attend.
6. The Purchaser shall award the Contract to the Bidder whose offer has been determined to be the lowest evaluated quotation and is substantially responsive to the Bidding Documents, provided further that the Bidder is determined to be qualified to perform the Contract satisfactorily.
7. All quotations must be accompanied by performance securing declaration as described in the bidding documents. Any quotation not accompanied by one will be rejected as non-compliant
8. The address where the Bidding Document may be inspected and obtained is:
   Procurement Office 1st floor of National Committee for Sub-National Democratic Development Secretariat (NCDDS), Building T located in the Ministry of Interior's Compound. You may contact Mr. Bith Chankhan, Chief of Procurement office on *(855) 17 258 889 or E-mail to: chankhan@ncdd.gov.kh* to obtain the Bidding Documents at no cost.
9. In case of any difficulty in obtaining the Bidding Documents, interested parties may contact in writing *Mr. Chey Sambatphalla, Project Manager of Cambodia Nutrition Project (CNP) of National Committee for Sub-National Democratic Development Secretariat (NCDDS), Building T in Ministry of Interior's Compound, Tel: 023 720 038/ 720 061, E-mail:* sambatphalla@ncdd.gov.kh and also send a copy of the communication to:
   (a) Director General
   General Department of International Cooperation and Debt Management, Ministry of Economy and Finance, Street 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia Fax No. (855-23) 725 341; and
   (b) Ziauddin Hyder, Task Team Leader of World Bank (Cambodia Office) at address: *Exchange Square Building No. 19-20, Street 106,* Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia, Telephone No. (855) 23 261 365, E-mail: zhyder@worldbank.org.
10. The quotation must be submitted on or before **10 AM, 25th October 2021** at the following address:
    Procurement Office 1st floor of National Committee for Sub-National Democratic Development Secretariat (NCDDS), Building T located in the Ministry of Interior's Compound. Due to Covid-19 pandemic, bidders are allowed to submit quotations in pdf file with protected password by email to chankhan@ncdd.gov.kh. The bidders will provide password during online bid opening.
11. The Government and/or the Development Partner will declare a firm ineligible either indefinitely or for a stated period of time, to be awarded a contract financed by the Government and/or the Development Partner respectively, if it at any time determines that the firm has engaged in fraud and corruption during the procurement and execution of this contract as described in ITB Clause 4.
12. A complaint may be made by any party at any stage of the procurement process. The procedure is described in Instructions to Bidders, Clause 21 of the Bidding Documents.

កម្ពុជាចាប់ផ្តើមយុទ្ធនា...

តពីទំព័រ១...គេដើម្បីការពារអាយុជីវិតប្រជាជន។

លោកបន្ថែមថា ការចាក់វ៉ាក់សាំងទាន់ពេលវេលានឹងអាចជួយសង្គ្រោះជីវិតប្រជាជនកម្ពុជាបានច្រើនតាមរយៈ ការកាត់បន្ថយការឆ្លង ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ ការស្លាប់ដោយសារជំងឺកូវីដ១៩ និងការបញ្ឈៀសប្រទេសកម្ពុជាពីមហន្តរាយនៃជំងឺកូវីដ១៩ដែលអាចធ្វើឱ្យគ្រប់គ្រងការឆ្លងរាលដាលជំងឺនេះបាន។

លោក ទៀ បាញ់ មានប្រសាសន៍ថា៖ «រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចាក់វ៉ាក់សាំងកូវីដ១៩ឱ្យបានឆាប់ និងសម្រេចបានតាមផែនការដើម្បីបង្កើតនូវភាពស៊ាំក្នុងសហគមន៍ និងការឈានទៅបើកដំណើរការឡើងវិញវិស័យទេសចរណ៍ផ្ទៃក្នុង និងវិស័យសេដ្ឋកិច្ចសង្គមផងដែរ»។

លោកបញ្ជាក់ថា៖«ជាការពិត រហូតមកដល់ពេលនេះ ពុំមានប្រទេសណាមួយអាចមានវ៉ាក់សាំងជូនប្រជាពលរដ្ឋដោយស្ម័គ្រចិត្តក្នុងពេលតែមួយដំណាលគ្នាដូចប្រទេសកម្ពុជាបានទេ ដោយសារសមត្ថភាពផលិត សមត្ថភាពចែកចាយ និងការចាក់វ៉ាក់សាំងមានកម្រិតទៅតាមប្រទេសនីមួយៗ»។

លោកទៀ បាញ់ បានស្នើឱ្យក្រុមការងារចាក់វ៉ាក់សាំងទាំងអស់ត្រូវយកចិត្តទុកដាក់នូវភារកិច្ចរបស់ខ្លួនដោយផ្អែកតាមបទពិសោធចាក់វ៉ាក់សាំងកូវីដ១៩ ជុំទី១នាពេលកន្លងមក។

បើតាម លោកទៀ បាញ់ ក្រុមការងារចាក់វ៉ាក់សាំងរបស់កងទ័ពនឹងទទួលភារកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ ជុំសប្តាហ៍នេះទៅដល់ប្រជាពលរដ្ឋ និងកម្មការនិយោជិតតាមបណ្តារោងចក្រនានាក្នុងខណ្ឌចំនួន៦ក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន៨ផ្សេងទៀត។

លោកថា៖ «កម្ពុជាទទួលបានជោគជ័យក្នុងការចាក់វ៉ាក់សាំងកូវីដ១៩ ដោយសារការបិទយុទ្ធនាការជុំទី១ក៏ត្រូវបានធ្វើឡើងស្ទើរគ្រប់ខេត្តផងដែរ។ យើងអាចនិយាយថា វាជាភាពអស្ចារ្យសម្រាប់ជាតិមាតុភូមិរបស់យើង ដែលយើងពិតជាមានមោទនភាពណាស់សម្រាប់ប្រទេសយើងដែលវាជាខ្សែក្រវាត់ជួរមុខបំផុតសម្រាប់ជាតិយើងផងដែរ»។

លោកស្រី ឱ វណ្ណឌីន អ្នកនាំពាក្យក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ក្នុងក្របខ័ណ្ឌទូទាំងប្រទេស បានលើកឡើងក្នុងថ្ងៃបើកយុទ្ធនាការចាក់វ៉ាក់សាំងដូសជំរុញនេះផងដែរថា ជាការគិតគូរពីសុខភាពរបស់ប្រជាពលរដ្ឋ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានសម្រេចឱ្យមានគោលនយោបាយការចាក់វ៉ាក់សាំងកូវីដ១៩ដូសជំរុញនេះ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១។

ដំណើរការចាក់វ៉ាក់សាំងដូសទី៣ នៅភ្នំពេញពីថ្ងៃ១១ តុលា។ រូបថត ហេង ជីវិន

លោកស្រីថ្លែងថា៖ «យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ ដូសជំរុញនេះ ចាប់ផ្តើមឡើងពីថ្ងៃទី១១ ខែតុលានេះ ក្រោមអភិក្រមផ្តាំរឹករបស់សម្តេចតេជោនាយករដ្ឋមន្ត្រី»។

ដើម្បីសម្រួលដល់ការងារចាក់វ៉ាក់សាំងកូវីដ១៩ដូសជំរុញនេះ ក្រសួងសុខាភិបាលក៏បានផ្តល់នូវសម្ភារបរិក្ខារពេទ្យមួយចំនួនទៅដល់ក្រុមគ្រូពេទ្យក្រសួងការពារជាតិដូចជា សម្លៀកបំពាក់ PPE អាវអៀមខាងមុខ ម៉ាស់ របាំងមុខ ស្រោមដៃ អាល់កុល សំឡី និងស្ទេរ៉ូមប្រៃ ជាដើម។

នាឱកាសនោះដែរ លោក ឥត សារ៉ាត់ អគ្គមេបញ្ជាការរង នាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ និងជាប្រធានប្រតិបត្តិនៃការចាក់វ៉ាក់សាំងកូវីដ១៩ក្រសួងការពារជាតិបានប្រកាសថា ក្រុមការងារចាក់វ៉ាក់សាំងរបស់ក្រសួងការពារជាតិបានទទួលភារកិច្ចចាក់វ៉ាក់សាំងកូវីដ១៩ក្នុងខណ្ឌចំនួន៦ក្នុងរាជធានីភ្នំពេញ ដែលមានខណ្ឌកំបូល ដង្កោ មានជ័យ ពោធិ៍សែនជ័យ ទួលគោក និងខណ្ឌឫស្សីកែវ។

លោកបន្ថែមថា ប្រជាពលរដ្ឋក្នុងខណ្ឌទាំង៦ ដែលក្រុមការងារកងទ័ពវ៉ាប់រងក្នុងការចាក់នេះមានចំនួនសរុប ១ ០២៦ ១២៦នាក់។ ចំណែកកម្លាំងកងទ័ពដែលនឹងត្រូវចូលរួមប្រតិបត្តិការនេះ មានចំនួន ៣ ៥៧៨នាក់ ដោយចែកជា១៥២ក្រុមពេទ្យផងដែរ។

នៅថ្ងៃទី១១តុលានេះដែរ សម្រាប់ក្រុមគ្រូពេទ្យនៃមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នឹងចាប់ផ្តើមចាក់នៅមូលដ្ឋានខណ្ឌបឹងកេងកង ខណ្ឌចំការមន ខណ្ឌច្បារអំពៅ ខណ្ឌ៧មករា និងខណ្ឌសែនសុខ។ ចំណែក ខណ្ឌដូនពេញ ខណ្ឌជ្រោយចង្វារ និងខណ្ឌព្រែកព្នៅ នឹងចាប់ដំណើរការចាក់វ៉ាក់សាំងពីថ្ងៃទី ៣០ ខែតុលាខាងមុខនេះ។

បើតាមរបាយការណ៍របស់ក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០២១ ប្រជាពលរដ្ឋដែលមានអាយុចាប់ពី៦ឆ្នាំឡើងសរុបជាង១៣លាននាក់ឬស្មើនឹង៨៤,៣៣ភាគរយ ធៀបនឹងគោលដៅចំនួន១៦លាននាក់ បានទទួលនូវការចាក់វ៉ាក់សាំង។ ក្នុងនោះមានប្រជាពលរដ្ឋអាយុពី១៨ឆ្នាំឡើងចំនួន៩៩,២០ភាគរយធៀបនឹងចំនួនប្រជាជនគោលដៅ១០លាននាក់ ក្រុមអាយុពី១២ឆ្នាំ ទៅក្រោម១៨ឆ្នាំ មានចំនួន៨៩,៨១ភាគរយ ធៀបនឹងចំនួនប្រជាជនគោលដៅជិត២លាននាក់ និងលើកុមារអាយុពី៦ឆ្នាំ ដល់ក្រោម១២ឆ្នាំមានចំនួន៩៥,១៨ភាគរយធៀបជាមួយនឹងប្រជាជនគោលដៅជាង១,៨លាននាក់៕ ■

ភ្នំពេញ ប៉ុស្ដិ៍ The Phnom Penh Post

Job Announcement

The Phnom Penh Post, the oldest independent media company in Cambodia, is seeking full-time candidate for the following position:

SUB-EDITORS: 02 POSITIONS

Main duties and responsibilities
- Report to Deputy Managing Editor PE/Managing Editor
- Lay out wire/National pages and manage layouts using InDesign/InCopy
- Communicate closely with reporters

Qualifications/experience required
- Bachelor's degree in journalism or other related fields (preferred but not a must)
- Excellent command of English is a must; proficiency in Khmer an asset
- News/business reporting experience
- At least one to two years' experience as sub-editor
- Familiar with names of state institutions
- Familiar with specific language used in court, business and politics
- Sound understanding of local politics and business atmosphere
- Cambodians preferred but foreign nationals are encouraged to apply

Interested candidates are required to submit a photo attached CV and cover letter with expected salary to the Human Resource and Administration Department at the following address no later than October 30, 2021.
Address: The Elements Condominium(Residence 9) Level 7, Hun Sen Boulevard, Chak Angre Krom commune, Meanchey district, Phnom Penh.
Tel: +855 (0) 23 888 161 -162
Email: jobs@phnompenhpost.com
www.phnompenhpost.com (http://www.phnompenhpost.com/) www.postkhmer.com (http://www.postkhmer.com/)

Post Media Co., Ltd is an equal opportunity employer. Only short-listed candidates will be contacted for interview. Application documents will not be returned.

Intelligent - In-depth - Independent

មន្ត្រីជំនាញជាតិ និងអន្តរជាតិចុះត្រួតពិនិត្យការងារនៅការដ្ឋានជួសជុលប្រាសាទតំបន់រមណីយដ្ឋានអង្គរ

នៅ ស៊ីវុត្ថា

ភ្នំពេញ: មន្ត្រីនៃលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ និងអង្គការយូណេស្កូប្រចាំកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានចុះពិនិត្យការងារនៅការដ្ឋានជួសជុលប្រាសាទមួយចំនួននៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងបានពិភាក្សាផ្លាស់ប្តូរយោបល់លើការងារបច្ចេកទេសជួសជុលប្រាសាទ ដើម្បីធ្វើយ៉ាងណាឱ្យជាប់គង់វង្សបានយូរអង្វែង។

លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា ប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១ នេះ ឱ្យដឹងថា មន្ត្រីនៃលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ និងអង្គការយូណេស្កូប្រចាំកម្ពុជាជារៀងរាល់ឆ្នាំតែងតែបានចុះមកពិនិត្យ គឺបានផ្លាស់ប្តូរយោបល់ និងផ្តល់ជាគំនិតក្នុងការជួសជុលប្រាសាទឱ្យមានភាពល្អប្រសើរ និងទៅតាមលក្ខណៈបច្ចេកទេស។

លោកបន្តថា ចំពោះការងារចុះត្រួតពិនិត្យនៃមន្ត្រីនៃលេខាធិការដ្ឋានអាយស៊ីស៊ី-អង្គរ និងអង្គការយូណេស្កូប្រចាំកម្ពុជា បានឱ្យយោបល់ទៅលើកិច្ចការងារដែលអាជ្ញាធរជាតិអប្សរា បាននិងកំពុងធ្វើពាក់ព័ន្ធនឹងបច្ចេកទេស ព្រោះរាល់ការជួសជុលត្រូវធ្វើការពិភាក្សាគ្នាដើម្បីស្វែងរកវិធីសាស្ត្របែបណា ឱ្យការជួសជុលត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងរឹងមាំគង់វង្សបានយូរអង្វែង។

លោកថ្លែងថា៖ «គេអត់មានផ្តល់ជំនួយអីទេ បើសិនជាគេជួយ គេមានកិច្ចប្រតិបត្តិការអន្តរជាតិ ប៉ុន្តែនៅក្នុងពេលនេះប្រទេសដៃគូជាមិត្ត មិនអាចធ្វើដំណើរហោះហើរចេញចូល ពីប្រទេស១ ទៅប្រទេស ១ទៀត មានផលលំបាកដោយសារតែបញ្ហាជំងឺកូវីដ១៩។ ហើយក្រុមការងារនេះតែងតែចុះមកពិនិត្យបែបនេះជារៀងរាល់ ២ដងក្នុង ១ឆ្នាំ»។

លោក ឡុង កុសល វាយតម្លៃខ្ពស់ចំពោះដំណើរទស្សនកិច្ចត្រួតពិនិត្យ និងពិភាក្សាស្វែងយល់អំពីដំណើរការជួសជុលបន្ទាន់ នូវរចនាសម្ព័ន្ធដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ ដើម្បីជានាបាននូវស្ថិរភាព និងភាពរឹងមាំរបស់ប្រាសាទ និងល្អប្រសើរខ្លាំងណាស់ ព្រោះកិច្ចការងារនេះ ត្រូវបានធ្វើរួមគ្នា និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក។ ការត្រួតពិនិត្យដំណើរការជួសជុលប្រាសាទមួយចំនួនរួមមាននៅ ប្រាសាទបន្ទាយស្រី ប្រាសាទនាគព័ន្ធ ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន ខ្លោងទ្វារតាកាវ ព្រះទីលានជល់ដំរី និងប្រាសាទមេបុណ្យខាងលិច។ ក្រុមការងារក៏បានបន្តមើលការរៀបចំសោភណភាពតំបន់ជុំវិញរចនាសម្ព័ន្ធប្រាសាទ ឱ្យមានលក្ខណៈល្អប្រសើរឡើងវិញ ដោយគោរព និងរក្សាឱ្យបាននូវតម្លៃនៃសភាពដើម និងបូរណភាពរបស់អង្គរ។ ក្រុមអ្នកជំនាញនេះ តែងតែចុះពិនិត្យមើលការងារប្រឈម នឹងគ្រោះថ្នាក់នៅតាមការដ្ឋានមួយចំនួនក្នុងរមណីយដ្ឋានអង្គរមុនបើកកិច្ចប្រជុំរបស់ខ្លួន ដើម្បីធ្វើរបាយការណ៍រួម សម្រាប់ដាក់ជូនទៅគណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ដើម្បីត្រួតពិនិត្យ និងផ្តល់អនុសាសន៍ក្នុងការអនុវត្តបន្ត៕ ■

បណ្ណាល័យធំជាងគេនៅខេត្តឆ្ងាយៗកម្ពុជានឹងបើកសម្ពោធនៅខែក្រោយ

នៅ ស៊ីវុត្ថា

មន្ត្រីនៃមន្ទីរអប់រំខេត្តបាត់ដំបងពេលចុះពិនិត្យទីតាំងបណ្ណាល័យកាលពីថ្ងៃ៩ តុលា។ រូបថត មន្ទីរអប់រំខេត្ត

បាត់ដំបង: បើមិនមានអ្វីប្រែប្រួលទេបណ្ណាល័យជាតិដ៏ធំបំផុតដែលស្ថិតក្នុងបរិវេណសាកលវិទ្យាល័យជាតិបាត់ដំបង ក្នុងខេត្តបាត់ដំបង នឹងត្រូវសម្ពោធដាក់ឱ្យប្រើប្រាស់នៅអំឡុងខែវិច្ឆិកា ឆ្នាំ២០២១ ខាងមុខនេះ ដើម្បីអនុញ្ញាតឱ្យសិស្សនិស្សិតចូលសិក្សាស្រាវជ្រាវទៅលើមុខវិជ្ជាដែលកំពុងរៀន និងជំនាញបច្ចេកទេសដូចជាវិស័យកសិកម្ម និងបច្ចេកវិទ្យាជាដើម។

លោក សុខ ឃន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិបាត់ដំបងប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី១០ ខែតុលាថា បណ្ណាល័យជាតិនេះ រហូតមកទល់ពេលនេះ ត្រូវបានរៀបចំរួចរាល់១០០ភាគរយ ដែលអាចនឹងចាប់ផ្តើមសម្ពោធដាក់ឱ្យប្រើនៅខែវិច្ឆិកា ឆ្នាំនេះទៅតាមផែនការដែលបានកំណត់។

លោកបានបន្តថា បណ្ណាល័យដ៏ធំមួយនេះ អាចផ្ទុកសៀវភៅគ្រប់ប្រភេទឱ្យសិស្សនិស្សិតចូលសិក្សាស្រាវជ្រាវចំនួនជាង៣ម៉ឺនក្បាលដែលសៀវភៅទាំងនេះបានមកពីការឧបត្ថម្ភរបស់ក្រសួងស្ថាប័នជាតិនានា និងសៀវភៅខ្លះទៀតត្រូវបានបញ្ជាទិញតាមរយៈគម្រោងកែលម្អឧត្តមសិក្សា។ ក្រៅពីនេះ បណ្ណាល័យនេះ ក៏អាចផ្ទុកអ្នកចូលអានបានចំនួន៥០នាក់ក្នុង ១លើក។ផងដែរ។

បណ្ណាល័យនេះត្រូវបានសាងសង់កម្ពស់២ជាន់ និងទំហំ៣០មxx៣០ម ស្ថិតក្នុងបរិវេណសាកលវិទ្យាល័យជាតិបាត់ដំបង និងជាងគេបំផុតនៅភូមិភាគពាយព្យនៃប្រទេសកម្ពុជា។ ក្រៅពីនិស្សិតដែលសិក្សានៅសាកលវិទ្យាល័យនេះ ប្រជាពលរដ្ឋជម្មតា និងសិស្សនិស្សិតនៅខាងក្រៅក៏អាចចូលទៅសិក្សា និងស្រាវជ្រាវនៅក្នុងបណ្ណាល័យនេះបានដែរ ប៉ុន្តែត្រូវមានលក្ខខណ្ឌមួយចំនួនដូចជាតម្រូវឱ្យមានកាតសមាជិកដើម្បីងាយស្រួលគ្រប់គ្រង ព្រោះសៀវភៅនីមួយៗមានតម្លៃ១២០ដុល្លារឬ២៣០ដុល្លារអាមេរិកក្នុង១ក្បាល។

បើតាម លោក សុខ ឃន បណ្ណាល័យនេះ ក៏នឹងបំពាក់នូវ E-Library បន្ថែមទៀត ដែលនឹងអនុញ្ញាតឱ្យសិស្សនិស្សិតទាំងអស់អាចចូលទៅមើលក្នុងកុំព្យូទ័រតាមរយៈការបំពាក់ប្រព័ន្ធអ៊ីនធឺណិត អាចអាននិងទាញយកសៀវភៅរាប់សែនក្បាលដែលត្រូវបានគេបង្ហោះនៅក្នុងE-Library របស់ប្រទេសនានាដែលជាដៃគូ និងស្ថាប័នដែលអនុញ្ញាតឱ្យចូលទៅមើលឬទាញយកមកទុកអានបានគ្រប់ពេល។

លោកបានបញ្ជាក់ថា៖ «អ្វីដែលយើងរៀបចំបណ្ណាល័យនេះ យើងដាក់បេសកកម្មរបស់យើងធំៗចំនួន២ ទី១ គឺវានឹងក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងទី២ គឺជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ។ វាមិនមែនត្រឹមតែសិក្សាស្រាវជ្រាវធ្វើនិក្ខេបបទ និងបង្កើនចំណេះដឹងប៉ុណ្ណោះទេ ប៉ុន្តែវានឹងក្លាយជាមជ្ឈមណ្ឌលស្រាវជ្រាវលើវិស័យកសិកម្ម និងបច្ចេកវិទ្យាជាដើម»។

លោកបន្តទៀតថា ទៅថ្ងៃអនាគត បណ្ណាល័យនេះ ក៏នឹងបង្កើតឱ្យទៅជាថ្នាលបណ្តុះអាជីវកម្ម ដែលអនុញ្ញាតឱ្យសិស្សនិស្សិត និងប្រជាពលរដ្ឋគ្រប់រូបចូលទៅសិក្សាស្រាវជ្រាវផងដែរ។ ក្រៅពីនេះ ក៏នឹងរៀបចំឱ្យមានឡាប៊ូ (Lab) សម្រាប់ធ្វើតេស្តគ្រឿងសំណង់ និងចំណីអាហារជាតិដែលយកមកពីខេត្តជាប់ព្រំដែនដូចជាខេត្តបន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង ឧត្តរមានជ័យ និងសៀមរាប ព្រោះនៅពេលខាងមុខហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានភាពងាយស្រួល។

កញ្ញា លន់ ស្រីមុី និស្សិតឆ្នាំទី១ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យជាតិបាត់ដំបង បានរំពឹងថា នៅពេលបើកសម្ពោធដាក់ឱ្យដំណើរការនូវបណ្ណាល័យនេះនឹងអនុញ្ញាតឱ្យសិស្សនិស្សិត ចូលអានសៀវភៅប្រមាណជាង៣ម៉ឺនក្បាល ដើម្បីបង្កើនចំណេះដឹង និងសិក្សាស្រាវជ្រាវបន្ថែមលើមុខវិជ្ជាដែលខ្លួនកំពុងសិក្សានៅក្នុងសាកលវិទ្យាល័យ។

កញ្ញាបន្តថា បណ្ណាល័យនេះមានទំហំធំ និងមានកម្ពស់២ជាន់ និងធំជាងគេបំផុតនៅខេត្តបាត់ដំបងដែលមិនធ្លាប់មានពីមុនមកនោះទេ។ មិនមែនមានតែសៀវភៅប៉ុណ្ណោះទេប៉ុន្តែបណ្ណាល័យនេះ បំពាក់ទៅដោយ E-Libraryផ្តល់ឱកាសសិស្សនិស្សិតដែលកំពុងសិក្សានៅក្នុងសាកលវិទ្យាល័យ និងសិស្សនិស្សិតមកពីខាងក្រៅបានចូលទៅសិក្សាស្រាវជ្រាវបានយ៉ាងទូលំទូលាយ និងងាយស្រួលផងដែរ។

កញ្ញាថ្លែងថា៖«កាលពីមុនអត់មានបណ្ណាល័យធំជាងគេអីចឹងទេ ទើបតែមាននៅឆ្នាំនេះ វានឹងរួមចំណែកបណ្តុះការអាននិងសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិតឱ្យកាន់តែមានចំណេះដឹងទូលំទូលាយ ព្រោះនៅក្នុងបណ្ណាល័យនេះមានទាំងE-Library ថែមទៀត»។

លោក យី សុងគី ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២១បានចុះពិនិត្យទិដ្ឋភាពទូទៅនៃបណ្ណាល័យជាតិសាកលវិទ្យាល័យជាតិបាត់ដំបង និងអាងហែលទឹកខ្នាតអន្តរជាតិដែលត្រៀមសម្ពោធដាក់ឱ្យប្រើប្រាស់នាពេលឆាប់ៗខាងមុខនេះ៕ ■

អាជ្ញាធរដែនដីរៀបចំស្តារត្រពាំងក្នុងសង្កាត់ក្រឡាញ់ដើម្បីអភិរក្ស និងទាក់ទាញភ្ញៀវ

អោម ប៊ុនធឿន

លោកចៅសង្កាត់ជ្រាវ ក្នុងកិច្ចប្រជុំកាលពីកន្លងមក។ រូបថត រដ្ឋបាលសង្កាត់ជ្រាវ

សៀមរាប: អាជ្ញាធរសង្កាត់ជ្រាវ ក្រុងសៀមរាបកំពុងរៀបចំស្តារត្រពាំងបុរាណឈ្មោះថា«ត្រពាំងហែផ្កា»ស្ថិតក្នុងភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើម្បីអភិរក្សទាក់ទាញភ្ញៀវទេសចរ និងបង្កើតមុខរបរ ឬអាជីវកម្មលក់ដូរជូនពលរដ្ឋនៅក្បែរត្រពាំងបុរាណនោះ។

លោក ក្អោប រ៉ន ចៅសង្កាត់ជ្រាវ បានឱ្យដឹងកាលពីថ្ងៃទី១០ ខែតុលាថា ត្រពាំងបុរាណនេះ មានទំហំប្រមាណ៦ហិកតា នឹងត្រូវជីកស្តារជម្រៅ៣ម៉ែត្រ។ ការជីកស្តារត្រពាំងបុរាណនេះ គឺជីកដីក្នុងត្រពាំងយកមកចាក់នៅជុំវិញត្រពាំងដែលមានទំហំជុំវិញស្មើនឹង១៣ន់ម៉ែត្រ និងទទឹង៥០ម៉ែត្រ កម្ពស់ ២ម៉ែត្រ។ យ៉ាងណាការជីកស្តារនេះ នៅមិនអាចកំណត់ថា ត្រូវចំណាយថវិកាចំនួនប៉ុន្មាននោះទេ។

លោកបានថ្លែងថា៖ «ការចាក់ដីនេះយើងធ្វើរបៀបដូចភាសាមួយគេនិយាយថា យកស្លឹកត្នោតខ្ចប់ស្ករត្នោត គឺយើងឱ្យគេដឹកចាក់នៅទីតាំងដែលយើងកំណត់ហើយយើងគិតជាលុយឱ្យគេ[ថ្លៃដឹក] តែយើងគិតយកតម្លៃអាចម៍ដីយើង ដោះដូរអីចឹង»។

បើតាមលោកចៅសង្កាត់ជ្រាវបច្ចុប្បន្ន ត្រពាំងបុរាណនោះមានការរីងគោកទឹកអស់ហើយ ចំណែកការស្តារត្រពាំងបុរាណនេះគឺមានបំណងដើម្បីជាការអភិរក្សកុំឱ្យមានការរំលោភយកពីសំណាក់ប្រជាពលរដ្ឋ បង្កើតជាកន្លែងកម្សាន្តទាក់ទាញភ្ញៀវទេសចរ និងរៀបចំឱ្យមានកន្លែងលក់ដូរជួយជីវភាពប្រជាពលរដ្ឋនៅជុំវិញនោះផងដែរ។

លោកបានបញ្ជាក់ថា៖ «យើងចង់រៀបចំទីកន្លែងហ្នឹងឱ្យស្អាត មានរមណីយដ្ឋាន មានសួន មានកន្លែងឱ្យពលរដ្ឋលក់ដូរអីតិចតួចទៅណា ក្រែងលោបានកម្រៃដោះស្រាយក្នុងគ្រួសារក្នុងមូលដ្ឋាននេះ។ បើយើងទុកចោលអីចឹងទៅវាដូចជាឥតប្រយោជន៍ ហើយមានការរំលោភយកពីប្រជាពលរដ្ឋ នេះជាការស្នើសុំរបស់ខ្ញុំទៅអាជ្ញាធរជាតិអប្សរា»។

យ៉ាងណាក៏ដោយ ការស្តារត្រពាំងបុរាណមួយនេះ មានប្រជាពលរដ្ឋមួយចំនួនបានបង្ហាញការមិនពេញចិត្ត និងបាននាំគ្នាតវ៉ាមិនឱ្យអាជ្ញាធរដាក់គ្រឿងចក្រចូលដើម្បីជីកស្តារនោះទេ។ ក៏ប៉ុន្តែ លោក ក្អោប រ៉ន បានបញ្ជាក់ថា អ្នកដែលមិនពេញចិត្តក្នុងការអភិវឌ្ឍនេះគឺអ្នកដែលបានរំលោភយកដីក្នុងត្រពាំងនោះឯង។

លោកបានថ្លែងថា៖ «គេមានមេខ្លោង ដើរប្រមូលស្នាមមេដៃប្រជាពលរដ្ឋប្រមាណជិត៣០០នាក់ បានយកពាក្យសុំអន្តរាគមន៍ទៅដាក់នៅសាលាខេត្ត ប៉ុន្តែដោយសារខាងខេត្តកំពុងជាប់រវល់រឿងបញ្ហាកូវីដក៏មិនទាន់បានដោះស្រាយនូវពាក្យបណ្តឹងនោះដែរ»។

លោកចៅសង្កាត់បញ្ជាក់ថា ចំពោះការស្តារនេះគឺមានអាជ្ញាប័ណ្ណពីខេត្ត និងការអនុញ្ញាតពីអាជ្ញាធរជាតិអប្សរារួចហើយនៅតែការដោះស្រាយចំពោះពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋដែលយកទៅដាក់នៅសាលាខេត្តប៉ុណ្ណោះ។

លោក លី សំរិទ្ធ អភិបាលរង និងជាអ្នកនាំពាក្យរដ្ឋបាលខេត្តសៀមរាប ថ្លែងនៅថ្ងៃទី១០ ខែតុលាថា ជុំវិញរឿងនេះ លោកនៅមិនទាន់បានដឹងនៅឡើយ។ ចំណែកលោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា ថ្លែងថា អាជ្ញាធរជាតិអប្សរាអនុញ្ញាតជាគោលការណ៍ឱ្យមានការស្តារត្រពាំងបុរាណនោះ ប៉ុន្តែការជីកស្តារជាការទទួលខុសត្រូវរបស់អាជ្ញាធរសង្កាត់ជ្រាវ ក្រុងសៀមរាប ព្រោះនេះជាការស្នើសុំពីអាជ្ញាធរនៅទីនោះ។ យ៉ាងណាចំពោះការស្តារត្រពាំងបុរាណឈ្មោះត្រពាំងហែផ្កានេះ អាជ្ញាធរជាតិអប្សរាក៏បានផ្តល់លក្ខណៈបច្ចេកទេស ដូចជា ការធ្វើកំណាយបុរាណវិទ្យាផងដែរ។

ជុំវិញករណីនេះ ភ្នំពេញប៉ុស្ដិ៍មិនអាចស្វែងរកទំនាក់ទំនងសុំការបំភ្លឺពីតំណាងប្រជាពលរដ្ឋបានឡើយនៅថ្ងៃទី១០ ខែតុលា៕ ■

ជប៉ុនផ្តល់ឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង$៧២លានដល់កម្ពុជា

រី សុចាន់

លោកប្រាក់ សុខុន(ស្តាំ)ក្នុងពិធីចុះហត្ថលេខាប្រគល់ជំនួយដោយឯកអគ្គរាជទូតជប៉ុនពីថ្ងៃទី១១ តុលា។ រូបថត ក្រសួងការបរទេស

ភ្នំពេញ: ជប៉ុនចុះហត្ថលេខាផ្តល់ឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណង៧២លានដុល្លារ ដល់កម្ពុជា ដើម្បីអនុវត្តគម្រោងចំនួន៦ ក្នុងការរួមចំណែកដល់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៃព្រះរាជាណាចក្រកម្ពុជា។

ការចុះហត្ថលេខានេះធ្វើឡើងរវាងលោកមិកាមិ ម៉ាសាហ៊ីរ៉ូ (MIKAMI Masahiro) ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា និងលោកប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស នាថ្ងៃទី១១ តុលា នៅទីស្តីការក្រសួងការបរទេស។ គម្រោងទាំង៦ រួមមាន គម្រោងផ្គត់ផ្គង់ទឹកស្អាត គម្រោងបោសសម្អាតមីន គម្រោងបំពាក់សម្ភារបច្ចេកទេសសម្រាប់មន្ទីរពិសោធន៍ជាតិសំណង់ គម្រោងស្ថានីយវាស់វែងអចិន្ត្រៃយ៍ មជ្ឈមណ្ឌលទិន្នន័យ គម្រោងសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងគម្រោងឧស្សាហកម្មគ្រឿងយន្ត អេឡិចត្រូនិក និងមេកានិក។

ក្រសួងការបរទេសបញ្ជាក់ក្នុងសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី១១ ខែតុលា ថា៖ «[ជំនួយនេះ]ដើម្បីរួមចំណែកដល់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម នៃព្រះរាជាណាចក្រកម្ពុជា»។

សេចក្តីប្រកាសព័ត៌មានបញ្ជាក់ថា ឥណទានសម្បទាន មាន១គម្រោង គឺគម្រោងពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតខេត្តសៀមរាបដំណាក់កាលទី២ ដែលមានទឹកប្រាក់ប្រមាណ៥៨លានដុល្លារ។ រីឯហិរញ្ញប្បទានឥតសំណង មាន៥គម្រោង គឺគម្រោងគាំទ្រដំណើរការកសាងផែនការបោសសម្អាតមីន និងត្រួតពិនិត្យគុណភាពលើផ្ទៃដីបោសសម្អាតមីនដែលមានទឹកប្រាក់ប្រមាណ១,៨លានដុល្លារ។ គម្រោងសម្ភារបច្ចេកទេស សម្រាប់មន្ទីរពិសោធន៍ជាតិសំណង់ ដែលមានទឹកប្រាក់ប្រមាណ២,២លានដុល្លារ។

គម្រោងបំពាក់សម្ភារបច្ចេកទេស សម្រាប់ស្ថានីយវាស់វែងអចិន្ត្រៃយ៍ និងមជ្ឈមណ្ឌលទិន្នន័យដែលមានទឹកប្រាក់ប្រមាណ២,២លានដុល្លារ។ គម្រោងបំពាក់សម្ភារបច្ចេកទេសសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានទឹកប្រាក់ប្រមាណ៣,៦លានដុល្លារ។ ចុងក្រោយ ហិរញ្ញប្បទានឥតសំណងនេះក៏នឹងត្រូវប្រើប្រាស់ដើម្បីអនុវត្តគម្រោងបំពាក់សម្ភារបរិក្ខារ និងគ្រឿងម៉ាស៊ីនក្នុងវិស័យឧស្សាហកម្មគ្រឿងយន្ត អេឡិចត្រូនិក និងមេកានិក នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានទឹកប្រាក់ប្រមាណ៤,៥លានដុល្លារផងដែរ។

យោងតាមសេចក្តីប្រកាសព័ត៌មាននេះ លោកប្រាក់ សុខុន ថ្លែងក្នុងពិធីចុះហត្ថលេខាថា នេះគឺជាសក្ខីភាពនៃការបន្តជួយគាំទ្ររបស់ជប៉ុនដល់កម្ពុជា បើទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ១៩ក្តី ហើយដែលជាការជួយគាំទ្រយ៉ាងរឹងមាំដល់ការអភិវឌ្ឍនៅកម្ពុជា។

លោកថ្លែងថា៖«ប្រទេសជប៉ុនបាននិងកំពុងជួយគាំទ្រដល់កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ តាមរយៈការផ្តល់ឥណទានសម្បទាន ហិរញ្ញប្បទានឥតសំណង និងវ៉ាក់សាំង ហើយដែលជំនួយសប្បុរសធម៌ទាំងនេះឆ្លុះបញ្ចាំងនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធរវាងប្រទេសកម្ពុជា និងជប៉ុន ព្រមទាំងបានរួមចំណែកដល់យុទ្ធនាការចាក់វ៉ាក់សាំងនៅទូទាំងប្រទេសរបស់កម្ពុជា»។

លោកប្រាក់ សុខុន បន្តថា ជំនួយរបស់ជប៉ុនបាននិងកំពុងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសង្គម និងធនធានមនុស្សនៅកម្ពុជា។ ប្រទេសជប៉ុន គឺជាស្ថាបត្យករ ដ៏សកម្មក្នុងដំណើរការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា និងបានរួមចំណែកយ៉ាងសំខាន់បំផុតដល់ដំណើរការកសាងប្រទេសកម្ពុជាឡើងវិញ ក្រោយសង្គ្រាមហែកហួរប្រទេស និងការបំផ្លិចបំផ្លាញអស់ជាច្រើនទសវត្សរ៍។

ស្ថានទូតជប៉ុនប្រចាំកម្ពុជា បញ្ជាក់ក្នុងសេចក្តីប្រកាសព័ត៌មាននាថ្ងៃទី១១ តុលា ថា រដ្ឋាភិបាលជប៉ុន បានសម្រេចពង្រីកជំនួយអភិវឌ្ឍន៍ផ្លូវការ(ODA)ជាឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណងដើម្បីឆ្លើយតបទៅនឹងសំណើ របស់រាជរដ្ឋាភិបាលកម្ពុជា និងដើម្បីពង្រឹងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២។

ស្ថានទូតជប៉ុនបានឱ្យដឹងថា គម្រោង ពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត ខេត្តសៀមរាបនៅដំណាក់កាលទី២នេះ នឹងបន្តអភិវឌ្ឍបរិក្ខារបូមទឹកឆៅ និងរោងចក្រប្រព្រឹត្តិកម្មទឹកស្អាត ដែលមានសមត្ថភាពផលិត៦០ ០០០ម៉ែត្រគូបក្នុង១ថ្ងៃ និងបណ្តាញចែកចាយទឹកដែលមានប្រវែងលើស២០០គីឡូម៉ែត្រ នៅខេត្តសៀមរាប បន្ទាប់ពីដំណាក់កាលទី១។

ស្ថានទូតជប៉ុនបញ្ជាក់ថា៖ «គម្រោងសហប្រតិបត្តិការទាំងនេះត្រូវបានរំពឹងទុកថា នឹងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យនីមួយៗនាពេលអនាគត និងការយោគយល់គ្នាទៅវិញទៅមក ក៏ដូចជាការពង្រឹងទំនាក់ទំនងមិត្តភាព រវាងជប៉ុន និងកម្ពុជា»៕ ■

បញ្ជូនយុវជនម្នាក់ទៅតុលាការករណីលួងក្មេងស្រីទៅរួមតេទនៅសណ្ឋាគារ

គីម សារុំ

កំពង់ចាម:កងរាជអាវុធហត្ថខេត្តកំពង់ចាម បានបញ្ជូនយុវជនម្នាក់ទៅតុលាការខេត្តនៅថ្ងៃទី១១តុលា ពាក់ព័ន្ធការលួងក្មេងស្រីអាយុ១២ឆ្នាំទៅរួមភេទប្រព្រឹត្តនៅសណ្ឋាគារមួយ ក្នុងសង្កាត់វាលវង់ ក្រុងខេត្តកំពង់ចាម។

លោក សែម យាង ប្រធានមន្ទីរយុត្តិធម៌ នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត ប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី១១តុលា ថា ជនសង្ស័យម្នាក់ត្រូវបានសមត្ថកិច្ចបញ្ជូនទៅសាលាដំបូងខេត្តកំពង់ចាម នៅថ្ងៃទី១១ តុលា។ ជនសង្ស័យត្រូវបានឪពុកក្មេងរងគ្រោះប្តឹងថា បានលួងកូនស្រីគាត់យកទៅរួមភេទ។

លោកបានថ្លែងថា៖ «ជនសង្ស័យម្នាក់នេះខាងខ្ញុំបញ្ជូនទៅតុលាការ ជាប់ពាក់ព័ន្ធរួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ»។

បើតាមលោក សែម យាង ការឃាត់ខ្លួនយុវជនសង្ស័យម្នាក់នេះ គឺដោយសារឪពុករបស់ជនរងគ្រោះឈ្មោះ ម. ស. ហ. ទ ភេទស្រី អាយុ១២ឆ្នាំ(កូនខ្មែរអិស្លាម)បានដាក់ពាក្យបណ្តឹងនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃកងរាជអាវុធហត្ថខេត្តកំពង់ចាមកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០២១។

នៅក្នុងពាក្យបណ្តឹងនោះ បានចោទប្រកាន់ឈ្មោះ សួង អ្នរណា ភេទប្រុស អាយុ១៨ ឆ្នាំ រស់នៅភូមិចំការដូង សង្កាត់ខណ្ឌដង្កោ រាជធានីភ្នំពេញថា បានប្រព្រឹត្តសកម្មភាពលួងលោមយកកូនស្រីរបស់គាត់អាយុ១២ឆ្នាំទៅរួមភេទ។

យុវជនជាជនសង្ស័យក្រោយឃាត់ខ្លួនពីថ្ងៃ៩តុលា។ រូបថត កងរាជអាវុធហត្ថ

នៅថ្ងៃទី៨ខែតុលាឆ្នាំ២០២១ ជនសង្ស័យបាននាំក្មេងរងគ្រោះទៅដេកនៅសណ្ឋាគារដែលមានយីហោ ហេង ហេង ស្ថិតនៅសង្កាត់វាលវង់ ក្រុងកំពង់ចាម និងរំលោភសេពសន្ថវៈបានសម្រេច។ ក្រោយទទួលបានពាក្យបណ្តឹងពីឪពុករបស់ក្មេងស្រីរងគ្រោះមកកម្លាំងសមត្ថកិច្ចជំនាញនៃមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសកងរាជអាវុធហត្ថខេត្តកំពង់ចាម បានសហការជាមួយកម្លាំងមូលដ្ឋានកងរាជអាវុធហត្ថក្រុងកំពង់ចាម ដោយមានការសម្របសម្រួលផ្លូវច្បាប់ពីលោកវង្ស ប៊ុនវិសុទ្ធ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ចាមផង។

បើតាមលោក សែម យាង សមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យបាននៅក្នុងសណ្ឋាគារខាងលើនៅថ្ងៃទី៩តុលា ហើយបានធ្វើតេស្តរកមេរោគកូវីដ ឃើញថាអវិជ្ជមានទើបសម្រេចកសាងសំណុំរឿងបញ្ជូនទៅតុលាការតែម្តង៕ ■

ភ្នំពេញ ប៉ុស្ដិ៍

ចាងហ្វាង និង អគ្គនាយក
លី តៃសេង
ប្រធានគ្រប់គ្រងការិនីពន្ធ
សំ រិទ្ធ
អនុប្រធានគ្រប់គ្រងការិនីពន្ធ
សូ វិសាល
ប្រធានក្រុមអ្នកយកព័ត៌មាន
ផាក់ ស៊ាងលី
ការិនីពន្ធរងព័ត៌មានជាតិ
វង្ស សុខេង, ព្រុំ ភ័ក្ត្រ
ការិនីពន្ធព័ត៌មានសេដ្ឋកិច្ច
ម៉ែ គុណមករា
ការិនីពន្ធរងព័ត៌មានសេដ្ឋកិច្ច
វ៉ាន់ ធីយ
ការិនីពន្ធព័ត៌មានអន្តរជាតិ
ប្រាក់ សាយ
ការិនីពន្ធជីវិតកម្សាន្ត
ប៉ាន់ ស៊ីម៉ាឡា
ការិនីពន្ធរងជីវិតកម្សាន្ត
ប៉ាន់ រិទ្ធា, ហុង រស្មី
ការិនីពន្ធរងព័ត៌មានកីឡា
ឈន ណន
ការិនីពន្ធរង/អ្នកបកប្រែព័ត៌មានកីឡា
ណែម វណ្ណៈ
ការិនីពន្ធគេហទំព័រ
លាង ផាន់ណារ៉ា
អ្នកយកព័ត៌មានជាន់ខ្ពស់
មាស សុខជា, ឡៀម ឆេង, មុំ គន្ធា
អ្នកយកព័ត៌មាន
ឃុត សុភចរិយា, យឺន ពន្លក, គីម សារុំ, ហ៊ីន ពិសី, នៅ ស៊ីវុត្ថា, ឡុង គីមម៉ារីតា,ឡាយ សាមាន, សួស យ៉ាមី, ធូ វីរៈ, អោម ប៊ុនធឿន រ៉ន ដារ៉ា, រ័ត្ន សុជាតា, រី សុចាន់
អ្នកបកប្រែ
ប៊ុន ផល្លា, ជិន ណាន, សយ រ៉ាស៊ី
ការរូបថត
ហេង ជីវ៉ែន, ហុង មិនា, ហ៊ាន រង្សី
អ្នកកែសម្រួលអត្ថាវិរុទ្ធ
ពៃក រស់, ម៉ី សុមុនី, សួន ឡង់ទី
ប្រធានផ្នែកផលិតកម្ម និងបោះពុម្ព
ញឹម សុក្រតីរ:
ផ្នែករចនាក្រាហ្វិក
ទេព ធឿនធីតា, ទឹម ប៊ូរិទ្ធ
ផ្នែកផ្សាយពាណិជ្ជកម្ម
ជៃម៍ អ៊ុងស៊ួន តិក
ចាប ណារិទ្ធ, 017 996 241
ហ៊ុន ចាន់ណេត, 017 578 768
ប្រាជ្ញ មុន្នីរ:, 015 239 293
កែវ ពុទ្ធី, 012 966 605
ពាំង ប៉ាត្រីយ៉ា, 081 872 202
JESSA PIASTRO, 092 445 983
ប្រធានចែកចាយកាសែតស្ដីទី
ចិញ្ច រិទ្ធី, 087 888 854
ប្រធានចែកចាយកាសែត
ន្ទ ចាន់ធី, 096 999 2828
យឹម វាសនា, 015 814 499
ប្រធានផ្នែករដ្ឋបាល និងធនធានមនុស្ស
ពេជ្រ សុជាតិ
ជំនួយការផ្នែករដ្ឋបាល និងធនធានមនុស្ស
ញ៉ិល សោភា
នាយិកាហិរញ្ញវត្ថុ: ហ៊ាង តាំងម៉េង
ប្រធានគណនេយ្យ: ស្រេន រិច្ចិកា
ផ្នែកព័ត៌មានវិទ្យា និងរចនាគេហទំព័រ
វង់ អួន
ផ្នែករចនាទំព័រ
សួន សាវ៉ាតឌី, ជុំ សុគន្ធី, ដាញ់ ប៊ូវ៉ាត់, ថាន វាសនា
ការិយាល័យខេត្តសៀមរាប
សុការិទ្ធ ប្លន់ឌៀល
ផ្ទះ មេឌា ខូ អិលធីឌី
ជាន់ទី៧ នៃអគារ THE ELEMENTS CONDOMINIUM មហាវិថី សម្តេច ហ៊ុន សែន(ផ្លូវ៦០ម៉ែត្រ) ភូមិទួលរកា៣ សង្កាត់ចាក់អង្រែក្រោម, ខណ្ឌមានជ័យ,១២៣៥៣ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ៨៨៨ ១៦១, ០២៣ ៨៨៨ ១៦២
CELLCARD : ០៧៨ ៥៥៥ ១៦៦, ០៧៨ ៥៥៥ ១៣៣
SMART : ០៨៦ ៨២២ ៩៩៩, ០៨៦ ២៧៧ ៩៩៩
ការិយាល័យសៀមរាប
ផ្ទះលេខ៦២៩ ផ្លូវលេខ៦ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប
ទូរស័ព្ទ ០៦៣ ៩៦៦ ២៩០

សេដ្ឋកិច្ច

www.postkhmer.com

ទិន្នន័យទីផ្សារមូលបត្រកម្ពុជា កាលបរិច្ឆេទ: ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១

វិធីសាស្ត្រជួញដូរតាមការដេញថ្លៃ (ATM)

NO	STOCK	CLOSING PRICE	OPENING PRICE	HIGH	LOW
1	ABC	11,320	11,480	11,580	11,300
2	GTI	4,360	4,400	4,400	4,360
3	PAS	13,480	13,580	13,580	13,460
4	PEPC	3,130	3,160	3,160	3,110
5	PPAP	14,960	14,980	15,000	14,880
6	PPSP	2,040	2,050	2,050	2,020
7	PWSA	7,000	7,000	7,000	7,000

G-LINK
Where Financial Investment Begins...
www.goldenfxlink.com | 023 22 6666

ក្រុមហ៊ុនចុះបញ្ជី ២ បានបង្ហាញពីភាពរីកចម្រើននៃអាជីវកម្មរបស់ខ្លួន

ម៉ែ គុណមករា

ភ្នំពេញ: ក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា (CSX) ចំនួន២ បានរាយការណ៍ពីការស្ទុះងើបឡើងវិញនៃប្រតិបត្តិការអាជីវកម្មរបស់ពួកគេក្នុងរយៈពេល៣ត្រីមាសចុងក្រោយនេះ ដោយសារភាពប្រសើរឡើងនៃសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោកពីវិបត្តិសុខភាពជំងឺកូវីដ១៩។

ក្រុមហ៊ុនកំពង់ផែស្វយ័តក្រុងភ្នំពេញ (PPAP) បានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុផ្ញើទៅ CSX កាលពីថ្ងៃទី៨ ខែតុលាថា ចំនួនកុងតឺន័រឆ្លងកាត់កំពង់ផែ បានកើនឡើងជិត ១៩ភាគរយ ខណៈចំនួនទំនិញនិងឥន្ធនៈឧស្ម័ន កើនឡើង ៤,២៣ ភាគរយផងដែរនៅក្នុងរយៈពេល ៩ខែដំបូងនៃឆ្នាំ២០២១។

រីឯក្រុមហ៊ុន PESTECH (Cambodia) ក៏បានរាយការណ៍ថា ប្រាក់ចំណូលសម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០២១ បានកត់ត្រាចំនួន ២៧៣ ៦២៨លានរៀលតំណាងឱ្យការកើន ៧០ ៦១៤ លានរៀល ឬ ៣៤,៨ភាគរយបើធៀបនឹងឆ្នាំហិរញ្ញវត្ថុ២០២០ ដែលបានកត់ត្រា ២០៣,០១៤លានរៀល។

ក្រុមហ៊ុន PESTECH បានឱ្យដឹងថា៖«ការកើនឡើងនេះភាគច្រើនបានមកពីការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅកម្ពុជា និងនៅប្រទេសប៉ាពូអាស៊ីនូវែលហ្គីណេ»។

ជាមួយគ្នានេះក្រុមហ៊ុនក៏បានរាយការណ៍ពីការធ្លាក់ចុះប្រាក់ចំណេញប្រតិបត្តិការពី ៦៤ ៦៨០លានរៀលនៅឆ្នាំហិរញ្ញវត្ថុឆ្នាំ២០២០ មកនៅត្រឹម ៣១ ០៣៣លានរៀលនៅឆ្នាំហិរញ្ញវត្ថុឆ្នាំ២០២១ ដែលតំណាងឱ្យការថយចុះ ៣៣ ៦៤៧លានរៀល ឬ ៥២,០ភាគរយ ដែលភាគច្រើនដោយសារប្រាក់ចំណេញកាន់តែខ្ពស់ ដែលបានមកពីការបញ្ចប់គម្រោងធំៗចំនួន ២ ក្នុងឆ្នាំហិរញ្ញវត្ថុឆ្នាំ២០២០។

ចំណែកប្រាក់ចំណេញសុទ្ធបានកត់ត្រាចំនួន ៥ ៩៨០លានរៀល តំណាងឱ្យការធ្លាក់ចុះ ២៣ ៤៦៣លានរៀល ឬ៧៩,៧ភាគរយបើធៀបនឹងប្រាក់ចំណេញសុទ្ធសម្រាប់ឆ្នាំហិរញ្ញវត្ថុឆ្នាំ ២០២០ ដែលមានចំនួន ២៩ ៤៤៣ លានរៀល។ យោងតាមរបាយការណ៍បានឱ្យដឹងថា ប្រាក់ចំណេញសុទ្ធកាន់តែខ្ពស់នៅក្នុងឆ្នាំហិរញ្ញវត្ថុឆ្នាំ២០២០ គឺដោយសារតែប្រាក់ចំណេញកាន់តែខ្ពស់ដែលបានមកពីការបញ្ចប់គម្រោងធំៗចំនួន ២។

លោក Han Fatt Juan អគ្គនាយក PESTECH បានឱ្យដឹងកាលពីខែឧសភាថា PESTECH បានអនុវត្តការងារដែលប្រើប្រាស់កម្លាំងពលកម្មច្រើន នៅលើអណ្តូងរ៉ែមាស អូខ្វាវ ក្នុងខេត្តមណ្ឌលគិរី។

បុរសម្នាក់កំពុងពិនិត្យមើលស្ថានភាពប្រែប្រួលនៃផ្សារមូលបត្រកម្ពុជា។ ហ៊ាន រង្សី

លោកបន្ថែមថា ក្រុមហ៊ុនមួយនេះកំពុងធ្វើការយ៉ាងសកម្មលើកសិដ្ឋានផលិតថាមពលសូឡាដែលមានថាមពល ២០មេហ្គាវ៉ាត់ នៅក្នុងក្រុងបាវិត ខេត្តស្វាយរៀង ដោយការងារបម្រុងមានការរីកចម្រើនជាលំដាប់ ហើយបានដាក់ការបញ្ចូទិញជាមុនសម្រាប់សម្ភារ និងគ្រឿងផ្គុំសំខាន់ៗដែលនឹងត្រូវផ្តល់នៅត្រីមាសទី៤ ឆ្នាំនេះនិងឆ្នាំបន្ទាប់ទៀត។

លោកបន្ថែមថា ការងារលើគម្រោងខ្សែបញ្ជូនថាមពលចម្ងាយ ១៣០គីឡូម៉ែត្រខាងកើតខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ កំពុងដំណើរការយ៉ាងរលូនដោយមានមូលដ្ឋានមួយចំនួនកំពុងត្រូវបានសាងសង់នៅលើទីតាំងដែលបានជ្រើសរើស។ លោកបន្តថា ប៉មខ្សែបញ្ជូនថាមពល និងឧបករណ៍ថាមពលនឹងត្រូវដំឡើងឡើងនៅពេលសម្ភារមកដល់នៅត្រីមាសខាងមុខ។

លោក Han ថ្លែងថា៖«យើងសង្ឃឹមថានឹងបន្តសកម្មភាពអនុវត្តគម្រោងចំពេលការរីករាលដាលជំងឺកូវីដ១៩។ យើងនឹងខិតខំធ្វើការជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីធានាបរិយាកាសការងារប្រកបដោយសុវត្ថិភាពសម្រាប់សមាជិកក្រុមរបស់យើងទាំងអស់»។

លោកឱ្យដឹងទៀតថា PESTECH ក៏មានភារកិច្ចអនុវត្តផ្នែកខ្លះនៃការងារដំណាក់កាលទី២ នៃគម្រោងពង្រីកប្រព័ន្ធខ្សែបញ្ជូនថាមពល និងចែកចាយក្នុងទីក្រុងភ្នំពេញចំនួន ២៣០ គីឡូវ៉ុលដែលលោកសង្កត់ធ្ងន់ថា ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលដ៏សំខាន់នៅកណ្តាលរាជធានីភ្នំពេញ។

លោកបន្តថា គម្រោងនេះជាប់ពាក់ព័ន្ធនឹងការដាក់ពង្រាយម៉ាស៊ីនខួងទិសដៅផ្តេក (HDD) ដែលកាត់បន្ថយការរំខានដល់ការធ្វើដំណើរតាមយានយន្ត និងថ្មើរជើង។

កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ក្រុមហ៊ុនមួយនេះបានចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា ប្រកបដោយភាពជោគជ័យ។ ចំនួនភាគហ៊ុនដែលចេញថ្មីមានចំនួន ៣ ៩៤៥ ០០០ ភាគហ៊ុនដែលមានតម្លៃស្មើនឹង ៤០០ រៀលឬ០.១០ដុល្លារក្នុងតម្លៃទិញលក់ ៣១២០រៀល ឬ០,៧៦ដុល្លារ។ នៅពេលបញ្ចប់ការចុះបញ្ជីនៅ CSX ក្រុមហ៊ុន PESTECH International Berhad បានគ្រប់គ្រងភាគហ៊ុនចំនួន ៩៤,៧៤ភាគរយរបស់ក្រុមហ៊ុនមួយនេះ៕ LA ■

ពាណិជ្ជកម្មទ្វេភាគីកម្ពុជា...

តពីទំព័រ ១...តម្លៃសរុប ៥ ៤៩៩,៤លានដុល្លារ កើនឡើង២៨,៤៧ភាគរយ ពីចំនួន ៤ ២៨០,៥លានដុល្លារនារយៈពេលដូចគ្នាឆ្នាំ២០២០។

បើតាមការិយាល័យជំរឿនអាមេរិក ក្នុងរយៈពេលខាងលើការនាំចំនិញពីកម្ពុជា មានទឹកប្រាក់ ៥ ២២០,៦លានដុល្លារ កើនឡើង ២៧,៨៨ភាគរយ និងការនាំចំនិញពីអាមេរិកមកកម្ពុជា មានទឹកប្រាក់ ២៧៨,៨ លានដុល្លារ កើនឡើង៤០,៥៩ ភាគរយ។

អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា លោក ហុង វណ្ណៈ បានប្រាប់ភ្នំពេញប៉ុស្តិ៍នាថ្ងៃទី១១ តុលាថា ភាពវិជ្ជមាននៃការធ្វើពាណិជ្ជកម្មរវាងភាគីទាំង ២ គឺមកពីលក្ខណៈមួយចំនួនដូចជា ភាពល្អប្រសើរនៃទំនាក់ទំនងការទូត, ផលិតកម្មរបស់កម្ពុជាអាចឆ្លើយតបនឹងតម្រូវការទីផ្សារអាមេរិក និងអាចបណ្តាលមកពីប្រទេសនាំចេញទៅទីផ្សារអាមេរិកមួយចំនួនជួបបញ្ហា (មីយ៉ាន់ម៉ា)។

លោកបញ្ជាក់ថា៖«ដោយសារអាមេរិក តែងតែចង់បានទំនាក់ទំនងល្អជាមួយបណ្តាប្រទេសតំបន់អាស៊ាន ដូច្នេះខ្ញុំមានសុទិដ្ឋិនិយមថា ទីផ្សារនាំចេញរបស់កម្ពុជា នឹងមានទំហំកាន់តែធំនៅពេលអនាគត»។

ទំនិញដែលកម្ពុជានាំចេញទៅអាមេរិកមានសម្លៀកបំពាក់ ស្បែកជើង កាបូប កង់ និងផលិតផលកសិកម្ម ជាដើម។ ចំណែកផលិតផលអាមេរិកនាំមកកម្ពុជាមានដូចជា យានយន្ត ចំណីសត្វ និងគ្រឿងម៉ាស៊ីន។

កាលពីខែកញ្ញា ឆ្នាំ២០២១ សហរដ្ឋអាមេរិក បានបើកការិយាល័យរបស់ក្រសួងកសិកម្ម (USDA) ជាលើកដំបូងរបស់ខ្លួននៅកម្ពុជា ដើម្បីទ្រទ្រង់ពាណិជ្ជកម្មទាក់ទងនឹងកសិកម្ម ដែលកំពុងមានកំណើនជាមួយគ្នាជាបន្តបន្ទាប់។

យោងតាមស្ថានទូតអាមេរិកប្រចាំកម្ពុជា ទីផ្សារកម្ពុជាកំពុងមានកំណើនសម្រាប់ទំនិញកសិកម្មនាំចេញរបស់អាមេរិក ដោយក្នុងឆ្នាំ២០២០ គេលក់បានក្នុងតម្លៃ ៧២,៧លានដុល្លារ កើន ៤៧៤ភាគរយនៅក្នុងរយៈពេល១០ឆ្នាំមកនេះ។

ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា លោក W. Patrick Murphy និយាយថា ប្រទេសកម្ពុជាចូលចិត្តផលិតផល និងបច្ចេកវិទ្យាកសិកម្មអាមេរិក។ ការិយាល័យថ្មីរបស់ USDA នឹងចូលរួមជំរុញឱ្យអតិថិជន និងផលិតករកម្ពុជាទទួលបានផលិតផល និងបច្ចេកវិទ្យាទាំងនោះឱ្យបានកាន់តែច្រើន។

លោកបានថ្លែងថា៖«នេះជាដំណឹងល្អសម្រាប់ប្រទេសទាំង ២ ហើយវាក៏បានឆ្លុះបញ្ចាំងឱ្យឃើញពីការប្តេជ្ញាចិត្តយូរអង្វែងរបស់យើង ក្នុងការធ្វើឱ្យប្រជាជនកម្ពុជាទទួលបាននូវទំនិញ និងសេវាប្រកបដោយគុណភាពពីសហរដ្ឋអាមេរិក»។

កាលពីឆ្នាំ២០២០ ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំង ២ មានតម្លៃសរុប៦ ៩២១,៣លានដុល្លារកើនឡើង១៧,៨៩ភាគរយធៀបនឹងឆ្នាំ២០១៩។ ក្នុងនោះការនាំចេញរបស់កម្ពុជាមានតម្លៃ ៦ ៥៧៧,៧លានដុល្លារ កើន ២២,៧៩ភាគរយ ចំណែកការនាំទំនិញពីអាមេរិកមកកម្ពុជាវិញមានតម្លៃ៣៤៣,-៦លានដុល្លារធ្លាក់ចុះ៣៣,-១៥ភាគរយ។ នេះបើយោងតាមការិយាល័យពាណិជ្ជកម្មអាមេរិក៕ LA ■

ស្ថាបនា ទទួលមូលនិធិពី OP Finnfund Global Impact Fund I

ម៉ៃ គុណមករា

ភ្នំពេញ: ស្ថាបនា ដែលជាធនាគារក្នុងស្រុក បានទទួលមូលនិធិចំនួន១០លានដុល្លារពីមូលនិធិ OP Finnfund Global Impact Fund I ដែលមានមូលដ្ឋាននៅប្រទេសហ្វាំងឡង់ ដើម្បីជាការផ្តល់លទ្ធភាពបន្ថែមទៀតដល់ធនាគារមួយនេះសម្រាប់ពង្រីកប្រាក់កម្ចីរបស់ខ្លួនទៅដល់អតិថិជនសហគ្រាសធុនតូច និងមធ្យម(SMEs)ជាពិសេសស្ត្រី។

អគារសាខាមួយរបស់ធនាគារស្ថាបនា ក្នុងរាជធានីភ្នំពេញ។ រូបថត ហេង ជីវិន

លោក Fung Kai Jin អគ្គនាយកធនាគារស្ថាបនា បានឱ្យដឹងថា ធនាគាររបស់លោកកំពុងផ្តល់សេវាកម្មជាច្រើនទៅដល់សហគ្រាសធុនតូច និងមធ្យម និងសហគ្រិនស្ត្រីដើម្បីរួមចំណែកដល់សេដ្ឋកិច្ចជាតិ។

លោក Fung ថ្លែងថា៖«ធនាគារស្ថាបនាមិនត្រឹមតែផ្តោតលើការផ្តល់សេវាកម្មហិរញ្ញវត្ថុដល់អតិថិជនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចង់ផ្តល់នូវសេវាកម្មមិនមែនហិរញ្ញវត្ថុដែលផ្តល់គុណតម្លៃបន្ថែមដល់សហគ្រាសធុនតូច និងមធ្យម និងស្ត្រីផងដែរ»។

លោកបានបន្ថែមថា៖«ដូចយើងដឹងហើយថាអាជីវកម្មនៅប្រទេសកម្ពុជាភាគច្រើន គឺជាសហគ្រាសធុនតូច និងមធ្យម ហើយវាមានសារៈសំខាន់ខ្លាំងចំពោះសេដ្ឋកិច្ចប្រទេសកម្ពុជា។ សហគ្រាសធុនតូច និងមធ្យមចំនួន ២៦ភាគរយត្រូវគ្រប់គ្រងដោយស្ត្រី ខណៈសហគ្រាសមីក្រូ ៦២ភាគរយគ្រប់គ្រងដោយស្ត្រី ដូច្នេះយើងមិនអាចបញ្ជាក់ពីសារៈសំខាន់របស់ពួកគេចំពោះសេដ្ឋកិច្ចកម្ពុជាបានទេ»។

លោកបន្តថា៖«យើងក៏ជានាបាននូវសមភាពយេនឌ័រក្នុងការជ្រើសរើសបុគ្គលិករបស់យើងផងដែរ ក្រៅពីផ្តល់លទ្ធភាព និងទ្រទ្រង់ដល់សហគ្រិនទាំងនេះជាមួយនឹងផលិតផល និងសេវាកម្មរបស់យើងដូចជា ប្រាក់កម្ចីបង់រំលស់អាជីវកម្ម ការផ្តល់ប្រាក់កម្ចីដែលអាចបត់បែនបាន ការទូទាត់ដោយមិនចាំបាច់ធ្វើទំនាក់ទំនង និងការសន្សំប្រាក់វៃឆ្លាត»។

លោក Tuomas Virtala ប្រធានគ្រប់គ្រងទ្រព្យសកម្មនៅធនាគារ OP Corporate Bank បានឱ្យដឹងថា ការជំរុញកំណើនសហគ្រាសធុនតូច និងមធ្យម ព្រមទាំងការពង្រឹងអំណាចស្ត្រីទាំង២ គឺជាស្នូលនៃយុទ្ធសាស្ត្រវិនិយោគរបស់មូលនិធិ OP Finnfund Global Impact Fund I។

លោកថ្លែងថា៖ «យើងរីករាយដែលបានរួមកម្លាំង និងគាំទ្រការងាររបស់ធនាគារស្ថាបនា ទាំងក្នុងការអភិវឌ្ឍប្រតិបត្តិការរបស់ពួកគេ និងសមភាពយេនឌ័រនៅក្នុងធនាគារ ព្រមទាំងរួមចំណែកដល់វិស័យហិរញ្ញវត្ថុកម្ពុជា និងសង្គមជាតិទាំងមូល»។

បើតាមលោក Antti Urvas នាយករងប្រធានផលបត្រនៃគ្រឹះស្ថានហិរញ្ញវត្ថុនៅ Finnfund ក្នុងអំឡុងពេល ៦ឆ្នាំនៃភាពជាដៃគូ លោកសង្កេតឃើញធនាគារស្ថាបនាបានអភិវឌ្ឍខ្លួនពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទៅជាធនាគារពាណិជ្ជ។ ទន្ទឹមនឹងនេះការងាររបស់ពួកគេឆ្ពោះទៅរកសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី ដែលធ្វើឱ្យធនាគារស្ថាបនាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្ថិតនៅក្រោមគំនិតផ្តួចផ្តើម 2x Challenge។

លោកបញ្ជាក់ថា៖«មហិច្ឆតាក្នុងការអភិវឌ្ឍប្រតិបត្តិការរបស់ខ្លួន និងការក្លាយជាធនាគារឈានមុខគេក្នុងអេកូស៊ីស្តែមទូទាត់នៅកម្ពុជាធ្វើឱ្យធនាគារស្ថាបនាក្លាយជាដៃគូដ៏គួរឱ្យចាប់អារម្មណ៍សម្រាប់ Finnfund នៅពេលអនាគត។ យើងក៏រីករាយដែលមានមូលនិធិ OP Finnfund Global Impact Fund I ដាក់បញ្ចូលជាវិនិយោគិនថ្មីក្នុងធនាគារនេះ»៕LA ■

អតិផរណានៅស្រីលង្កាកើនកាន់តែខ្ពស់ ខណៈរដ្ឋាភិបាលប្រកាសមិនអន្តរាគមន៍ទេ

ទីក្រុងកូឡុំបូ: ប្រធានាធិបតីស្រីលង្កាលោក Gotabaya Rajapaksa បានសារភាពថា រដ្ឋាភិបាលរបស់លោក នឹង«មិនផ្តល់ទេ» ពេលដែលកង្វះខាតស្បៀងអាហារ ថ្នាំពេទ្យនិងរបស់របរចាំបាច់ផ្សេងៗទៀតនៅតែបន្តកើតមានដោយសារតែការធ្លាក់ចុះនៃអត្រាប្តូរប្រាក់បរទេស និងបាត់បង់សមត្ថភាពដោះបំណុលដ៏ច្រើន។

ការិយាល័យរបស់លោក Rajapaksa បានដកស្រង់សម្តីគាត់ដោយនិយាយកាលពីថ្ងៃអាទិត្យថា៖«ប្រជាជនអាចមានអារម្មណ៍មិនសប្បាយចិត្តចំពោះខ្ញុំនិងរដ្ឋាភិបាលចំពោះការមិនផ្តល់ឱ្យដូចដែលពួកគេរំពឹង»។

លោកបានប្រាប់កងទ័ពនៅក្នុងសុន្ទរកថាមួយដែលប្រារព្ធខួបលើកទី៧២នៃការបង្កើតយោធាថា៖«ខ្ញុំទទួលយករឿងនេះ។ មិនត្រឹមតែខ្ញុំប៉ុណ្ណោះទេ រដ្ឋមន្ត្រីនិងសមាជិកសភាទាំងអស់គួរតែទទួលយកដែរ»។

កង្វះរូបិយប័ណ្ណបរទេសបានរារាំងសមត្ថភាពរបស់ប្រទេសដែនកោះនេះដែលមានប្រជាជនចំនួន២១លាននាក់ក្នុងការនាំចូលទំនិញដែលជំរុញឱ្យរដ្ឋាភិបាលប្រកាសភាពអាសន្ន និងកំណត់ការផ្តល់របប។

កាលពីថ្ងៃសុក្រ រដ្ឋាភិបាលបានដកការរឹតបន្តឹងតម្លៃលើអាហារសំខាន់ៗក្នុងកិច្ចខិតខំដ៏លំបាកដើម្បីបញ្ចប់ការរក្សាទុកនូវអាហារសំខាន់ៗដូចជាអង្ករ ស្ករស សណ្តែក និងម្សៅទឹកដោះគោ។

ក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីសុន្ទរកថារបស់លោក Rajapaksa កាលពីថ្ងៃអាទិត្យ រដ្ឋាភិបាលក៏បានប្រកាសពីការដំឡើងថ្លៃប្រេងឥន្ធនៈរាវដែលប្រើក្នុងចង្ក្រានចម្អិនអាហារចំនួន ៨៥ភាគរយចាប់ពីថ្ងៃចន្ទ។

តម្លៃម្សៅស្រូវសាលីនិងសម្ភារសំណង់ដូចជាស៊ីម៉ងត៍ក៏បានកើនឡើងជិត១០ភាគរយដែរ។

សាជីវកម្មប្រេងឥន្ធនៈគ្រប់គ្រងដោយរដ្ឋបាននិយាយថា ខ្លួនកំពុងស្នើសុំឱ្យរដ្ឋាភិបាលបង្កើនតម្លៃលក់រាយសម្រាប់ឥន្ធនៈទាំងអស់ដើម្បីទូទាត់ការខាតបង់ដែលបានកើតមានចំនួន៣៥០លានដុល្លារក្នុងរយៈពេល៨ខែដំបូងនៃឆ្នាំនេះ។

សេដ្ឋវិទូឯកជននិងទីភ្នាក់ងារវាយតម្លៃអន្តរជាតិនិយាយថា វិបត្តិសេដ្ឋកិច្ចរបស់ប្រទេសស្រីលង្កាមានមុនពេលមានជំងឺរាតត្បាតកូវីដ១៩ទៅទៀត។

ទុនបម្រុងបរទេសរបស់ប្រទេសស្រីលង្កាមានចំនួន៧,៥ពាន់លានដុល្លារនៅពេលដែល Rajapaksa ចូលកាន់តំណែងនៅខែវិច្ឆិកាឆ្នាំ២០១៩ ប៉ុន្តែបានធ្លាក់ចុះមកត្រឹម២,៥ ពាន់លានដុល្លារនៅចុងខែកញ្ញាដែលបង្កើនឱ្យមានការព្រួយបារម្ភអំពីសមត្ថភាពរបស់ទីក្រុងកូឡុំបូក្នុងការសងបំណុលបរទេសដ៏ធំរបស់ខ្លួន៕ AFP/RR ■

លោក Gotabaya Rajapaksa **ប្រធានាធិបតីស្រីលង្កា។** រូបថត AFP

គម្រោងវិនិយោគឯកជនក្រៅ...

តពីទំព័រ ១ ... របាយការណ៍ស្តីពីនិន្នាការសេដ្ឋកិច្ច-សង្គមបង្ហាញថា ការបណ្តាក់ទុនថ្មីៗនៅកម្ពុជា មិនទាន់មានភាពល្អប្រសើរទេ ជាក់ស្តែងចាប់ពីខែមករា-សីហា ឆ្នាំ២០២១ មានគម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេសត្រឹមតែ៧៥គម្រោងប៉ុណ្ណោះ ដែលត្រូវបានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័ត ខណៈតួលេខនេះធ្លាក់ចុះ ៣០គម្រោងធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ គម្រោងថ្មីៗទាំងនេះ អាចបង្កើតការងារបាន ៥៧ ០០០នាក់ ធ្លាក់ចុះ ៣២,៣ភាគរយ និងមានទុនវិនិយោគសរុប ១ ១០៦លានដុល្លារ ធ្លាក់ ៥២,៥ភាគរយ។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា លោក លឹម ហេង បានប្រាប់ភ្នំពេញប៉ុស្ដិ៍ នាថ្ងៃទី១១ ខែតុលាថា ការធ្លាក់ចុះគម្រោងវិនិយោគឯកជននៅក្រៅតំបន់សេដ្ឋកិច្ចពិសេស គឺជាប់ទាក់ទងនឹងឥទ្ធិពលនៃការឆ្លងរាលដាលជំងឺកូវីដ១៩ ដែលបង្ខំឱ្យប្រទេសនីមួយៗធ្វើការរឹតបន្តឹងឬបិទព្រំដែនសម្រាប់ការធ្វើដំណើរ។ បន្ថែមលើនេះ ប្រទេសនីមួយៗសុទ្ធតែបានកំណត់ពីរយៈពេលនៃការធ្វើចត្តាឡីស័កយូរថ្ងៃដែលធ្វើឱ្យឱកាសនៃការចូលមកសិក្សាទីផ្សារ ទីតាំងវិនិយោគ និងបែបបទវិនិយោគត្រូវជាប់គាំង។

លោកបន្ថែមថា ទោះយ៉ាងណាសម្រាប់កម្ពុជា ដែលជាប្រទេសមានអត្រាអ្នកចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ១៩ បានច្រើនជាងគេក្នុងតំបន់ រំពឹងថានឹងអាចចាប់ផ្តើមបើកដំណើរការសេដ្ឋកិច្ចរបស់ខ្លួនឱ្យបានទូលំទូលាយក្នុងពេលឆាប់ៗ។

លោកបញ្ជាក់ថា៖«ខ្ញុំជឿថាផែនការកាត់បន្ថយរយៈពេលធ្វើចត្តាឡីស័ក និងបើកដំណើរការសេដ្ឋកិច្ចឡើងវិញ នឹងបើកឱកាសឱ្យវិនិយោគិនជាច្រើនធ្វើដំណើរមកកម្ពុជា ហើយកំណើននៃការដាក់ពាក្យស្នើសុំវិនិយោគ ក៏ដូចជាការអនុម័តរបស់អាជ្ញាធរនឹងមានសម្ទុះឡើងវិញ ពិសេសចាប់ពីដើមឆ្នាំ២០២២ ដែលពេលនោះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងលក្ខណៈតំបន់ ក៏ត្រូវចូលជាធរមានផងដែរ»។

លោក ហុង វណ្ណៈ: អ្នកស្រាវជ្រាវសេដ្ឋកិច្ចអន្តរជាតិនៃវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា(បណ្ឌិត្យសភាកម្ពុជា) និយាយថា ចាប់ពីមានវិបត្តិជំងឺកូវីដ១៩ ពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ សញ្ញានៃការមកស្នើសុំវិនិយោគហាក់មិនមានសញ្ញាវិជ្ជមាននោះទេ ព្រោះកូវីដ១៩ ធ្វើឱ្យកម្រិតនៃភាពជឿជាក់លើសុវត្ថិភាពផ្នែកសុខាភិបាលធ្លាក់ចុះ។ លោកបន្តថា ក្តីបារម្ភពីសុវត្ថិភាពផ្នែកសុខភាព និងភាពមិនច្បាស់លាស់នៃតម្រូវការទីផ្សារ ធ្វើឱ្យផែនការវិនិយោគជាច្រើនត្រូវពន្យារពេល។ ម៉្យាងទៀតភាពប្រទាញប្រទង់នៃប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗទាំង ២ លើពិភពលោក ក៏បានជះឥទ្ធិពលធ្វើឱ្យវិនិយោគិនមួយចំនួនមានភាពរវែកក្នុងការសម្រេចចិត្តទៅវិនិយោគនៅប្រទេស ឬទីតាំងណាមួយផងដែរ។

ជាមួយនឹងសមិទ្ធផលថ្មីៗដែលរដ្ឋាភិបាលសម្រេចបានជាបន្តបន្ទាប់(ច្បាប់វិនិយោគថ្មី, ការចូលធរមាននៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសនានា, និងសេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន) លោក វណ្ណៈ បានបន្ថែមថា កំណើននៃការចូលមកវិនិយោគនៅកម្ពុជានឹងមានកំណើនឡើងវិញ។

លោកបញ្ជាក់ថា៖«ខ្ញុំអាចនិយាយថា សមិទ្ធផលដែលរដ្ឋាភិបាលកម្ពុជាទើបសម្រេចបាន នឹងក្លាយជាកម្លាំងឆក់ដ៏ខ្លាំងក្នុងការស្រូបទាញអ្នកវិនិយោគធំៗឱ្យបញ្ចេញប្រាក់មកវិនិយោគនៅកម្ពុជា ជាពិសេសបន្ទាប់ពីស្ថានភាពជំងឺកូវីដ១៩មានភាពធូរស្រាល»។

លោកបានបន្ថែមថា តាមការសង្កេតវិស័យដែលកំពុងថមថយ ឬជាប់គាំងនៅពេលនេះនឹងមានកំណើនឡើងវិញក្នុងនោះរួមមានវិស័យទេសចរណ៍, ឧស្សាហកម្ម អចលនទ្រព្យ និងសំណង់ និងបច្ចេកវិទ្យា៕LA ■

តៃវ៉ាន់ថាខ្លួននឹងមិនចុះចាញ់ដោយមានសម្ពាធពីចិនឡើយ ទោះបីមានការអំពាវនាវបង្រួបបង្រួមពីទីក្រុងប៉េកាំង

ហួន ឌីណា

ប្រធានាធិបតីកោះតៃវ៉ាន់ លោកស្រី Tsai Ing-wen និយាយកាលពីថ្ងៃអាទិត្យថា តៃវ៉ាន់នឹងមិនចុះចាញ់នឹងការដាក់សម្ពាធពីទីក្រុងប៉េកាំងទេ ដោយនឹងបន្តពង្រឹងការការពាររបស់ខ្លួន១ថ្ងៃបន្ទាប់ពីសមភាគីចិនប្តេជ្ញាថានឹងនាំមកនូវការបង្រួបបង្រួមដោយសន្តិភាពជាមួយកោះប្រជាធិបតេយ្យមួយនេះ។

អ្នកស្រីនិយាយនៅក្នុងពិធីជួបជុំដើម្បីអបអរសាទរទិវាជាតិតៃវ៉ាន់ថារដ្ឋាភិបាលរបស់លោកស្រីនឹងមិនធ្វើសកម្មភាពដោយប្រញាប់ប្រញាល់ទេប៉ុន្តែក៏មិនគួរមានការបំភាន់ដែលថាប្រជាជនតៃវ៉ាន់នឹងចុះចាញ់ក្រោមសម្ពាធមួយណានោះឡើយ។ បន្ថែមពីនេះ អ្នកស្រីសង្ឃឹមថា នឹងមានការបន្ធូរបន្ថយភាពតានតឹងនៅគ្រប់ច្រកសមុទ្រតៃវ៉ាន់។

សុន្ទរកថារបស់មេដឹកនាំរូបនេះ ធ្វើឡើងទន្ទឹមនឹងការបង្ហាញដ៏កម្រនៃសមត្ថភាពការពារជាតិរបស់តៃវ៉ាន់ក្នុងក្បួនព្យុហយាត្រាពាក់ព័ន្ធនឹងសព្វាវុធជាច្រើនប្រភេទរួមទាំងរថពាសដែកយន្តហោះចម្បាំង និងឧទ្ធម្ភាគចក្រ ដោយគាប់ជួនបន្ទាប់ពីលោកប្រធានាធិបតីចិន ស៊ី ជីនភីង (Xi Jinping) សន្យាថានឹងមានការបង្រួបបង្រួមដោយសន្តិភាពក្នុងសុន្ទរកថាមួយកាលពីថ្ងៃសៅរ៍។

លោកនិយាយក្នុងខួបនៃបដិវត្តន៍ដែលផ្តួលរំលំរាជវង្សអធិរាជចុងក្រោយនៅឆ្នាំ១៩១១ ថា៖ «ការបំបែកឯករាជ្យតៃវ៉ាន់គឺជាឧបសគ្គធំបំផុតក្នុងការសម្រេចបាននូវការបង្រួបបង្រួមជាតិមាតុភូមិ និងគ្រោះថ្នាក់លាក់កំបាំងធ្ងន់ធ្ងរបំផុតចំពោះការធ្វើឱ្យប្រទេសជាតិមានភាពខ្លាំងក្លាឡើងវិញ»។

ទីក្រុងប៉េកាំងចាត់ទុកកោះតៃវ៉ាន់ថាជាខេត្តដែលបំបែកចេញដោយខុសច្បាប់ និងជាផ្នែកមួយនៃទឹកដីរបស់ខ្លួន។ នៅពេលដែលពួកកុម្មុយនីស្តឈ្នះសង្គ្រាមស៊ីវិលប្រឆាំងនឹងអ្នកជាតិនិយមនៅឆ្នាំ១៩៤៩ អ្នកជាតិនិយមបានបង្កើតរដ្ឋាភិបាលគូប្រជែងមួយនៅតៃប៉ិហើយធ្វើស្ងួយគ្រប់គ្រងតាំងពីពេលនោះមក។

លោកស្រី Tsai Ing-Wen **នៅក្នុងពិធីទិវាជាតិតៃវ៉ាន់។** រូបថត AFP

ការអត្ថាធិប្បាយរបស់លោកស៊ីត្រូវរងប្រតិកម្មពីរដ្ឋាភិបាលក្រុងតៃប៉ិដែលនិយាយថាមានតែជនជាតិតៃវ៉ាន់ប៉ុណ្ណោះដែលអាចសម្រេចចិត្តអនាគតរបស់ពួកគេ។លោកនិយាយបែបនេះស្របពេលដែលចិនបង្កើនការលុកលុយរបស់ខ្លួនម្តងហើយម្តងទៀតចូលទៅក្នុងតំបន់កំណត់អត្តសញ្ញាណការពារដែនអាកាសរបស់តៃវ៉ាន់ក្នុងរយៈពេលប៉ុន្មានសប្តាហ៍ថ្មីៗនេះ។

ការលុកលុយបង្កឱ្យមានការរិះគន់ពីក្រសួងការបរទេសអាមេរិកដែលចោទប្រកាន់ចិនពីសកម្មភាពយោធាបង្កហេតុឆ្ពោះទៅកោះតៃវ៉ាន់កាលពីសប្តាហ៍មុន។ អ្នកនាំពាក្យក្រសួងលោកNed Price និយាយថា សកម្មភាពរបស់ចិនកំពុងធ្វើឱ្យអស្ថិរភាពហើយថាពួកគេប្រថុយនឹងការគណនាខុស និងធ្វើឱ្យប៉ះពាល់ដល់សន្តិភាព និងស្ថិរភាពនៅក្នុងតំបន់។

យ៉ាងណាមិញប្រទេសចិនក៏បានស្តីបន្ទោសអាមេរិកចំពោះភាពតានតឹងដែលកើនឡើងដោយប្រទេសយក្សសេដ្ឋកិច្ចទាំង២មានភាពផ្ទុយគ្នាមិនត្រឹមតែបញ្ហាជាមួយតៃវ៉ាន់ប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងបញ្ហាពាណិជ្ជកម្មហុងកុងស្ថានភាពនៅតំបន់ស៊ីនជាំង និងវីរុសកូរ៉ូណា។

ទោះបីជាសហរដ្ឋអាមេរិកមិនមានទំនាក់ទំនងការទូតផ្លូវការជាមួយកោះតៃវ៉ាន់ ប្រទេសនេះត្រូវបានកំណត់ដោយច្បាប់ដើម្បីការពារតៃវ៉ាន់និងជាប្រភពជំនួយយោធានិងនយោបាយធំបំផុតរបស់រដ្ឋាភិបាលក្រុងតៃប៉ិ។ ក្រុងវ៉ាស៊ីនតោនមិនមានកិច្ចព្រមព្រៀងជាក់លាក់ជាមួយទីក្រុងប៉េកាំងស្តីពីទំនាក់ទំនងឆ្លងកាត់ច្រកសមុទ្រនោះទេ។

លោកស្រី Tsai និយាយកាលពីថ្ងៃអាទិត្យថា ស្ថានភាពរបស់តៃវ៉ាន់មានភាពស្មុគស្មាញ និងមានភាពរឹងមាំជាងនៅចំណុចផ្សេងទៀតក្នុងរយៈពេល ៧២ឆ្នាំកន្លងមកនេះហើយវត្តមានយោធាជាប្រចាំរបស់ចិននៅក្នុងតំបន់ការពារអាកាសរបស់តៃវ៉ាន់ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខជាតិនិងសុវត្ថិភាពអាកាសចរណ៍របស់ខ្លួន។

លោកស្រីលើកឡើងថា៖ «យើងនឹងបន្តពង្រឹងការការពារជាតិរបស់យើងនិងបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារខ្លួន ដើម្បីធានាថាគ្មាននរណាអាចបង្ខំតៃវ៉ាន់ឱ្យដើរតាមផ្លូវដែលចិនដាក់ចេញសម្រាប់យើងនោះឡើយ។ នេះក៏ព្រោះតែផ្លូវដែលចិនបានដាក់ចេញមិនផ្តល់នូវរបៀបរស់នៅបែបសេរី និងប្រជាធិបតេយ្យសម្រាប់តៃវ៉ាន់ឬអធិបតេយ្យភាពសម្រាប់ប្រជាជន ២៣ លាននាក់របស់យើងឡើយ»។

អ្នកស្រីTsaiបន្ថែមថាកោះតៃវ៉ាន់នឹងធ្វើអ្វីដែលអាចធ្វើបានដើម្បីការពារស្ថានភាពបច្ចុប្បន្នជាមួយចិនពីការផ្លាស់ប្តូរឯកតោភាគី។

ឆ្លើយតបនឹងការលើកឡើងរបស់លោកស្រី Tsai លោក Ma Xiaoguangអ្នកនាំពាក្យការិយាល័យកិច្ចការតៃវ៉ាន់របស់ចិននិយាយប្រាប់ទីភ្នាក់ងារសារព័ត៌មានស៊ីនហួថា ការថ្លែងបែបនេះវាជាការញុះញង់ឱ្យមានការប្រឈមមុខដាក់គ្នានិងបំភ្លៃការពិត។

លោកនិយាយថា៖«តៃវ៉ាន់គឺជាផ្នែកមួយនៃប្រទេសចិន។ ប្តីបើភាគីទាំង២មិនទាន់បង្រួបបង្រួមទាំងស្រុងតាំងពីឆ្នាំ១៩៤៩ក្តី តែការពិតដែលថា ចិនដីគោកនិងតៃវ៉ាន់ជាកម្មសិទ្ធិរបស់ចិនតែមួយមិនដែលផ្លាស់ប្តូរ និងមិនអាចផ្លាស់ប្តូរបានឡើយ។ អធិបតេយ្យភាព និងទឹកដីរបស់ចិនមិនដែលត្រូវបានបែងចែកហើយនឹងមិនអនុញ្ញាតឱ្យមានការបែងចែកឡើយ»។

លោកXiaoguang បន្ថែមថា៖«ការសម្រេចបាននូវការបង្រួបបង្រួមជាតិមាតុភូមិឱ្យបានពេញលេញគឺជាសេចក្តីប្រាថ្នារួមរបស់ប្រជាជនចិនទាំងក្នុង និងក្រៅប្រទេស និងឆន្ទៈរួមរបស់ប្រជាជាតិចិន។ កោះតៃវ៉ាន់គឺជាកោះកំណប់នៃមាតុភូមិ»។

លោកស្រីTsaiសរសេរនៅក្នុងផ្នែកមួយសម្រាប់កិច្ចការបរទេសចេញផ្សាយកាលពីថ្ងៃអង្គារសប្តាហ៍មុនថា ប្រសិនបើតៃវ៉ាន់ធ្លាក់ទៅក្នុងកណ្តាប់ដៃចិន វានឹងបង្កផលវិបាកមហន្តរាយដល់សន្តិភាពនៅអាស៊ី។ ឆ្លើយតបនឹងអត្ថបទរបស់លោកស្រីTsai សារព័ត៌មានរដ្ឋចិនGlobal Times ចោទប្រកាន់មេដឹកនាំរូបនេះនិងគណបក្សអភិវឌ្ឍន៍ប្រជាធិបតេយ្យរបស់អ្នកស្រីថាប្រែក្លាយលទ្ធិប្រជាធិបតេយ្យរបស់តៃវ៉ាន់ទៅជា«មនោគមន៍វិជ្ជាជ្រុលនិយម»៕ ■

ព័ត៌មានខ្លីៗ

អាមេរិកនិយាយថាការចរចាជាមួយគាលីបង់នៅក្រុងដូហាគឺ «ត្រង់ៗ និងប្រកបដោយវិជ្ជាជីវៈ»

កាលពីថ្ងៃអាទិត្យ ទី១០ តុលាសហរដ្ឋអាមេរិកបាននិយាយថា ការចរចាជាមួយក្រុមតាលីបង់ជាលើកដំបូងចាប់តាំងពីក្រុមនេះចូលកាន់អំណាចនៅប្រទេសអាហ្វហ្គានីស្ថាន គឺ «ត្រង់ៗ និងប្រកបដោយវិជ្ជាជីវៈ» ដោយភាគីអាមេរិកបានបញ្ជាក់ជាថ្មីម្តងទៀតថា ក្រុមតាលីបង់នឹងត្រូវបានវិនិច្ឆ័យដោយសកម្មភាពរបស់ពួកគេ។

អ្នកនាំពាក្យក្រសួងការបរទេសអាមេរិកលោកណេដ ប្រៃស បាននិយាយថា ក្នុងជំនួបនៅក្រុងដូហាប្រទេសកាតា គណៈប្រតិភូអាមេរិកបានផ្តោតទៅលើប្រធានបទសន្តិសុខ ការប្រឆាំងអំពើភេរវកម្ម ការធ្វើដំណើរប្រកបដោយសុវត្ថិភាពសម្រាប់ពលរដ្ឋអាមេរិក ជនបរទេសដទៃទៀត និងជនជាតិអាហ្វហ្គានីស្ថាន ក៏ដូចជាបញ្ហាសិទ្ធិមនុស្ស ជាពិសេសបញ្ហាសិទ្ធស្ត្រី និងកុមារី។

រីឯទូរទស្សន៍ Al-Jazeera វិញបានរាយការណ៍ថា តាលីបង់បានស្នើឱ្យអាមេរិកដោះលែងប្រាក់បម្រុងរាប់ពាន់លានដុល្លារបស់ធនាគារកណ្តាលអាហ្វហ្គានីស្ថាន ដែលឥឡូវនេះកំពុងជាប់បង្គុំកនៅធនាគារបរទេស។

Al-Jazeera ក៏បានរាយការណ៍ថា រដ្ឋមន្ត្រីការបរទេសស្តីទីរបស់តាលីបង់លោកអាមៀ ខាន ម៉ុតាគី បានស្នើឱ្យអាមេរិកជួយផ្គត់ផ្គង់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩សម្រាប់ប្រជាជនអាហ្វហ្គានីស្ថាន ហើយបានពិភាក្សា «ការបើកទំព័រថ្មី» ក្នុងទំនាក់ទំនងរវាងប្រទេសទាំង២។

រហូតមកដល់ពេលនេះគ្មានការរាយការណ៍អំពីការធ្វើកិច្ចព្រមព្រៀង ឬកិច្ចសន្យាណាមួយរវាងភាគីទាំង២ក្នុងការចរចាខាងលើនោះឡើយ៕ **សុខ វេងឈាង**

ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំសហភាពអឺរ៉ុបជំរុញឱ្យអឺរ៉ុបជួសជុលទំនាក់ទំនងដើម្បីចៀសវាងបញ្ហាកង្វះឧស្ម័នធម្មជាតិ

ឯកអគ្គរដ្ឋទូតរុស្ស៊ីប្រចាំសហភាពអឺរ៉ុបបានអំពាវនាវដល់អឺរ៉ុបជួសជុលទំនាក់ទំនងជាមួយទីក្រុងម៉ូស្គូដើម្បីចៀសវាងបញ្ហាកង្វះឧស្ម័នធម្មជាតិនៅពេលអនាគត ប៉ុន្តែបានបញ្ជាក់ថារុស្ស៊ីមិនមានអ្វីពាក់ព័ន្ធទៅនឹងការឡើងថ្លៃនៅពេលថ្មីៗនេះទេ។

តំណាងអចិន្ត្រៃយ៍រុស្ស៊ីប្រចាំសហភាពអឺរ៉ុបលោកវ្ល៉ាឌីមៀរ ឈីហ្សូវបាននិយាយថា លោកព្រួយបារម្ភថាក្រុមហ៊ុនរុស្ស៊ីហ្គាសប្រូម ដែលជាអ្នកផ្គត់ផ្គង់ ៣៥ ភាគរយនៃតម្រូវការឧស្ម័ននៅអឺរ៉ុបនឹងចាត់វិធានការឆាប់ៗនេះតាមការណែនាំរបស់លោកប្រធានាធិបតីវ្ល៉ាឌីមៀរ ពូទីនក្នុងការលៃតម្រូវការផ្គត់ផ្គង់ដើម្បីជួយធ្វើឱ្យតម្លៃថាមពលនៅអឺរ៉ុបមានស្ថិរភាព។

ក្នុងរយៈពេលប៉ុន្មានសប្តាហ៍មុន តម្លៃឧស្ម័នធម្មជាតិនៅទ្វីបអឺរ៉ុបបានហក់ឡើងយ៉ាងខ្លាំង ដែលធ្វើឱ្យមានការព្រួយបារម្ភបន្ថែមទៀតអំពីការឡើងថ្លៃថាមពលនៅរដូវរងា និងការប៉ះពាល់ទៅលើការងើបឡើងវិញនៃសេដ្ឋកិច្ច។ នៅចំណុចមួយកាលពីសប្តាហ៍មុន តម្លៃឧស្ម័នធម្មជាតិនៅទ្វីបអឺរ៉ុបបានកើនដល់ទៅ ១០ ដង បើប្រៀបធៀបទៅនឹងកាលពីដើមឆ្នាំនេះ ដែលក្រោយមកធ្លាក់ចុះវិញបន្ទាប់ពីលោកពូទីនបង្ហាញសញ្ញាថា ហ្គាសប្រូមអាចបង្កើនការផ្គត់ផ្គង់។

ខណៈពេលដែលធ្វើការច្រានចោលការអះអាងពីសមាជិកសភាអឺរ៉ុបមួយចំនួនថា រុស្ស៊ីបានដើរតួក្នុងការឡើងថ្លៃឧស្ម័ននៅអឺរ៉ុប លោកឈីហ្សូវបាននិយាយថា ការសម្រេចចិត្តរបស់អឺរ៉ុបក្នុងការចាត់ទុករុស្ស៊ីជាសត្រូវភូមិសាស្ត្រនយោបាយគឺមិនបានជួយអ្វីទេ។

«ចំណុចសំខាន់នៃបញ្ហានេះគឺគ្រាន់តែជាបញ្ហានៃការប្រើប្រាស់ពាក្យសម្តីប៉ុណ្ណោះ» លោកនិយាយបែបនេះហើយបន្តទៀតថា៖ «ផ្លាស់ប្តូរសត្រូវទៅជាដៃគូហើយអ្វីៗ ត្រូវបានដោះស្រាយកាន់តែងាយស្រួល នៅពេលដែលអឺរ៉ុបរកឃើញឆន្ទៈនយោបាយដើម្បីធ្វើបែបនេះ ពួកគេដឹងថា ត្រូវរកយើងនៅឯណាហើយ»៕ **សុខ វេងឈាង**

ការបន្តតំណែងពីលោកស្រីមឺកែលដ៏តក់ក្រហល់ : របៀបដែលមេដឹកនាំអាល្លឺម៉ង់បរាជ័យក្នុងការរក្សាការគាំទ្រអំណាចគណបក្សខ្លួន

អធិការបតីអាល្លឺម៉ង់ លោកស្រី អេនជេឡា មឺកែល។ រូបថត AFP

សុខ វេងឈាង

អធិការបតីអាល្លឺម៉ង់លោកស្រីអេនជេឡា មឺកែល ត្រូវបានគេចាត់ទុកជាអ្នកនយោបាយជោគជ័យជាងគេក្នុងប្រវត្តិសាស្ត្រនៃប្រទេសនេះ ប៉ុន្តែសម្រាប់ក្រុមអភិរក្សនិយមការបរាជ័យរបស់គណបក្សលោកស្រីក្នុងការបោះឆ្នោតកាលពីខែមុន បានក្លាយជាផ្នែកមិនល្អបានក្នុងកំណត់ត្រាកាន់អំណាចរបស់លោកស្រី។

ដើមឡើយការបោះឆ្នោតថ្ងៃ២៦ កញ្ញា ត្រូវបានគេរំពឹងថានឹងអនុញ្ញាតឱ្យគណបក្សសហភាពប្រជាធិបតេយ្យគ្រិស្ត និងសហភាពសង្គមគ្រិស្ត (CDU/CSU) បន្តកាន់អំណាចបន្ទាប់ពីការចូលនិវត្តន៍របស់លោកស្រីមឺកែល។ ប៉ុន្តែក្រោមការដឹកនាំរបស់អ្នកស្នងតំណែងបន្ទាប់គឺលោកអាមីន ឡាសឆេត គណបក្ស CDU/CSU បានបាត់បង់សំឡេងគាំទ្រមួយចំនួនធំក្នុងការបោះឆ្នោត ធ្វើឱ្យគូប្រជែងទទួលជ័យជម្នះ។ ឥឡូវនេះសមាជិក CDU/CSU ជាច្រើនកំពុងស្តីបន្ទោសលោកស្រីមឺកែលថាបានធ្វេសប្រហែសមិនបានជ្រើសរើសអ្នកស្នងតំណែងដែលអាចឈ្នះឆ្នោតបាន ហើយធ្វើឱ្យបាត់បង់ការគាំទ្រពីក្រុមអ្នកបោះឆ្នោតសំខាន់ៗ។

សមាជិកដទៃទៀតបានធ្វើការរិះគន់ខ្លាំងជាងនេះទៅទៀត ដោយសមាជិកខ្លះនិយាយថាលោកស្រីមឺកែលមិនបានអើពើនឹងបក្សអស់រយៈពេលជាច្រើនឆ្នាំ ហើយបាននិយាយថាស្ថានភាពបក្សនៅពេលបច្ចុប្បន្នគឺជាកំហុសរបស់លោកស្រី។

កាលពីឆ្នាំ២០១៨ លោកស្រីមឺកែលបានលាលែងពីតំណែងប្រធានCDU/CSU ប៉ុន្តែលោកស្រីជ្រើសរើសបន្តកាន់អំណាចជាអធិការបតី។ នេះមានន័យថា អ្នកស្នងតំណែងពីលោកស្រីជាប្រធានបក្សមិនអាចលេចចេញពីស្រមោលរបស់លោកស្រី។ ការសម្រេចចិត្តបែបនេះរបស់លោកស្រីមឺកែលបានរងការរិះគន់យ៉ាងខ្លាំងពីសមាជិកជាន់ខ្ពស់ជាច្រើន ដែលមានជំហរថា តំណែងប្រធានបក្ស និងអធិការបតីគឺត្រូវតែកាន់ដោយបុគ្គល១រូប។

បន្ថែមពីលើនេះទៅទៀត ការលាលែងរបស់លោកស្រីមឺកែលបន្ទាប់ពីការគ្រប់គ្រងជាច្រើនឆ្នាំបានបង្កឱ្យមានប្រេះឆាផ្ទៃក្នុងរវាងក្រុមប្រកួតប្រជែងគ្នាក្នុងគណបក្ស CDU/CSU គឺជាម្លោះរវាងក្រុមទាំងនេះ។

ក្រុមអភិរក្សនិយមនៃ CDU/CSU បានចោទប្រកាន់គោលនយោបាយកណ្តាលនិយមរបស់លោកស្រីមឺកែលថា បានធ្វើឱ្យបាត់បង់ការគាំទ្រពីអ្នកគាំទ្រដើមរបស់ CDU/CSU។

ក្នុងការបោះឆ្នោតកាលពីខែកញ្ញា គណបក្ស CDU/CSU បានទទួលសំឡេងគាំទ្រ ២៤,១ ភាគរយ ដែលធ្លាក់ ៩ ភាគរយពីលទ្ធផលនៃការបោះឆ្នោតកាលពីឆ្នាំ២០១៧។ នេះគឺជាគ្រោះមហន្តរាយដ៏ធំសម្រាប់គណបក្ស ដែលបានកាន់អំណាចនៅប្រទេសអាល្លឺម៉ងជាង ៥២ឆ្នាំក្នុងអំឡុងពេល ៧២ឆ្នាំចុងក្រោយនេះ។

ការបោះឆ្នោតត្រូវបានឈ្នះដោយគណបក្សប្រជាធិបតេយ្យសង្គម (SDP) ដឹកនាំដោយអតីតរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុលោក អូឡាហ្វ សូល។ SDP បានចាប់ផ្តើមធ្វើការចរចាជាមួយគណបក្សបៃតង និងគណបក្សប្រជាធិបតេយ្យសេរី (FDP) ដើម្បីបង្កើតរដ្ឋាភិបាលដែលអាចនឹងក្លាយជាសម្ព័ន្ធភាពកាន់អំណាចត្រីភាគីដំបូងនៅអាល្លឺម៉ង់ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០។

នៅពេលដែលការចរចាត្រីភាគីបានចាប់ផ្តើម លោកឡាសឆេតបានចុះចាញ់នឹងសម្ពាធក្នុងCDU/CSU ឱ្យលោកលាលែងពីតំណែងប្រធានបក្ស ដោយប្រកាសថាលោកនឹងស្នើឱ្យរៀបចំសន្និសីទបក្សដើម្បីបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំថ្មី។ ប្រសិនបើលោកធ្វើបែបនេះ គណបក្ស CDU នឹងប្រឈមនឹងការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំលើកទី៣ក្នុងរយៈពេលតិចជាង៣ឆ្នាំ។ ■

ព័ត៌មានខ្លីៗ

យន្តហោះរុស្ស៊ីដឹកអ្នកលោតឆត្រយោងធ្លាក់ បណ្តាលឱ្យមនុស្សយ៉ាងហោចណាស ១៦នាក់ស្លាប់

ម៉ូស្គូ: ក្រសួងផ្នែកសង្គ្រោះបន្ទាន់រុស្ស៊ីរាយការណ៍ថា យន្តហោះ១គ្រឿងដែលផ្ទុកអ្នកលោតឆត្រយោង១ក្រុមបានធ្លាក់ចុះបន្ទាប់ពីហោះឡើងនៅសាធារណរដ្ឋTatarstan ប្រទេសរុស្ស៊ីកាលពីព្រឹកថ្ងៃអាទិត្យដោយសម្លាប់មនុស្ស ១៦ នាក់និងធ្វើឱ្យរបួស ៦ នាក់។

អតិបាលនៃសាធារណរដ្ឋTatarstan លោកRustam Minnikhanovនិយាយថា អ្នកបើកយន្តហោះបានរាយការណ៍ថាម៉ាស៊ីនខាងឆ្វេងរបស់យន្តហោះមិនដំណើរការនៅពេលហោះបានរយៈកម្ពស់ ៧០ ម៉ែត្រ បន្ទាប់មកក៏ព្យាយាមចុះចតជាបន្ទាន់នៅជិតទីក្រុងMenzelinskដោយព្យាយាមបង្វែរយន្តហោះដើម្បីចៀសវាងតំបន់ដែលមានមនុស្សរស់នៅ ប៉ុន្តែស្លាបរបស់យន្តហោះបានបុកនឹងរថយន្តGazelle ខណៈដែលចុះចតបណ្តាលឱ្យក្រឡាប់។

យោងតាមក្រសួងសុខាភិបាលរុស្ស៊ី យន្តហោះឈ្មោះThe Let L-410 Turboletដែលធ្លាក់នេះ ដឹកអ្នកលោតឆត្រយោងចំនួន ២០ នាក់ និងអ្នកបើក២នាក់ ហើយសម្រាប់អ្នកដែលនៅរស់ទាំង ៦ នាក់ស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ។

លោក RavilNurmukhametovប្រធានក្លឹបហោះហើរដែលជាម្ចាស់យន្តហោះនិយាយថា អវកាសយានិកប្រើប្រាស់តំបន់ដែលយន្តហោះធ្លាក់នេះសម្រាប់ការហ្វឹកហាត់ ដោយក្លឹបបានរៀបចំការប្រកួតជើងឯកអឺរ៉ុបនិងជើងឯកពិភពលោកមួយ។

ទោះយ៉ាងណា លោកNurmukhametovបានបដិសេធធ្វើអត្ថាធិប្បាយវែងឆ្ងាយជុំវិញហេតុការណ៍ដែលកើតឡើង ដោយលើកឡើងថានឹងមានការស៊ើបអង្កេតការអនុវត្តច្បាប់ចំពោះករណីនេះ។ ចំណែកឯគណៈកម្មាធិការស៊ើបអង្កេតនិយាយថាខ្លួនបានបើកការស៊ើបអង្កេតព្រហ្មទណ្ឌទៅលើការសង្ស័យថារំលោភលើច្បាប់សុវត្ថិភាព។

រុស្ស៊ីរឹតបន្តឹងស្តង់ដាសុវត្ថិភាពអាកាសចរណ៍របស់ខ្លួនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះប៉ុន្តែគ្រោះថ្នាក់នៅតែបន្តកើតមានជាពិសេសនៅតំបន់ដាច់ស្រយាល។ កាលពីខែមុនយន្តហោះដឹកជញ្ជូនAntonov An-26 ចំណាស់១គ្រឿងធ្លាក់នៅភាគខាងកើតនៃប្រទេសដោយបណ្តាលឱ្យមនុស្ស ៦ នាក់ស្លាប់ ហើយកាលពីខែកក្កដា យន្តហោះម៉ាស៊ីនភ្លោះ Antonov An-26 មួយផ្សេងទៀតធ្លាក់នៅតំបន់Kamchatkaដោយធ្វើឱ្យមនុស្សទាំង ២៨ នាក់ដែលជិះស្លាប់ផងដែរ។ **ហួន ឌីណា**

ប្រទេសចំនួន ១៣៦ យល់ព្រមលើកិច្ចព្រមព្រៀងពន្ធសាជីវកម្មដ៏ធំបំផុតក្នុងរយៈពេល១សតវត្សរ៍

ហួន ឌីណា

ប្រទេសចំនួន ១៣០ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាសកលមួយស្តីពីកំណែទម្រង់ពន្ធសាជីវកម្មដែលមានគោលបំណងលុបបំបាត់ទីជម្រកពន្ធដោយនឹងជួយរកចំណូលជាង ១៥០ ពីលានដុល្លារក្នុង១ឆ្នាំបន្ថែមទៀតពីក្រុមហ៊ុនពហុជាតិ។

ប្រទេសទាំងនេះក៏យល់ព្រមផងដែរចំពោះការហាមឃាត់រយៈពេល២ឆ្នាំលើការដាក់ពន្ធថ្មីលើក្រុមបច្ចេកវិទ្យាដូចជាGoogle និង Amazon ខណៈពេលដែលរដ្ឋបាលរបស់លោកប្រធានាធិបតី ចូ បៃដិនព្យាយាមផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងនេះនៅសហរដ្ឋអាមេរិក។

កិច្ចព្រមព្រៀងដែលជាកំណែទម្រង់ពន្ធសាជីវកម្មដ៏ធំបំផុតក្នុងរយៈពេលជាង ១សតវត្សរ៍ដែលរៀបចំឡើងដោយអង្គការដើម្បីសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) នេះរួមបញ្ចូលទាំងអត្រាពន្ធសាជីវកម្មប្រកបដោយប្រសិទ្ធភាពអប្បបរមា ១៥ ភាគរយនៅទូទាំងពិភពលោក បូករួមទាំងច្បាប់ថ្មីដើម្បីបង្ខំឱ្យក្រុមហ៊ុនពហុជាតិរបស់ពិភពលោកប្រកាសប្រាក់ចំណេញនិងបង់ប្រាក់បន្ថែមនៅក្នុងប្រទេសដែលពួកគេធ្វើអាជីវកម្ម។

យោងតាមអ្នកដែលស្និទ្ធនឹងកិច្ចចរចានេះ ចំនួនប្រទេសដែលត្រៀមខ្លួនដើម្បីចុះបញ្ជីបានប្រែប្រួលនៅថ្ងៃសុក្រចុងសប្តាហ៍មុនដោយឥណ្ឌាយល់ព្រមចុងក្រោយគេបង្អស់ហើយមានចិននិងប្រេស៊ីលជាហត្ថលេខីដែលស្នាក់ស្នើរនឹងកិច្ចព្រមព្រៀងហើយមានតែស្រីលង្កា ប៉ាគីស្ថាន នីហ្សេរីយ៉ានិងកេនយ៉ាប៉ុណ្ណោះដែលបដិសេធវិញ។

កិច្ចព្រមព្រៀងនេះគឺជាជ័យជម្នះមួយសម្រាប់អង្គការOECD ដែលព្យាយាមទប់ស្កាត់ការចៀសវាងពន្ធសាជីវកម្មក្នុងរយៈពេលជាច្រើនឆ្នាំនៃការចរចាដ៏ស្មុគស្មាញ។ លោក Mathias Cormannអគ្គលេខាធិការរបស់អង្គការនិយាយថាកិច្ចព្រមព្រៀងនេះនឹងធ្វើឱ្យប្រព័ន្ធពន្ធសាជីវកម្មអន្តរជាតិមានយុត្តិធម៌និងដំណើរការល្អជាងមុន។

កិច្ចព្រមព្រៀងដដែលបានបញ្ចប់ព័ត៌មានលម្អិតស្តីពីការចែករំលែកប្រាក់ចំណេញរបស់ក្រុមហ៊ុនពហុជាតិធំៗ ដូច្នេះពួកគេបង់ពន្ធបន្ថែមនៅកន្លែងដែលពួកគេធ្វើអាជីវកម្ម។ ក្រុមហ៊ុនដែលមានចំណូលលើសពី ២០ពីលានផោននឹងត្រូវបែងចែក ២៥ ភាគរយនៃប្រាក់ចំណេញរបស់ពួកគេលើសពី ១០ ភាគរយសម្រាប់ប្រទេសដែលខ្លួនដំណើរការដោយផ្អែកលើការលក់របស់ខ្លួន។ ប្រាក់ចំណេញ ១០ ភាគរយនឹងត្រូវគណនាដោយប្រើយន្តការជាមធ្យមដោយផ្អែកលើប្រាក់ចំណេញមុនពេលបង់ពន្ធ។

ប្រទេសកំពុងអភិវឌ្ឍន៍បានត្អូញត្អែរអំពីការខ្វះប្រាក់ចំណូលដែលខ្លួនបានពីកិច្ចព្រមព្រៀងស្តីពីការបែងចែកប្រាក់ចំណេញត្រឹមត្រូវ និងសិទ្ធិបង់ពន្ធ។ប្រទេសទាំងនេះចង្អុលបង្ហាញថា បញ្ហានេះកាន់តែអាក្រក់ទៅៗដោយសារការដកពន្ធសេវាកម្មឌីជីថលទោះបីជាការប៉ាន់ស្មានរបស់OECD បង្ហាញថា ពួកគេនឹងទទួលបានក៏ដោយ។ ■

អគារក្រុមហ៊ុនបច្ចេកវិទ្យា Google**។** រូបថត AFP

ស្រីស្រស់កញ្ញា ប៉ូគីមថេង សុធីតា បានត្រងមកុដកញ្ចាងកដ៏អស្ចារ្យនៃកម្ពុជាឆ្នាំ២០២១

ប៉ាន់ រិទ្ធា

កញ្ញា ប៉ូគីមថេង សុធីតា ជាម្ចាស់មកុដ Miss Grand Cambodia2021។

រូបថត ហ្វេសប៊ុក

ភ្នំពេញ: ទីបំផុតក្តីស្រមៃដែលប្រាថ្នាចង់ក្លាយជាបេក្ខនារីតំណាងសម្រស់ឱ្យកម្ពុជាម្តងទៀតនៅលើឆាកអន្តរជាតិនៃពិភពប្រកួតបវរកញ្ញាពីស្រីស្រស់ជាតារាម៉ូដែលទើបអភិវឌ្ឍខ្លួនជាតារាសម្តែងភាពយន្តថ្មីថ្មោង-កញ្ញា ប៉ូគីមថេង សុធីតា នោះបានក្លាយជាការពិត។

កញ្ញា ប៉ូគីមថេង សុធីតា មានវ័យ ២៣ ឆ្នាំ មានកម្ពស់ ១,៧៥ ម៉ែត្រទម្ងន់៥៥គីឡូក្រាម និងមានទំហំទាំងបី ៣៤/២៤/៤០ មានស្រុកកំណើតនៅរាជធានីភ្នំពេញ តែជាបេក្ខនារីតំណាងសម្រស់ឱ្យខេត្តបាត់ដំបង កាលពីវគ្គជម្រុះ ២៥ រូបចុងក្រោយនោះ បានត្រងតំណែងជាម្ចាស់មកុដនៃការប្រកួតកញ្ញាឯកដ៏អស្ចារ្យនៃកម្ពុជាឆ្នាំ២០២១ នៅក្នុងវគ្គផ្តាច់ព្រ័ត្រ កាលពីចុងសប្តាហ៍កន្លងមកថ្មីៗនេះ។

ខណៈស្រីស្រស់ ប៉ូគីមថេង សុធីតា ក៏ជាអតីតកញ្ញាឯកអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩ និងជាអតីតកញ្ញាឯករងទី៣ ក្នុងការប្រកួតកញ្ញាឯក្តវាឡកម្ពុជាឆ្នាំ ២០១៩ និងការប្រកួតកញ្ញាទេសចរណ៍ពិភពលោកឆ្នាំ២០១៩ ផងដែរ។

ស្រីស្រស់ជយលាភី៥រូបចុងក្រោយនៃការប្រកួតMiss Grand Cambodia 2021។ ហ្វេសប៊ុក

ដោយឡែកកញ្ញា អ៊ិន លក្ខិណា បានជាប់ជាជយលាភីរងទី១ (1st Runner Up) ជាបេក្ខនារីតំណាងសម្រស់មកពីខេត្តកំពង់ចាម កញ្ញា អែម គុណថង ជាបេក្ខនារីតំណាងសម្រស់មកពីខេត្តព្រះសីហនុ ជាប់ជាជយលាភីរងទី២ (2nd Runner Up) កញ្ញា កែវ សេងលីហួរ ជាប់ជាជយលាភីរងទី៣ (3rd Runner Up) ជាបេក្ខនារីតំណាងសម្រស់មកពីខេត្តកំពត ហើយនឹងកញ្ញា សុខ វ៉ាត់ចារៈកន ជាបេក្ខនារីតំណាងសម្រស់មកពីខេត្តកំពង់ឆ្នាំង ជាប់ជាជយលាភីរងទី៤ (4th Runner Up) នៃការប្រកួតកញ្ញាឯកដ៏អស្ចារ្យនៃកម្ពុជាឆ្នាំ២០២១។

ព្រោះតែចង់ក្លាយជាកញ្ញាឯកតំណាងឱ្យប្រទេសកម្ពុជាម្តងទៀត នោះទើបកញ្ញា ប៉ូគីមថេង សុធីតា បានបង្ហើបពីហេតុផលខ្លួនចូលរួមសាជាថ្មីនេះដែរថា៖ «ដោយសារតែជាចំណូលចិត្ត តាំងពីក្មេងខាងវិស័យបវរកញ្ញា និងតែងតែបានតាមដាននូវរាល់កម្មវិធីប្រកួតបវរកញ្ញា ខណៈវាក៏ជាហេតុផលមួយជំរុញឱ្យរូបនាងខ្ញុំគិតគូរយ៉ាងច្បាស់លាស់ក្នុងការចូលមកប្រកួតកម្មវិធី Miss Grand Cambodia ឆ្នាំនេះផងដែរ។ ពិតប្រាកដណាស់ បំណងប្រាថ្នានាងខ្ញុំគឺចង់ឈ្នះការប្រកួតនេះ ហើយក៏ចង់ក្លាយជាតំណាងឱ្យកម្ពុជា សម្រាប់ឱកាសនៃការចូលរួមប្រកួតលើឆាកអន្តរជាតិ ដើម្បីឱ្យនាងខ្ញុំស្រែកពាក្យថា «Cambodia» ម្តងទៀត»។

កញ្ញា ប៉ូគីមថេង សុធីតា បានបន្តទៀតថា៖ «កម្មវិធី Miss Grand Cambodia នេះ ក៏បានផ្តោតសំខាន់លើការបញ្ឈប់អំពើហិង្សា និងសង្គ្រាមដែរ។ នាងខ្ញុំក៏ចង់ប្រើវេទិកាមួយនេះ ដើម្បីផ្ញើសារទៅកាន់ពិភពលោក ឱ្យបានដឹងពីគុណវិបត្តិនៃសង្គ្រាម និងបង្ហាញពីគុណសម្បត្តិនៃសន្តិភាព»។

ទោះបីជាធ្លាប់បានចូលរួមប្រកួតកម្មវិធីបវរកញ្ញាច្រើនលើកទាំងថ្នាក់ជាតិ និងអន្តរជាតិមែនក្តី ក៏ស្រីស្រស់កញ្ញា ប៉ូគីមថេង សុធីតា នៅតែបន្តឆន្ទៈចូលរួមកម្មវិធីប្រកួត Miss Grand Cambodia 2021 ម្តងទៀតនៅឆ្នាំនេះ រហូតដល់ទទួលបានជោគជ័យជាស្តាពរ ដោយកញ្ញាជាប់ជាកញ្ញាឯកសម្រាប់ឆ្នាំ២០២១។

កញ្ញា ប៉ូគីមថេង សុធីតា អតីតជាកញ្ញាឯកអាស៊ីប៉ាស៊ីហ្វិកឆ្នាំ ២០១៩ វ័យ ២៣ឆ្នាំ រាងខ្ពស់ស្រឡះរូបនេះ ក៏ទើបឆក់ឱកាសក្លាយជាតួឯកស្រីក្នុងភាពយន្តដំបូង គឺរឿង «Red Wall ជញ្ជាំងក្រហម» របស់ផលិតកម្ម LD ដែលជាការពង្រីកបន្ថែមនូវអាជីពសិល្បៈ និងសម្តែងប៉ះនឹងតារាសម្តែងប្រុសរាងសង្ហា ជាជនជាតិមីយ៉ាន់ម៉ា លោក Paing Takhon វ័យ ២៤ ឆ្នាំ ជាតារាម៉ូដែលលំដាប់លេខ ១ នៅប្រទេសមីយ៉ាន់ម៉ា ដែលមានកម្ពស់ ១,៨០ ម៉ែត្រ៕ ■

រដ្ឋមន្ត្រីដឹកជញ្ជូនឥណ្ឌាពិចារណាជំនួសសំឡេងស៊ីផ្លេដោយសូរឧបករណ៍តន្ត្រី

ក្រុងញូវដែលី : រដ្ឋមន្ត្រីដឹកជញ្ជូនឥណ្ឌាកំពុងពិចារណាលើច្បាប់មួយដែលនឹងជំនួសសំឡេងស៊ីផ្លេរថយន្តដ៏ទ្រហឹងនៃចរាចរណ៍ដ៏មមាញឹករបស់ប្រទេសនេះដោយសំឡេងឧបករណ៍តន្ត្រីវិញ។

លោក នីទីន ហ្គាដការី បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកថា៖ «ខ្ញុំកំពុងសិក្សាអំពីរឿងនេះ ហើយឆាប់ៗនេះខ្ញុំមានគម្រោងបង្កើតច្បាប់មួយដែលថា ស៊ីផ្លេយានជំនិះទាំងអស់គួរតែត្រូវបានជំនួសដោយឧបករណ៍តន្ត្រីឥណ្ឌា ដូច្នេះវាគួរឱ្យចង់ស្តាប់ណាស់»។

លោកបានបន្ថែមថា សំឡេងស៊ីផ្លេអាចបន្លឺឡើងដោយឮសូរខ្លុយ ស្គរ វីយូឡុង ឬអាម៉ូនីកា។

លោក ហ្គាដការី ក៏បាននិយាយផងដែរថា លោកចង់ជំនួសស៊ីរ៉ែនរថយន្តសង្គ្រោះ និងរថយន្តប៉ូលិសដ៏តក់ក្រហល់ ជាមួយនឹងសំឡេងបៃបទន់ភ្លន់សម្រួលផ្លូវចិត្តវិញ។

ប្រទេសឥណ្ឌាគឺជាទីក្រុងដែលមានសំឡេងរំខានបំផុតនៅលើពិភពលោក ដូចជា រ៉ឺម៉ក ឡានក្រុង តាក់ស៊ី ម៉ូតូ-ឌុប និងរថយន្តឯកជន ដណ្តើមទីចល័តនៅលើផ្លូវដ៏ស្ទះណែនណាន់តាន់តាប់។

ស៊ីផ្លេត្រូវបានគេចាត់ទុកថា ស្ទើរតែមានសារៈសំខាន់ដូចឈ្មាន់ហ្គែរ ហើយវាសំខាន់ជាងកញ្ចក់មើលក្រោយ។ ស៊ីផ្លេត្រូវបានប្រើដោយអ្នកបើកបរ ដើម្បីជូនដំណឹងដល់អ្នកប្រើប្រាស់ផ្លូវផ្សេងទៀតចំពោះវត្តមានរបស់ពួកគេជាជាងស្រែកស្តីបន្ទោស។

រថយន្តដឹកទំនិញចម្រុះពណ៌របស់ឥណ្ឌាជារឿយៗមានសារលាបពណ៌លើតួរថយន្ត ក្នុងគោលបំណងចង់ជែងអ្នកបើកបរដូចជា «ស៊ីផ្លេ អូខេ» ឬ «ចុចស៊ីផ្លេ»។

អង្គការសុខភាពពិភពលោកបានឱ្យដឹងថា ការបំពុលដោយសំឡេងអាចបណ្តាលឱ្យខ្សោយ ឬបាត់បង់សោតវិញ្ញាណ បញ្ហាសរសៃឈាមបេះដូង ការចុះខ្សោយការយល់ដឹង បញ្ហាស្ត្រេស និងជំងឺធ្លាក់ទឹកចិត្តជាដើម៕ AFP/HR ■



រដ្ឋមន្ត្រីក្រសួងដឹកជញ្ជូនឥណ្ឌា លោក នីទីន ហ្គាដការី។ រូបថត AFP

ហាងអាហារថៃល្បីឱ្យភ្ញៀវលុយទឹក ត្រាំជើងទទួលទានសាច់អាំង

ក្រុងបាងកក : តោជនីយដ្ឋានថៃមួយពុំបានបិទទ្វារដោយសារតែគ្រោះជំនន់ទឹកភ្លៀងនោះទេ ប៉ុន្តែម្ចាស់ហាងបានឆ្លៀតឱកាសទឹកលិចល្ហល្ហាចស្វាគមន៍ភ្ញៀវមកទទួលបទពិសោធអង្គុយតុកៅអីឈើ ទទួលទានសាច់អាំងឡើងភ្នំ លើផ្ទៃទឹកល្អក់ដូចកាហ្វេទឹកដោះគោ។

ព្យុះត្រូពិក និងខ្យល់មូសុងបោកបក់នាំមកនូវទឹកភ្លៀងលិចលង់ខេត្តចំនួន ៣៣នៅថៃ ដែលលេបត្របាក់ផ្ទះសំបែងពលរដ្ឋជាង ៣០ម៉ឺនគ្រួសារ និងឆក់យកជីវិតមនុស្ស៩នាក់។

ប៉ុន្តែក្នុងមហន្តរាយនេះ ក៏មានឱកាសល្អខ្លះសម្រាប់ហាងកាហ្វេ Chaopraya Antique Cafe នៅនុនថាប៊ូរី ដែលជាផ្នែកមួយនៃខ្សែទឹកហូរពីរាជធានីបាងកក។

នៅវេលារសៀល និងល្ងាច តោជនីយដ្ឋានបានពោរពេញទៅដោយភ្ញៀវអង្គុយទទួលទានសាច់អាំងខ្ជប់បន្លែ ហើយសើចក្អាកក្អាយបណ្តើរ លោតឡើងលើកៅអីបណ្តើរ នៅពេលដែលទូក និងកាណូតដឹកស្រូវអង្ករបរកាត់បង្កើតបានជាទឹករលកពណ៌កាហ្វេទឹកដោះគោ។

ភ្ញៀវលុយទឹកមកទទួលទានអាហារនៅហាងកាហ្វេ Chaopraya Antique Cafe។ រូបថត AFP

ជើងត្រាំទឹកកខ្វក់ ភ្ញៀវរីករាយនឹងសាច់អាំងឡើងភ្នំផ្ទាប់បន្លែស្រស់ៗ។ រូបថត AFP

នៅពេលដែលបាតុភូតគ្រោះ ទឹកជំនន់បានចាប់ផ្តើម ម្ចាស់ហាង ទីទីផន ជូទីម៉ាណុន ដើមឡើយគិតថាចង់បិទហាង ប៉ុន្តែក្រោយមកលោកបាននឹកឃើញថា ម៉ូយរបស់លោកបែបមិនប្រកាន់នឹងការអង្គុយលើទឹកអាំងសាច់ទទួលទាននោះទេ។

លោកបានថ្លែងប្រាប់ទីភ្នាក់ងារ AFP ថា៖ «គំនិតនេះត្រូវបានផ្សាយតៗគ្នាពីមាត់១ទៅមាត់១ ហើយក៏មានការចែករំលែករូបភាពវីដេអូហាងយើងលិចទឹក ហើយនៅតែមាន ភ្ញៀវដែលនាំឱ្យមានការចាប់អារម្មណ៍ខ្លាំងតាមបណ្តាញសង្គម»។

ការប៉ាន់ប្រមាណ តោជនីយដ្ឋាន ៥ ម៉ឺនកន្លែងបានបិទទ្វារដោយសារកូវីដ ហើយលោក ទីទីផន បានលើកឡើងថា៖ «បើខ្ញុំមិនតស៊ូទេ តែហ៊ានបិទហាងចោលម្តងទៀតពេលទឹកលិចនេះ ហាងរបស់ខ្ញុំច្បាស់ជាលែងស្រោចស្រង់បានហើយ»។

យ៉ាងណាមិញការដំណើរការលក់ម្ហូបអាហារក្នុងហាងលិចទឹក ពិតជារឿងមិនងាយស្រួលទេ។

លោកបាននិយាយថា៖ «ទាំងភ្ញៀវទាំងយើង សុទ្ធតែត្រូវលុយទឹក តែលំបាកជាងគេគឺអ្នករត់តុត្រូវព្យាយាមកាន់អាហារភ្ញៀវទៅកាន់តុ កុំឱ្យកំពប់។ រឹតតែពិបាក គឺរាល់ពេលទឹកជំនន់ថមថយកម្ពស់ បុគ្គលិកហាងត្រូវស្រូតរូតរះសម្អាតភក់ជ្រាំ»។

ការខិតខំប្រឹងប្រែងនេះពិតជាហុចផល ដោយយុវវ័យ និងក្រុមគ្រួសារជាច្រើនបានមកហាងរបស់លោកទទួលយកបទពិសោធនេះ។

អតិថិជនឈ្មោះ នើម អាយុ ៤៩ឆ្នាំ បាននិយាយថា៖ «សេដ្ឋកិច្ចយើងរាយ៉ាប់ណាស់ទៅហើយសព្វថ្ងៃ ហើយខ្ញុំគិតថា នេះជាគំនិតល្អ ដែលម្ចាស់ហាងចេះស្វែងរកឱកាសរស់ក្នុងគ្រោះមហន្តរាយផ្លូនៗ»។

អាជ្ញាធរសុខាភិបាលនៅបណ្តាប្រទេសជាច្រើនបានណែនាំពលរដ្ឋរបស់ខ្លួនកុំឱ្យត្រាំ ងូត ឬហែលទឹកជំនន់ដែលអាចមានផ្ទុកនូវលាមកកាកសំណល់មនុស្ស ទឹកលូស្អុយ កខ្វក់ និងកាកសំណល់ឧស្សាហកម្ម ដែលជាដើមចមនៃជំងឺឆ្លង និងរោគសើស្បែកនានា៕ AFP/HR ■

ដួងបំពេញក្រពះ ការរអិដ្ឋានដល់ព្រះ បុរស២នាក់រួចជីវិត ២៩ថ្ងៃលើសមុទ្រ

ក្រុងកូកូប៉ូ : បាត់ខ្លួននៅសមុទ្ររយៈពេល ២៩ថ្ងៃ អ្នកកោះសាឡូម៉ូន ២នាក់បានរួចជីវិតដោយអាស្រ័យការហូបបុកផ្លែដូង ផ្លែក្រូច និងការអធិដ្ឋានមុនពេលពួកគេត្រូវបានជួយសង្គ្រោះ នៅចម្ងាយ ៤០០ គីឡូម៉ែត្រពីឆ្នេរប៉ាពួ ញូវហ្គីណេ។

បុរសទាំង ២នាក់នេះកំពុងធ្វើដំណើររវាងកោះក្នុងសមុទ្រសាឡូម៉ូន ស្រាប់តែទូកប្រវែង ៧ម៉ែត្ររបស់ពួកគេត្រូវបានបំផ្លាញដោយអាកាសធាតុអាក្រក់ប៉ុន្មានម៉ោងនៅថ្ងៃទី៣ ខែកញ្ញា។

លោក លីវៃ ណានជីកាណា និង ជូលីកូឡានី រសាត់អណ្តែត ដោយសារភ្ញៀងធ្លាក់ខ្លាំងពពកខ្មៅ និងខ្យល់បក់ខ្លាំង។ នេះបើតាម ណានជីកាណា បានប្រាប់ប្រព័ន្ធផ្សព្វផ្សាយកោះសាឡូម៉ូនពីស្រុក PNG នៅស្រុកភូមីអូ។

នៅពេលដែលថ្មនៅក្នុងជីតិអេសរបស់ពួកគេអស់ ហើយពេលរាត្រីជិតមកដល់ ពួកគេបានបិទម៉ាស៊ីនកម្លាំង ៦០សេះរបស់ពួកគេ ដើម្បីសន្សំសំចៃប្រេងមួយគ្រាសិន។

បុរសទាំងនោះបានចំណាយពេលយប់ដំបូងរបស់ពួកគេក្រោមអំណាចខ្យល់ និងភ្ញៀងដែលបណ្តាលឱ្យទូករបស់ពួកគេឆ្ពោះទៅសមុទ្រឆ្ងាយ។

រយៈពេល ៩ថ្ងៃដំបូងពួកគេរស់នៅដោយទទួលទានផ្លែក្រូចដែលពួកគេបានខ្ជប់សម្រាប់ដំណើរលើសាគរ។

នៅពេលដែលអស់ស្បៀងទាំងនោះ ណានជីកាណា បាននិយាយថា៖ «យើងបានរួចជីវិតពីទឹកភ្ញៀង ដួង និងជំនឿរបស់យើងលើព្រះ ពីព្រោះយើងអធិដ្ឋានទាំងយប់ទាំងថ្ងៃ»។

ពួកគេត្រងទឹកភ្ញៀងនៅក្នុងថង់ និងប្រមូលអណ្តែតទឹកប្រណាំង ដើម្បីយកវាឡើងសម្រួលក្រពះមួយគ្រា។

លោក ណានជីកាណា បាននិយាយថា៖ «អស់ជាច្រើនថ្ងៃដោយសារយើងបានអធិដ្ឋាន ព្រះបានប្រទានគំនិតដល់យើងក្នុងការធ្វើក្តោងទូក និងច្នៃធ្វើច្រវាអុំ»។

នាវាប្រើកម្លាំងខ្យល់ និងច្រវាអុំបានបញ្ជូនពួកគេឆ្ពោះទៅកោះញូវប្រីថេន នៅប៉ាពួ ញូវហ្គីណេ ជាកន្លែងដែលពួកគេឃើញអ្នកនេសាទម្នាក់ពីចម្ងាយ។ ពួកគេបានបញ្ឆេះម៉ាស៊ីនទូកជាលើកចុងក្រោយ ស្រាប់តែរលត់អស់ប្រេងតែម្តង។

លោក ណានជីកាណា បាននិយាយថា៖ «នៅពេលនោះ យើងបានស្រែកបក់ដៃទៅកាន់អ្នកនេសាទ រហូតគាត់បានឃើញយើងហើយបញ្ជូនទូកមកក្បែរយើងហើយយើងមានអារម្មណ៍ថាដូចជាមានសុវត្ថិភាពហើយ»។

អ្នកទាំង២ស្ថិតក្នុងទីក្រុងនៃស្រុកភូមីអូ និងត្រៀមទទួលការបញ្ជូនមកកោះសាឡូម៉ូនវិញ៕ AFP/HR ■

បាត់ខ្លួននៅសមុទ្រ ២៩ថ្ងៃ បុរស ២នាក់ ប្រមូលផ្លែដូងហូបបន្តជីវិត។ រូបថត AFP

ពួកគេត្រូវបានសង្គ្រោះនៅចម្ងាយ ៤០០គីឡូម៉ែត្រពីឆ្នេរប៉ាពួ ញូវហ្គីណេ។ រូបថត AFP

បារាំងលើកពាន Nations League

កីឡាកររបស់ក្រុមបារាំង កំពុងលើកពានកម្មវិធី Nations League **ក្រោយឈ្នះអេស្ប៉ាញ កាលពីថ្ងៃអាទិត្យ។** AFP

ក្រុងមីឡាន: ខ្សែប្រយុទ្ធ Kylian Mbappe ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងជាមួយនឹងការមានសួនរួមយ៉ាងជំជែង ក្រោយពីបានស៊ុតគ្រាប់បាល់ជ័យជម្នះឱ្យក្រុមម៉ាន់គកបារាំង ដែលត្រូវក្រុមគោជល់អេស្ប៉ាញនាំមុខ ១ គ្រាប់មុន ពីការប្រកួត ក្នុងកម្មវិធី Nations League វគ្គផ្តាច់ព្រ័ត្រ កាលពីថ្ងៃអាទិត្យ នៅឯក្រុងមីឡាន ប្រទេសអ៊ីតាលី។

កីឡាករ Mbappe មានឱកាសស៊ុតបាល់បញ្ចូលទីជាមួយនឹងការនៅសល់តែប្រមាណជា ១០នាទីចុងក្រោយនៃការប្រកួត ដើម្បីជួយឱ្យក្រុមជើងឯកពិភពលោកឈ្នះពានរង្វាន់លីគ សម្រាប់ក្រុមជម្រើសជាតិ ប្រចាំតំបន់អឺរ៉ុប ដោយគ្រាប់បាល់នោះកើតឡើងបន្ទាប់ពីខ្សែប្រយុទ្ធ Karim Benzema បំប៉ោងសំណាញ់ទីឱ្យក្រុមបារាំងតាមស្មើ ក្នុងរយៈពេលតែ ២នាទី ក្រោយពី Mikel Oyarzabal ធ្វើបានសម្រេចឱ្យអេស្ប៉ាញនាំមុខ ក្នុងនាទីទី៦៤។

ជោគជ័យនេះ នឹងមិនត្រឹមតែជួយបន្ទរបន្ថយបានខ្លះៗពីការឈឺចាប់ ដែលកើតឡើងដោយសារការធ្លាក់ចេញពីព្រឹត្តិការណ៍ Euro 2020 ក្រោមថ្វីជើងរបស់ក្រុមជម្រើសជាតិស្វីសប៉ុណ្ណោះទេ តែថែមទាំងបង្ហាញឱ្យឃើញថា ក្រុមដ៏រឹងមាំបារាំង កំពុងធ្វើដំណើរឆ្ពោះទៅមុខយ៉ាងដូចម្តេច?

«ខ្ញុំពិតជាចង់ឈ្នះពានរង្វាន់ជាមួយក្រុមបារាំងណាស់ ហើយឥឡូវនេះ វាសម្រេចបានហើយ»។ នេះជាសម្តី ដែលនិយាយទៅកាន់ទូរទស្សន៍ M6 ពីសំណាក់កីឡាករ Benzema ដែលបានវិលត្រឡប់មកបង្ហាញខ្លួនជាមួយក្រុមជម្រើសជាតិវិញ នៅមុនព្រឹត្តិការណ៍ Euro ចាប់ផ្តើម។

កីឡាករវ័យ ៣៣ឆ្នាំ Benzema បានបន្ថែមថា៖ «យើងបានបង្ហាញឱ្យគ្រប់គ្នាឃើញនូវឥរិយាបថដ៏រឹងមាំ ព្រោះក្រុមនេះ គឺរឹងមាំណាស់ ពោលជាក្រុម ដែលមិនព្រមចុះចាញ់ឡើយ ហើយយើងបានបង្ហាញឱ្យឃើញ នៅថ្ងៃនេះ។ វាជាសញ្ញានៃក្រុមដ៏អស្ចារ្យ ដែលគ្មានការភ័យខ្លាច អត់ធ្មត់ នឹងរង់ចាំឱកាសដ៏សមរម្យ»។

ជាមួយគ្នានេះ គ្រូបង្វឹករបស់ក្រុម ដែលមានរហស្សនាមថា «Les Bleus» (ពណ៌ខៀវ) លោក Didier Deschamps អាចត្រូវអរគុណជាពិសេសចំពោះកីឡាករ Hugo Lloris ដែលការប្រកួតមិនចាំបាច់បន្តដល់វគ្គបន្ថែមម៉ោងពិសេស ១៥នាទី ២ដង ដោយសារតែអ្នកចាំទីរូបនេះ សង្គ្រោះបាល់បានយ៉ាងល្អពីការស៊ុតរបស់កីឡាករ Yeremi Pino ដែលជាឱកាសមាស ក្នុងការជួយឱ្យក្រុមអេស្ប៉ាញតាមស្មើ ក្នុងម៉ោងបន្ថែមមានរបួស។

ក្រុមបារាំងរបស់លោក Deschamps ពេលនេះ មិនទាន់ចាញ់នៅឡើយទេ ២៥ហ្គេម ពីការប្រកួត នៅគ្រប់កម្មវិធីទាំងអស់ ដោយធ្លាប់ធ្វើបានល្អជាងហ្នឹងតែម្តងគត់ នៅក្នុងប្រវត្តិសាស្ត្ររបស់ក្រុម កាលពីចន្លោះឆ្នាំ១៩៩៤ និងឆ្នាំ១៩៩៩។

នេះជាលើកទី៧ ក្នុងឆ្នាំ ២០២១ ដែលបារាំង គេចពីបរាជ័យបាន ក្រោយត្រូវក្រុមគូប្រជែងនាំមុខ ក្នុងនោះរួមទាំងការតាមពីក្រោយក្រុមបែលហ្សិក ក្នុងវគ្គ ៤ក្រុមចុងក្រោយនៅមុននេះដែរ៕ AFP/VN ■

អ៊ីតាលី ឈ្នះបែលហ្សិក ដើម្បីបញ្ចប់នៅលេខ ៣

ក្រុងទូរីន: ក្រុមជម្រើសជាតិអ៊ីតាលី ដណ្តើមបានចំណាត់ថ្នាក់លេខ៣ ក្នុងកម្មវិធី Nations League កាលពីថ្ងៃអាទិត្យ ក្រោយពីយកឈ្នះក្រុមបែលហ្សិក ២-១ ដែលជាលទ្ធផលអាចជួយឱ្យលុបលាងពីការបាត់បង់កំណត់ត្រាមិនចាញ់សោះរបស់ខ្លួន។

ការស៊ុតបាល់ ក្នុងលម្ហូចូលទីយ៉ាងអស្ចារ្យរបស់កីឡាករ Nicolo Barella ក្រោយការប្រកួត នៅវគ្គទី២ ដំណើរការទៅត្រឹមតែ ១នាទី និងការស៊ុតបាល់ប៉េណាល់ទីបានសម្រេចរបស់ Domenico Berardi នៅនាទីទី៦៣ គឺគ្រប់គ្រាន់ដើម្បីឱ្យក្រុមរហស្សនាម «Azzurri» (ពណ៌ខៀវ) មានជ័យជម្នះលើក្រុមពណ៌ទឹកក្រូចដែលគ្មានវត្តមានរបស់ខ្សែប្រយុទ្ធ Romelu Lukaku និងខ្សែបម្រើ Eden Hazard ដោយសារតែរបួស។

ក្រុមជើងឯកអឺរ៉ុបអ៊ីតាលី ដែលត្រូវបានក្រុមគោជល់អេស្ប៉ាញ យកឈ្នះ ក្នុងវគ្គ ៤ក្រុមចុងក្រោយ កាលពីយប់ថ្ងៃពុធ និងដែលដំណើរមិនចាញ់សោះរបស់ខ្លួន ៣៧ ប្រកួត ត្រូវបញ្ចប់នោះ បានលេងយ៉ាងមានជីវិតជីវ៉ា ក្រោមរស្មីព្រះអាទិត្យដ៏ស្រស់ស្អាត នៅឯកីឡដ្ឋាន Allianz ក្នុងក្រុងទូរីន តែសំណាងមិនល្អរបស់ក្រុមបែលហ្សិក នៅបន្តកើតមាន ចាប់តាំងពីភ្លាត់ឱ្យបារាំងវាយបកយកជ័យជម្នះនៅនាទីចុងក្រោយ ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ កាលពីថ្ងៃព្រហស្បតិ៍។

ខ្សែប្រយុទ្ធ Alexis Saelemaekers ដែលចាប់ផ្តើមចូលលេងដំណាលខ្សែបម្រើ Kevin De Bruyne ខ្សែប្រយុទ្ធ Michy Batshuayi និងខ្សែបម្រើ Yannick Carrasco សុទ្ធតែបានស៊ុតបុករបារទីដូចគ្នា មុនពេលដែលកីឡាករ Charles De Ketelaere អាចរកបាល់ឱ្យក្រុមហូឡង់បាន នៅប្រមាណជា ៤នាទីចប់ការប្រកួត។

វាជាថ្ងៃប្រកបដោយភាពវិជ្ជមានសម្រាប់គ្រូបង្វឹកក្រុមអ៊ីតាលី លោក Roberto Mancini ដែលបានមើលឃើញថា កីឡាករ Federico Chiesa ជាតារាដ៏លេចធ្លោនៅតំបន់ប្រយុទ្ធសម្រាប់ការសាកល្បងរបស់គាត់។

«យើងលេងល្អណាស់ នៅថ្ងៃនេះ។ កីឡាករ Chiesa អាចលេងបានគ្រប់កន្លែងទាំងអស់ មិនថា ស្លាបស្តាំ ឬឆ្វេង។ ថ្ងៃនេះ គេលេងនៅស្លាបឆ្វេង ហើយគេពិតជាធ្វើបានល្អណាស់។ គេគឺជាកីឡាករដ៏សំខាន់ម្នាក់»។ គ្រូបង្វឹករបស់ក្រុមអ៊ីតាលី លោក Mancini បានថ្លែងទៅកាន់ទូរទស្សន៍ក្នុងស្រុក RAI៕ AFP/VN ■

អាហ្សង់ទីន បំបាក់អ៊ុយរូហ្គាយ ខណៈប្រេស៊ីល បាត់បង់កំណត់ត្រា ១០០ឆាគរយ

ក្រុងម៉ុងតេវីដេអូ: ខ្សែប្រយុទ្ធ Lionel Messi ជាអ្នកស៊ុតគ្រាប់បាល់បើកឆាក ខណៈដែលក្រុមពពកសអាហ្សង់ទីន ឈ្នះក្រុមជិតខាងអ៊ុយរូហ្គាយ ដោយស្រួលៗ ៣-០ ពីការប្រកួត ក្នុងវគ្គជម្រុះ World Cup ប្រចាំតំបន់អាមេរិកឡាទីន (CONMEBOL) កាលពីថ្ងៃអាទិត្យ។

គ្រាប់បាល់ ២គ្រាប់ទៀត ដែលធ្វើបានសម្រេចដោយខ្សែបម្រើ Rodrigo De Paul និងខ្សែប្រយុទ្ធ Lautaro Martinez បានជួយបញ្ចប់រាត្រីដ៏ជោគជ័យមួយក្នុងក្រុងប៊ុយណូសៃ សម្រាប់លោក Lionel Scaloni ដែលក្រុមរបស់លោក បាននិងកំពុងបន្តនូវការចាប់ផ្តើមមិនចាញ់សោះក្នុងយុទ្ធនាការវគ្គជម្រុះ និងមានគម្លាតកាន់តែកៀកនឹងក្រុមនាំមុខគេប្រេស៊ីល ដោយតាមពីក្រោយត្រឹមតែ ៦ពិន្ទុ ក្នុងតារាងពិន្ទុ ដែលមានតែ ១ នៃតំបន់ CONMEBOL។

«ពួកយើងពិតជាលេងបានយ៉ាងអស្ចារ្យ ខ្ញុំគិតថា យើងអភិវឌ្ឍបានយ៉ាងល្អប្រសើរជាងមុនច្រើនវាជាការប្រកួតដ៏តឹងតែង ហើយយើងត្រូវតែឈ្នះឱ្យបាន។ ក្រុមអ៊ុយរូហ្គាយ បានតាមពីក្រោយពួកយើង ហើយជាក្រុមដ៏គ្រោះថ្នាក់មួយ។ នៅពេលយើងស៊ុតបញ្ចូលទីគ្រាប់ដំបូងបាន យើងចាប់ផ្តើមរកឃើញចន្លោះកាន់តែច្រើនឡើង ហើយគ្រាប់បាល់ផ្សេងទៀតបានកើតឡើង»។ នេះជាសម្តីរបស់កីឡាករ Messi ដែលជាកីឡាកររកគ្រាប់បាល់បានច្រើនជាងគេនៅតំបន់ CONMEBOL នេះ។

ការត្រឡប់មកវិញរបស់ខ្សែប្រយុទ្ធ Neymar ក៏មិនអាចជួយឱ្យក្រុមជម្រើសជាតិប្រេស៊ីល មានលទ្ធភាពដណ្តើមជ័យជម្នះបានឡើយ ខណៈដែលក្រុមម្ចាស់ផ្ទះកូឡុំប៊ី បានមកបញ្ចប់យុទ្ធនាការវគ្គជម្រុះដ៏ឥតខ្ចោះរបស់ពួកគេ ក្រោយការប្រកួត ក្នុងទីក្រុងបារ៉ាឡ្វីយ៉ា បានចប់ទៅ ក្នុងលទ្ធផលដោយគ្មានគ្រាប់បាល់។

Messi (**ឆ្វេងទី២**) **របស់អាហ្សង់ទីន បានស៊ុតបាល់ ពេលប្រកួតទល់នឹងអ៊ុយរូហ្គាយ។** AFP

ក្រុមប្រេស៊ីល ដែលមាន ២៨ពិន្ទុ បានឈ្នះទាំងអស់សម្រាប់ការប្រកួត ៩លើកដំបូងរបស់ខ្លួន ក្នុងវគ្គជម្រុះនេះ ក្នុងនោះស៊ុតបញ្ចូលទីបានដល់ទៅ ២២គ្រាប់ និងនាំមុខ ៨ពិន្ទុលើក្រុមលេខ២ អាហ្សង់ទីន នៅមុនពេលការប្រកួតនេះចាប់ផ្តើម។

តែយ៉ាងណាក្តី ក៏ក្រុមប្រេស៊ីល របស់គ្រូបង្វឹកលោក Tite នៅតែមានក្តីសង្ឃឹមស្ទើរតែ ១០០ភាគរយហើយ ក្នុងការបានសិទ្ធិទៅចូលរួមព្រឹត្តិការណ៍ World Cup 2022 នៅប្រទេសកាតា ដោយសារកំពុងនាំមុខដល់ទៅ ១៣ពិន្ទុពីលើក្រុមលេខ៥ កូឡុំប៊ី ព្រោះក្រុមនៅលើគេទាំង៤ ប្រចាំតំបន់អាមេរិកឡាទីននេះ នឹងបានឡើងស្វ័យប្រវត្តិ រីឯក្រុមលេខ៥ ត្រូវលេងវគ្គចាញ់ធ្លាក់អន្តរតំបន់។

បើទោះបីជាក្រុមមិនទទួលបានជ័យជម្នះក៏ពិតមែន ក៏លោក Tite នៅតែពោលសរសើរកីឡាករ Neymar ដែរ ដោយលោកប្រាប់ថា៖ «Neymar ធ្វើបានល្អណាស់ ក្នុងនាមជាអ្នកដឹកនាំក្រុម នៅលើទីលាន ព្រោះគេប្រែប្រួលបានយ៉ាងប្រសើរជាមួយនឹងវិធីលេងរបស់កូឡុំប៊ី ជាក្រុម ដែលមានគុណភាពខាងតិចនិកល្អជាងក្រុមផ្សេងៗទៀត»៕ AFP/VN ■

កីឡាករ ទូច ដេវីត បានម៉ាត់ទៅលើ សែត សារីត ពេលប្រកួត កាលពីថ្ងៃអាទិត្យ។ រូបថត សហការី

វី សម្ភស្ស សម្រេចការសងសឹក ឯ ទូច ដេវីត ឡើងទៅវគ្គផ្តាច់ព្រ័ត្រ

យឺន ពន្លក

ភ្នំពេញ: កីឡាករប្រដាល់សកលជម្រើសជាតិ វី សម្ភស្ស (អេលីត សម្ភស្ស) បានសម្រេចការសងសឹកទៅលើអតីតកីឡាករជម្រើសជាតិ ផល សោភ័ណ្ឌ សម្រាប់ការជួបគ្នាដោយមិនបានត្រៀមទុកកាលពីថ្ងៃអាទិត្យ ក្នុងព្រឹត្តិការណ៍ប្រដាល់សកល Ultimate Boxing Championship 2021 ចំណែក ទូច ដេវីត បានយកឈ្នះលើកីឡាករជម្រើសជាតិដូចគ្នា គឺ សែត សារីត ដើម្បីឡើងទៅកាន់វគ្គផ្តាច់ព្រ័ត្រ។

តាមគម្រោងពីដំបូងឡើយ វី សម្ភស្ស ត្រូវដាក់ឱ្យជួប ម៉ន ព្រហ្មម៉ាញ ដើម្បីដណ្តើមប្រាក់លាន ប៉ុន្តែដោយសារ ម៉ន ព្រហ្មម៉ាញ មានបញ្ហាសុខភាព អ៊ីចឹង គណៈកម្មការ បានលើកពេលទៅសប្តាហ៍ទី៨វិញ ហើយដាក់សម្ភស្ស ឱ្យប្រកួតជាមួយជើងខ្លាំង ផល សោភ័ណ្ឌ ក្នុងហាន:ជាគូដណ្តើមប្រាក់លាន លើប្រភេទទម្ងន់៦៣,៥គីឡូក្រាម ហើយតាមលទ្ធផលនេះ ទូច ដេវីត ត្រូវឡើងទៅវគ្គផ្តាច់ព្រ័ត្រ ដោយរង់ចាំការប្រកួតគ្នារវាង វី សុភ័ស និង ម៉ាង ព្រហ្មម៉ាញ នាសប្តាហ៍ទី៤ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២១ ខាងមុខ។

ទាក់ទងនឹងប្រកួតនេះ ទូច ដេវីត និយាយថា៖ «ការប្រកួតនៅជុំទី២ (វគ្គផ្តាច់ព្រ័ត្រ) ទោះត្រូវប៉ះ ម៉ន ព្រហ្មម៉ាញ ឬ វី សម្ភស្ស គឺសុទ្ធតែខ្លាំង លំបាក នឹងរកល្បិចកលយកឈ្នះដូចគ្នា តែការហ្វឹកហាត់បន្ត ខ្ញុំនៅតែខំប្រឹងជានិច្ច»។

ចំណែកលោក ប៊ុយ សុភ័ណ្ឌ អ្នករៀបចំការប្រកួតនេះ បានប្រាប់ថា៖«យើងសង្កេតឃើញថា ការប្រកួតលើកនេះមានភាពទាក់ទាញ ក៏ដូចជាមានការគាំទ្រកាន់តែច្រើន លើសពីសប្តាហ៍មុនៗ ព្រោះនៅសប្តាហ៍នេះ យើងបានរៀបចំកីឡាករប្រកួតដណ្តើមប្រាក់លាន គូឯក និងគូពិសេស សរុប៦គូ ដែលកីឡាករជើងចាស់ ប៉ះជាមួយកីឡាករយុវជនថ្មីៗ មានភាពទាក់ទាញខ្លាំងជាមុនៗ»។

អគ្គលេខាធិការសហព័ន្ធកីឡាប្រដាល់សកលកម្ពុជា លោក ប៊ុយ សុភ័ណ្ឌ បានបន្ថែមថា៖«យើងសង្កេតឃើញថា មានអ្នកគាំទ្រច្រើន តាមរយៈការផ្សាយផ្ទាល់លើផេចផ្លូវការរបស់សហព័ន្ធកីឡាប្រដាល់សកលកម្ពុជា និងផេចដៃគូមួយចំនួនទៀត ហើយតាមពិត នៅសប្តាហ៍នេះ យើងត្រៀមរៀបចំ ២គូ សម្រាប់គូដណ្តើមប្រាក់លាន ប៉ុន្តែដោយសារកីឡាករ ម៉ាង ព្រហ្មម៉ាញ មានបញ្ហាសុខភាព ទើបពន្យារពេលដូច្នេះ វី សម្ភស្ស នឹងឡើងមកប្រកួតជាមួយ ម៉ាង ព្រហ្មម៉ាញ នៃគូដណ្តើមប្រាក់លាន សម្រាប់សប្តាហ៍ទី៤»៕ ■

ព្រះនាងតូច នរោត្តម ជេនណា កាន់តែលេចធ្លោលើវិថីសិល្បៈ

ប៉ាន់ រិទ្ធា

ភ្នំពេញ: នារយៈពេលជាង ២ ឆ្នាំ ចុងក្រោយនេះ កុមារីជាពន្លកតារាចម្រៀង តារាសម្តែង និងតារាម៉ូដែល ជាប់សែស្រឡាយព្រះរាជវង្ស ព្រះនាងតូច នរោត្តម ជេនណា កំពុងតែមានរាសីឡើងខ្លាំង ដោយទ្រង់ក្តៅបាននូវឱកាសជាប្រើនលើវិថីសិល្បៈ ស្ទើរគ្រប់ទម្រង់ ទាំងវិស័យសម្តែងភាពយន្ត និងចម្រៀង។

ក្នុងឱកាសថ្ងៃបុណ្យភ្ជុំបិណ្ឌតាមគន្លងប្រពៃណី ជាតិ សាសនា ឆ្នាំ២០២១ កន្លងមកថ្មីៗនេះ តាមរយៈផលិតកម្មអនឡាញ NCJ Empire Studio ព្រះនាងតូច ជេនណា បានចេញអាល់ប៊ុមទី២នៃចម្រៀងទាំងប្រភេទអ៊ូរីជីណល និងច្រៀងឡើងវិញបំពេរអារម្មណ៍ប្រិយមិត្ត នារដូវកាលបុណ្យភ្ជុំបិណ្ឌឆ្នាំនេះ ដែលទទួលបានការគាំទ្រយ៉ាងប្រើនរួមមានបទ «អូនអើយអូន»-បទ «ភ្ជុំបិណ្ឌទំនៀមខ្មែរ» បទ «វេចអន្សមភ្ជុំ» បទ «ភ្ជុំបិណ្ឌចាំស្នេហ៍» បទ «តាលុងផ្តាំស្នេហ៍» និងបទ «ភ្ជុំបិណ្ឌជុំញាតិ»។

ព្រះនាងតូច នរោត្តម-ជេនណា ដែលទ្រង់មានទេពកោសល្យ និងដុងពីកំណើត លើវិស័យសិល្បៈទាំងបុរាណ និងសម័យ ហើយចេះនិយាយ ៥ ភាសា និងមានព្រះជន្ម ៩ វស្សា នៅឆ្នាំ២០២១ នេះ ទ្រង់បង្ហើរសារថា៖ «បទ-«វេចអន្សមភ្ជុំ» ច្រៀងឡើងវិញ ដោយព្រះនាងតូច នរោត្តម ជេនណា ជាសំនៀងដើមលោកស្រី ប៉ែន រ៉ន និពន្ធបទ និងទំនុកច្រៀងដោយ លោក ឯល ប៊ុលណា។ សូមពុកម៉ែ បងប្អូន រីករាយស្តាប់កម្សាន្តនារដូវបុណ្យភ្ជុំបិណ្ឌនេះ សូមធ្វើដំណើរដោយសុខសប្បាយ សំណាងល្អ សុខភាពល្អ សូមឱ្យការជួបជុំ ប្រកបដោយភាពរីករាយ តែកុំភ្លេចពាក់ម៉ាស់ណា បង-ប្អូន ៣ កុំ ៣ ការពារ»។

ព្រះនាងតូច នរោត្តម ជេនណា គ្រងឈុតប្រពៃណីមានទង់ជាតិខ្មែរ។ រូបថត ហ្វេសប៊ុក

តារាចម្រៀង ម៉ូដែល ជាសែស្រឡាយរាជវង្ស ព្រះនាងតូច នរោត្តម ជេនណា។ ហ្វេសប៊ុក

មិនតែប៉ុណ្ណោះព្រះនាងតូចក៏លេចវត្តមានសម្តែងខ្សែភាពយន្តភាគ ២ រឿង ដែលផលិតដោយស្ថានីយទូរទស្សន៍ស៊ីធីអិនគឺរឿង «ទេពធីតាជ្តលមាស» នៅដើមឆ្នាំ២០២០ និងរឿង «នគរមាស» នៅដើមឆ្នាំ ២០២១ នេះ ខណៈទាំង២រឿង ព្រះនាងតូច សុទ្ធតែដើរជាតួអង្គឯក ដោយរឿង ១ ព្រះនាងសម្តែងជាតួអង្គក្នុងវណ្ណៈខ្ពស់ និងរឿង១ទៀត សម្តែងជាតួអង្គក្រខ្សត់ និងកម្សត់។

បើគិតមកត្រឹមពាក់កណ្តាលឆ្នាំ ២០២០ មកព្រះកិត្តិយសព្រះនាងតូចកំពុងតែបោះពួយឡើងជាលំដាប់លើវិថីសិល្បៈទាំងចម្រៀង និងសម្តែង ដោយគេឃើញព្រះនាង ជេនណា លេចវត្តមានក្នុងការថតស្ប៉ត ពាណិជ្ជកម្មនានា ជាតារាកិត្តិយស សម្ពោធកម្មវិធីសង្គម ជាញឹកញយ ថតកុន និងត្រូវក្រុមហ៊ុនទូរស័ព្ទ Cellcard-ជ្រើសជាទូតសុច្ឆន្ទៈទៀតផង។

កាលពីឆ្នាំ២០១៩ បានបង្កើតនូវភាពត្បាក់ផ្អើលខ្លាំងតាមបណ្តាញសង្គមហ្វេសប៊ុក និងយូធូប ជាមួយនឹងសូរសំនៀងដ៏ពីរោះបកស្រាយបទ «ដួងចន្ទ» របស់កុមារី ទើបតែមានព្រះជន្ម ៧ ឆ្នាំ ហើយជាប់សែស្រឡាយរាជវង្សខ្មែរ គឺជាព្រះនាងតូច នរោត្តម ជេនណា ដែលជាបុត្រីទី ២ អ្នកអង្គម្ចាស់ នរោត្តម បុប្ផារី និងត្រូវជាចៅស្រីរបស់ព្រះអង្គម្ចាស់ នរោត្តម-ចក្រពង្ស៊ូ៕ ■